#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

ជំពូកទី៣ៈ
ក្របខណ្ឌច្បាប់ដែលពាក់ព័ន្ធ

Draft

ជំពូកទី៣: ក្របខណ្ឌច្បាប់ពាក់ព័ន្ធ

ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងរបាយការណ៍ទាំងឡាយត្រូវចងក្រង និងធ្វើឡើងដោយ អនុលោមតាម ក្របខ័ណ្ឌច្បាប់និងអនុក្រឹត្យនានាដែលពាក់ព័ន្ធទៅនឹងគម្រោងអភិវឌ្ឍន៍ដូចខាងក្រោម៖

៣.១ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (១៩៩៣)

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជានេះ ត្រូវបានសភារដ្ឋធម្មនុញ្ញអនុម័ត កាលពីថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ នាសម័យប្រជុំលើកទី២។ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មានសេចក្តីសំខាន់ៗដូចខាងក្រោម៖

<u>មាត្រា១</u>៖ ប្រទេសកម្ពុជាជាព្រះរាជាណាចក្រ ដែលព្រះមហាក្សត្រទ្រង់ប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ និងតាមលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស។ ព្រះរាជាណាចក្រកម្ពុជា ជារដ្ឋឯករាជ្យ សន្តិភាព អព្យាក្រឹត្យ អចិន្ត្រៃយ៍ មិនចូលបក្សសម្ព័ន្ធ។

<u>មាត្រា៣១</u>៖ ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ។

- ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីយកិច្ច ដូចគ្នាទាំងអស់ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ។ ការប្រើសិទ្ធិសេរីភាពផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ មិនត្រូវអោយប៉ះពាល់ដល់សិទ្ធិសេរីភាពអ្នកដទៃឡើយ។ ការប្រើសិទ្ធិសេរីភាពនេះ ត្រូវប្រព្រឹត្តតាមលក្ខខ័ណ្ឌកំណត់ក្នុងច្បាប់។

<u>មាត្រា២២</u>៖ ជនគ្រប់រូប មានសិទ្ធិរស់រានមានជីវិត មានសេរីភាព និងមានសន្តិសុខផ្ទាល់ខ្លួន។ ទោសប្រហារជីវិតមិនត្រូវឱ្យមានឡើយ។

<u>មាត្រា៣៦</u>៖ ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិជ្រើសរើសមុខរបរ សមស្របតាមសមត្ថភាពរបស់ខ្លួនតាមសេចក្តីត្រូវការរបស់សង្គម។

- ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិទទួលប្រាក់បំណាច់ស្មើគ្នាចំពោះការងារដូចគ្នា។

- ការងារមេផ្ទះមានតម្លៃស្មើគ្នានឹងកំរៃដែលបានមកពីការងារធ្វើនៅក្រៅផ្ទះ។
- ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិទទួលការធានារ៉ាប់រងសង្គម និងអត្ថប្រយោជន៍ខាងសង្គមកិច្ច ដែលមានចែងក្នុងច្បាប់។
- ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិបង្កើតសហជីព និងចូលជាសមាជិកសហជីពនេះ។
- ការរៀបចំ និងការប្រព្រឹត្តទៅនៃសហជីព នឹងមានកំណត់ក្នុងច្បាប់។

<u>មាត្រា៣៧</u>៖ សិទ្ធិធ្វើកូដកម្ម និងធ្វើបាតុកម្មដោយសន្តិវិធី ត្រូវយកមកអនុវត្តនៅក្នុងក្របខ័ណ្ឌនៃច្បាប់

<u>មាត្រា៣៨</u>៖ ច្បាប់ រ៉ាប់រងមិនឱ្យមានការរំលោភបំពានលើរូបរាងកាយបុគ្គលណាមួយឡើយ។

- ច្បាប់ការពារជីវិត កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ។
- ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនជនណាមួយ និងអាចធ្វើទៅកើត លុះត្រាតែ អនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់។
- ការបង្ខិតបង្ខំ ការធ្វើបាបរូបរាងកាយ ឬប្រព្រឹត្តិកម្មណាមួយដែលបន្ថែមទម្ងន់ទណ្ឌកម្មអនុវត្តចំពោះជនជាប់ឃុំឃាំង ឬជាប់ពន្ធនាគារត្រូវហាមឃាត់មិនឱ្យធ្វើឡើយ។ អ្នកដែដល់ អ្នករួមប្រព្រឹត្តិ និងអ្នកសមគំនិតត្រូវទទួលទោសតាមច្បាប់។
- ការទទួលសារភាពដែលកើតឡើងពីការបង្ខិតបង្ខំតាមផ្លូវកាយក្តី មិនត្រូវទុកជាភស្តុតាងនៃពិរុទ្ធភាពទេ។
- រឿងសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ។
- ជនជាប់ចោទណាក៏ដោយ ត្រូវទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ។
- ជនគ្រប់រូបមានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ។

<u>មាត្រា៣៩</u>៖ ប្រជាពលរដ្ឋខ្មែរមានសិទ្ធិប្តឹងបរិហារ ប្តឹងតវ៉ា ឬប្តឹងទារសំណងជួសជុលការខូចខាតដែលបណ្តាលមកពីអំពើខុសច្បាប់របស់អង្គការរដ្ឋ របស់អង្គការសង្គម និងរបស់បុគ្គលិកនៃអង្គការទាំងនោះ។ ការដោះស្រាយបណ្តឹងតវ៉ា និងសំណងជួសជុលការខូចខាតជាសមត្ថកិច្ចរបស់តុលាការ។

<u>មាត្រា៤០</u>៖ ជនណាក៏ដោយ ទោះជាបុគ្គលក្តី ជាសមូហភាពក្តី មានសិទ្ធិជាម្ចាស់កម្មសិទ្ធិ។ មានតែរូបវន្តបុគ្គល ឬនិតិបុគ្គលដែលមានសញ្ជាតិជាខ្មែរទេ ទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លី។

- កម្មសិទ្ធិឯកជនស្របច្បាប់ ឋិតនៅក្រោមការគាំពារនៃច្បាប់។ ដែលនឹងដកហូតកម្មសិទ្ធិអំពីជនណាមួយបាននោះ លុះត្រាតែប្រយោជន៍សាធារណៈតំរូវអោយធ្វើ

ក្នុងករណី ដែលច្បាប់បានបញ្ញត្តិទុក ហើយត្រូវផ្តល់សំណងជាមុន ដោយសមរម្ម និងយុត្តិធម៌។

<u>មាត្រា៤៨</u>៖ ការរើសអើងគ្រប់ប្រភេទប្រឆាំងនឹងស្ត្រីភេទត្រូវបំបាត់ចោល។

- ការធ្វើអាជីវកម្មលើការងារស្ត្រីត្រូវហាមឃាត់។
- បុរស និងស្ត្រីមានសិទ្ធិស្មើគ្នាក្នុងគ្រប់វិស័យទាំងអស់ ជាពិសេសក្នុងអាពាហ៍ពិពាហ៍ និងគ្រួសារ។
- អាពាហ៍ពិពាហ៍ត្រូវធ្វើតាមលក្ខខ័ណ្ឌដែលមានចែងក្នុងច្បាប់ និងតាមគោលការណ៍ស្ម័គ្រចិត្តប្តីមួយប្រពន្ធមួយ។

<u>មាត្រា៤៩</u>៖ អំពើលក់ដូរមនុស្ស អំពើធ្វើអាជីវកម្មផ្នែកពេស្យាកម្ម និងអំពើអាសអាភាសន៍ដែលប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់នារី ត្រូវហាមឃាត់។

- ត្រូវហាមឃាត់មិនឱ្យមានការបញ្ឈប់នារីពីការងារ ដោយមូលហេតុមានគភ៌។ នារីមានសិទ្ធិឈប់សំរាកនៅពេលសំរាលកូន ដោយទទួលប្រាក់បៀវត្ស និងដោយមានការធានារក្សាសិទ្ធិអតីតភាពក្នុងការងារ និងអត្ថប្រយោជន៍សង្គមផ្សេងៗទៀត។
- រដ្ឋ និងសង្គមយកចិត្តទុកដាក់បង្កលក្ខណៈឱ្យនារី ជាពិសេសនារីនៅជនបទដែលគ្មានទីពឹង បានទទួលការឧបត្ថម្ភដើម្បីមានមុខរបរ មានលទ្ធភាពព្យាបាលជម្ងឺ ឱ្យកូនមានជីវភាពរស់នៅសមរម្ម។

<u>មាត្រា៤៨</u>៖ រដ្ឋធានារក្សាការពារសិទ្ធិរបស់កុមារ ដែលមានចែងក្នុងអនុសញ្ញាស្តីពីកុមារ ជាពិសេសសិទ្ធិមានជីវិតរស់នៅ សិទ្ធិទទួលការអប់រំរៀនសូត្រ សិទ្ធិត្រូវបានទទួលការគាំពារក្នុងស្ថានការណ៍មានសង្គ្រាម និងការការពារប្រឆាំងនឹងអាជីវកម្មសេដ្ឋកិច្ច ឬកាមគុណលើកុមារ។

- រដ្ឋគាំពារប្រឆាំងនឹងការងារទាំងឡាយដែលអាចធ្វើឱ្យខូចដល់ការអប់រំ និងការរៀនសូត្ររបស់កុមារ ឬដែលនាំអោយអន្តរាយដល់សុខភាព ឬសុខុមាលភាពរបស់កុមារ។

<u>មាត្រា៥០</u>៖ ប្រជាពលរដ្ឋខ្មែរទាំងពីរភេទត្រូវគោរពគោលការណ៍អធិបតេយ្យជាតិ និងលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស។

- ប្រជាពលរដ្ឋទាំងពីរភេទត្រូវគោរពទ្រព្យសម្បត្តិសាធារណៈ និងកម្មសិទ្ធិស្របច្បាប់របស់ឯកជន។

<u>មាត្រា១៨</u>៖ ច្បាប់ និងលិខិតបទដ្ឋានទាំងអស់នៅកម្ពុជា ដែលធានាការពារបាននូវទ្រព្យសម្បត្តិរដ្ឋ សិទ្ធិសេរីភាព និងទ្រព្យសម្បត្តិត្រឹមត្រូវតាមច្បាប់របស់បុគ្គល និងដែលសមស្របនឹង

Draft

ប្រយោជន៍ជាតិ ត្រូវមានអានុភាពអនុវត្តបន្តទៅមុខទៀតរហូតដល់មានអត្ថបទថ្មីមកកែប្រែ ឬលុបចោលលើកលែងតែបទប្បញ្ញត្តិណាដែលផ្ទុយនឹងស្មារតីនៃរដ្ឋធម្មនុញ្ញនេះ។

៣.២ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ (ឆ្នាំ១៩៩៦)

ច្បាប់ស្តីអំពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិត្រូវបានអនុម័តដោយរដ្ឋសភាជាតិ ហើយត្រូវបានប្រកាសឲ្យប្រើប្រាស់ដោយព្រះរាជក្រមលេខ នស,រកម១២៩៦,៣៦ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ច្បាប់នេះមានគោលដៅ៖

- ការពារលើកកម្ពស់គុណភាពបរិស្ថាន និងសុខភាពពលរដ្ឋដោយធ្វើការទប់ស្កាត់ កាត់បន្ថយ និងការត្រួតពិនិត្យការបំពុល។
- វាយតំលៃហេតុប៉ះពាល់បរិស្ថាន មុននឹងចេញនូវសេចក្តីសំរេចរបស់រាជរដ្ឋាភិបាលចំពោះរាល់គម្រោងដែលបានស្នើឡើង។
- ធានាឲ្យមានការអភិរក្សការអភិវឌ្ឍន៍ការគ្រប់គ្រង និងការប្រើប្រាស់ដោយសមហេតុផល និងប្រកបដោយនិរន្តរភាពនិងភាពស្ថិតស្ថេរនូវធនធានធម្មជាតិនៃព្រះរាជាណាចក្រកម្ពុជា
- លើកទឹកចិត្តនិងផ្តល់លទ្ធភាពឲ្យសាធារណៈជន ចូលរួមក្នុងកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ។
- បង្ក្រាបរាល់អំពើទាំងឡាយដែលធ្វើឲ្យប៉ះពាល់ដល់បរិស្ថាន។

ទាក់ទងនឹងការគ្រប់គ្រងធនធានធម្មជាតិ ច្បាប់នេះបានតំរូវឲ្យបណ្តាក្រុមហ៊ុនទាំងអស់ត្រូវរៀបចំរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង(IEIA) ឬរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ (EIA)។ ផ្អែកលើច្បាប់នេះបានចែងនៅក្នុងមាត្រាទី៦និង៧នៃជំពូកទី ៣ ដែលមានខ្លឹមសារដូចខាងក្រោម៖

<u>មាត្រា៦</u>៖ ការវាយតំលៃហេតុប៉ះពាល់បរិស្ថានត្រូវអនុវត្តលើគម្រោង និងសកម្មភាពរបស់ឯកជនឬសាធារណៈ:ហើយត្រូវបានត្រួតពិនិត្យ និងវាយតំលៃដោយក្រសួងបរិស្ថានមុននឹងដាក់ជូនរាជរដ្ឋាភិបាលសំរេច។ ការវាយតំលៃនេះត្រូវអនុវត្តផងដែរចំពោះសកម្មភាពដែលមានស្រាប់និងកំពុងដំណើរការហើយ ដែលពុំទាន់បានវាយតំលៃហេតុប៉ះពាល់បរិស្ថាននៅឡើយ។ ប្រភេទទំហំគម្រោងនិងសកម្មភាពដែលបានស្នើឡើងព្រមទាំងសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការទាំងឯកជននិងសាធារណៈ:ដែលត្រូវការវាយតំលៃហេតុប៉ះពាល់បរិស្ថាននេះត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងបរិស្ថាន។

<u>មាត្រា៧</u>៖ ចំពោះពាក្យស្នើសុំធ្វើគម្រោងវិនិយោគ និងរាល់គម្រោងដែលរដ្ឋស្នើឡើងត្រូវមានការវាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង (IEIA) ការវាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ (EIA)ដូចមានចែងក្នុងមាត្រា៦នៃច្បាប់នេះ។ ក្រសួងបរិស្ថានត្រូវត្រួតពិនិត្យ និងផ្តល់

យោបល់លើ IEIA ឬ EIA ទៅអង្គភាពមានសមត្ថកិច្ចក្នុងរយៈពេលដូចបានកំណត់ក្នុងច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

៣.៣ ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ (១៩៩៤)

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាអនុម័តនៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ ១៩៩៤ នាសម័យប្រជុំរដ្ឋសភា លើកទី២ នីតិកាលទី១ ដែលមានសេចក្តីសំខាន់ៗដូចខាងក្រោម៖

<u>មាត្រា១</u>៖ ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ មានកម្មវត្ថុជំរុញឲ្យមានការរៀបចំកែលម្អរទីក្រុង និងតំបន់ជនបទនៃព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងធានាកិច្ចអភិវឌ្ឍន៍សុខដុមនៃប្រទេសក្នុងស្មារតី៖

- គោរពប្រយោជន៍រួម និងប្រយោជន៍បុគ្គលផង គោរពសិទ្ធិឯកជនផង គោរពបទបញ្ជាច្បាប់ផង និងត្រួតពិនិត្យការសាងសង់ផង។
- ធានាការអភិវឌ្ឍន៍សំដៅរកលំនឹងរវាងទីក្រុង និងតំបន់ជនបទ ផ្អែកទៅលើភូមិសាស្ត្រ និងលក្ខណៈពិសេសនៃជនបទនីមួយៗ។
- ធានាលើតំលៃសម្បត្តិធម្មជាតិ សម្បត្តិវប្បធម៌ និងធានាការអភិវឌ្ឍន៍វិស័យសេដ្ឋកិច្ច វិស័យទេសចរណ៍ និងរក្សាបាននូវគុណភាពបរិស្ថាន។

<u>មាត្រា៤</u>៖ ឯកសារទាំងឡាយដែលទាក់ទងនឹងការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ត្រូវរៀបចំតាមករណីនីមួយៗឲ្យសមស្របទៅតាមស្ថានភាពលក្ខណៈពិសេសនៃទឹកដីខេត្ត-ក្រុង តំបន់ក្នុងស្មារតីការពារដល់បេតិកភណ្ឌ ដល់បរិស្ថានការពារធនធានធម្មជាតិ ព្រមទាំងធានាដល់ការអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ច។

<u>មាត្រា៥</u>៖ គណៈកម្មាធិការរៀបចំដែនដី នគរូបនីយកម្ម និងសំណង់រាជធានីភ្នំពេញ ឬអនុគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម សំណង់ខេត្ត-ក្រុងនីមួយៗ ត្រូវគូសប្លង់គោលដើម្បី រៀបចំ និងអភិវឌ្ឍន៍រាជធានី ខេត្ត-ក្រុងរបស់ខ្លួន។ ប្លង់គោលនេះត្រូវមានការយល់ព្រមពីគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ នឹងកំណត់ដោយអនុក្រឹត្យ។ ដើម្បីការពារនូវបេតិកភ័ណ្ឌការពារបរិស្ថាន និងដើម្បីធានាអភិវឌ្ឍសេដ្ឋកិច្ចចំពោះតំបន់ពិសេសណាមួយ ដែលគណៈរដ្ឋមន្ត្រីបានកំណត់គណៈកម្មាធិការជាតិរៀបចំ ទឹកដី នគរូបនីយកម្ម និងសំណង់ មានការកិច្ចរៀបចំប្លង់គោល សម្រាប់តំបន់ពិសេសនោះ ដាក់ជូនគណៈរដ្ឋមន្ត្រីអនុម័ត។

<u>មាត្រា៦</u>៖ ប្លង់ប្រើប្រាស់ដីធ្លីនិងសំណង់ ត្រូវរៀបចំឡើងសម្រាប់រាជធានី ខេត្ត ក្រុង។ ប្លង់នេះត្រូវមានការគោរពពីសំណាក់ឯកជន ក៏ដូចជាអាជ្ញាធរសាធារណៈក្នុងកិច្ចការសាងសង់របស់ខ្លួន។

<u>មាត្រា៧</u>៖ ប្លង់ប្រើប្រាស់ដីធ្លី និងសំណង់ត្រូវតែបញ្ជាក់ឲ្យច្បាស់លាស់ អំពីតំបន់ដែលត្រូវប្រើប្រាស់សម្រាប់ការពារជាតិ សម្រាប់កសិកម្ម សម្រាប់ពាណិជ្ជកម្ម សម្រាប់ឧស្សាហកម្មសម្រាប់សិប្បកម្ម សម្រាប់រៀបចំ សម្រាប់ទេសចរណ៍ សម្រាប់សាសនា ព្រមទាំងសម្រាប់សំណង់នៃរដ្ឋបាល និងបរិក្ខារសាធារណៈ។ ប្លង់នេះកំណត់ផងដែរនូវលទ្ធភាព សម្រាប់សាងសង់។

<u>មាត្រា៨</u>៖ ប្លង់ប្រើប្រាស់ដីធ្លី និងសំណង់ត្រូវគោរពតាមប្លង់គោល ដែលមានចែងក្នុងមាត្រា ៥ នៃច្បាប់នេះ។

<u>មាត្រា៩</u>៖ ប្លង់ប្រើប្រាស់ដីធ្លី និងសំណង់សម្រាប់រាជធានី និងខេត្ត ក្រុងនីមួយៗត្រូវមានការទទួលយល់ព្រមពីគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ខេត្ត ក្រុងរួចត្រូវមានការយល់ព្រមពីគណៈកម្មាធិកាជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ទៀត។ ប្លង់ទាំងអស់ត្រូវមានការទទួលគោរពពីឯកជន ក៏ដូចជាអាជ្ញាធរសាធារណៈទាំងពួងផង។

<u>មាត្រា១០</u>៖ រាល់ការកកាយរុករក ឬការស្វង់ដែលមានការប៉ះពាល់ដល់ខាងផ្នែកបុរាណវិទ្យាចាំបាច់ត្រូវការអនុញ្ញាតពីរាជរដ្ឋាភិបាល។ រាល់ការសាងសង់ ក្នុងករណីជួបប្រទះនូវវត្ថុអ្វីមួយដែលមានអត្ថប្រយោជន៍ខាងផ្នែកបុរាណវិទ្យា ឬប្រវត្តិសាស្ត្រ អ្នកទទួលខុសត្រូវការដ្ឋានត្រូវមានកាតព្វកិច្ចរាយការណ៍មកអាជ្ញាធរមានសមត្ថកិច្ចឲ្យបានជ្រាបភ្លាមៗ។ អាជ្ញាធរមានសមត្ថកិច្ចត្រូវបញ្ឈប់សំណង់ជាបន្ទាន់។

<u>មាត្រា១២</u>៖ រាល់បុគ្គល ឬស្ថាប័នឯកជនក៏ដូចជាអាជ្ញាធរសាធារណៈ ត្រូវហាមឃាត់មិនឲ្យសាងសង់លើទីធ្លា ដែលមានលក្ខណៈជាសាធារណៈដូចតទៅ៖

- ទីបំរុងទុកទឹក និងទំនប់ទឹក
- ទីបំរុងជីកដី និងតំបន់ព្រៃឈើ
- រមណីយដ្ឋានបុរាណវិទ្យា និងប្រវត្តិសាស្ត្រ
- សួនច្បារ ឧទ្យានសាធារណៈ និងតំបន់អភិវឌ្ឍន៍
- ដីបំរុងទុកសម្រាប់ផ្លូវ បំរុងសម្រាប់ចំណីផ្លូវ និងដីបំរុងទុកសម្រាប់ផ្លូវរថភ្លើង និងអាកាសយានដ្ឋាន
- ទន្លេ សមុទ្រ ព្រែក ស្ទឹង ព្រមទាំងឆ្នេរច្រាំង
- ជាទូទៅនៅលើដីទាំងឡាយណាដែលបញ្ញត្តិច្បាប់កំណត់មិនឲ្យសង់។

លក្ខខណ្ឌនៃការគ្រប់គ្រងតំបន់ទាំងនោះ លក្ខខ័ណ្ឌសំណង់ទីតាំងលំនៅធុនស្រាលបណ្តោះអាសន្នអនុញ្ញាតបានដោយអនុក្រឹត្យ។

<u>មាត្រា១៣</u>៖ ការងារសាងសង់ និងការតាំងទីត្រូវធ្វើឡើងដោយគោរពតាមឯកសារ ដែលទាក់ទង និងការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ គោរពតាមប្លង់គោល ដែលមានចែងក្នុងមាត្រា ៤ និង ៥ នៃច្បាប់នេះ។

<u>មាត្រា១៦</u>៖ ពាក្យសុំអនុញ្ញាតសាងសង់ ត្រូវយកមកដាក់សុំដោយម្ចាស់កម្មសិទ្ធិដី ឬអ្នកទទួលសិទ្ធិពីម្ចាស់កម្មសិទ្ធិ។ ពាក្យសុំអនុញ្ញាតនេះត្រូវមានភ្ជាប់មកជាមួយផង នូវឯកសារបញ្ជាក់ពីកម្មសិទ្ធិរបស់ម្ចាស់ដី។

<u>មាត្រា១៧</u>៖ មិនអនុញ្ញាតឲ្យសាងសង់នូវសំណង់ ក្នុងលក្ខណៈដែលមិនសមស្របនឹងប្លង់គោល ឬប្លង់ប្រើប្រាស់ដីធ្លី និងសំណង់។ មិនអនុញ្ញាតឲ្យសាងសង់ បើគម្រោងសាងសង់នោះមានការប៉ះពាល់ដល់សន្តិសុខសាធារណៈ ប៉ះពាល់ដល់បរិស្ថាន ប៉ះពាល់ដល់អនាម័យសាធារណៈសំណង់ ឬអចលនវត្ថុដែលមានសារប្រយោជន៍ដល់ផ្នែកបុរាណវិទ្យា ប្រវត្តិ-សាស្ត្រ វប្បធម៌ សោភណ្ឌភាព បច្ចេកទេស ឬប៉ះពាល់ដល់តំបន់ដែលមានធនធានធម្មជាតិ។ មិនអនុញ្ញាតឲ្យ សាងសង់ បើសិនជាពុំមានការរៀបចំឲ្យមានហេដ្ឋារចនាសម្ព័ន្ធ ឬបរិក្ខារសាធារណៈឲ្យបានគ្រប់គ្រាន់ និងគម្រោងសំណង់ដែលស្នើរសុំ។

<u>មាត្រា១៨</u>៖ ក្នុងករណីពុំទាន់មានប្លង់ប្រើប្រាស់ដីធ្លី និងសំណង់ អាជ្ញាធរខេត្ត ក្រុង ត្រូវបង្កើតគណៈកម្មាធិការ ដើម្បីពិនិត្យពាក្យសុំ និងចេញលិខិតអនុញ្ញាតសាងសង់។

<u>មាត្រា២០</u>៖ សំណង់ទាំងឡាយណា ដែលអ្នកវិនិយោគទុនឯកជន បានសាងសង់នៅលើដីរបស់រដ្ឋស្របតាមកិច្ចសន្យាណាមួយ ត្រូវប្រគល់មកឲ្យរដ្ឋវិញពេលផុតកំណត់ចែងក្នុងកិច្ចសន្យានោះ។

៣.៤ ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា (២០០៧)

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាអនុម័តនៅថ្ងៃទី២២ ខែឧសភា ឆ្នាំ ២០០៧ នាសម័យប្រជុំរដ្ឋភាលើកទី ៦ នីតិកាលទី ៣ ដែលមានមាត្រាសំខាន់ៗដូចខាងក្រោម៖

<u>មាត្រា១</u>៖ ច្បាប់នេះមានគោលដៅជុំវិញ ឱ្យមានការគ្រប់គ្រងធនធានទឹកប្រកបដោយប្រសិទ្ធិភាព និងនិរន្តរភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីសំរេចបាននូវការងារអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ។ ច្បាប់នេះកំណត់អំពី:

- សិទ្ធិ និងកាតព្វកិច្ចនៃអ្នកប្រើប្រាស់ទឹក
- គោលការណ៍គ្រឹះសំខាន់ៗ សម្រាប់ការគ្រប់គ្រងធនធានទឹក
- ការចូលរួមរបស់សហគមន៍អ្នកប្រើប្រាស់ទឹក ក្នុងការអភិវឌ្ឍន៍ធនធានទឹកប្រកបដោយ

Draft

និរន្តរភាព។

<u>មាត្រា២</u>៖ ក្នុងច្បាប់នេះ ពាក្យបច្ចេកទេសមួយចំនួនមានន័យថា៖

- ទឹក គឺទឹកលើដី ទឹកក្រោមដី និងទឹកក្នុងអាកាស។
- ធនធានទឹកគឺទឹកសមុទ្រ ទន្លេ ស្ទឹង ព្រែក ជ្រោះ ជ្រលងដងអូរ បឹងបួ ត្រពាំង ថ្លុក។
- ទឹកក្រោមដី គឺទឹកដែលហូរនៅក្រោមដីក្នុងចន្លោះថ្មគ្ងួចធំ និងភាគល្អិតនៃដីដែលផ្លាស់ទីពីកន្លែង មួយទៅកន្លែងមួយទៀត។
- ណ្ណាងទឹកក្រោមដី គឺទឹកក្រោមដីដែលស្ថិតនៅជាអចិន្ត្រៃយ៍ក្នុងណ្ណាងធម្មជាតិក្រោមដី។
- អាងទន្លេ គឺតំបន់ភូមិសាស្ត្រដែលកំណត់ដោយព្រំប្រទល់ទីជម្រាលនៃប្រព័ន្ធទឹកហូរ ដោយរាប់បញ្ចូលទាំងទឹកលើដី និងទឹកក្រោមដី។
- អាងទន្លេរង គឺផ្នែកមួយនៃអាងទន្លេ។
- ទន្លេអន្តរជាតិ គឺទន្លេដែលមានភូមិសាស្ត្រពាក់ព័ន្ធដល់ទឹកដីប្រទេសចាប់ពីពីរឡើងទៅ
- ច្រាំងទន្លេ ស្ទឹង ព្រែក អូរ ប្រឡាយ បឹងបួ និងអាងទឹក គឺចំណែកដីដែលធម្មតាលិចដោយទឹក នៅក្នុងទន្លេ ស្ទឹង ព្រែក អូរ បឹងបួ និងអាងទឹក ដោយរាប់បញ្ចូលទាំងដី ថ្ម ឬអង្គធាតុដទៃទៀត ដែលនៅឆ្ងាយពីច្រាំង និងលិចទឹកម្តងម្កាលនោះ។
- ឆ្នេរសមុទ្រ ទន្លេ ស្ទឹង គឺចំណែកដី ឬខ្សាច់ដែលមានសណ្ឋានជម្រាល និងលិចទឹកម្តងម្កាល។
- បាតទន្លេ ស្ទឹង ព្រែក អូរ ប្រឡាយ បឹងបួ និងអាងទឹក គឺផ្នែកមួយនៃដីដែលកំណត់ដោយច្រាំងទន្លេ ស្ទឹង ព្រែក អូរ ប្រឡាយ បឹងបួ និងអាងទឹកដែលគ្របដណ្តប់ដោយទឹក។
- តម្រូវការសាធារណៈ គឺការផ្គត់ផ្គង់ទឹកនៅតាមទីក្រុង និងជនបទ ការផលិតស្បៀង ការផលិតថាមពលវារីអគ្គីសនី ការបំពេញវិស័យកសិកម្ម វិស័យឧស្សាហកម្ម វិស័យនាវាចរ និងការរក្សាឲ្យមានធារាទឹកអប្បរមា ដើម្បីថែរក្សាបរិស្ថាន ជីវិតមនុស្ស ជីវិតមច្ឆាជាតិ និងរុក្ខជាតិនានា។
- ការងារទឹក គឺសំណង់ទំនប់ធំ គ្ងួច ទំនប់បង្ខៀរ ទំនប់បញ្ជាល់ទឹក ទំនប់ទឹកការពារទឹកជំនន់ ប្រឡាយដោះទឹកធំ គ្ងួច ប្រព័ន្ធស្រោចស្រព អាងទឹកគ្ងួចធំ ប្រឡាយនាំទឹក អណ្ណាងទឹកគ្រប់ប្រភេទ ទំនប់វារីអគ្គីសនី និងសំណង់ដទៃទៀត ដែលបានសាងសង់ក្នុងគោលបំណងបង្វែរទឹក រក្សាទឹកទុក នាំទឹកយកទៅប្រើប្រាស់ អភិរក្សការពារធនធានទឹក ដោះទឹកចេញពីតំបន់ដីលិចទឹកការពារកាត់បន្ថយនូវឥទ្ធិពលទឹកជំនន់ និងសង្គ្រោះបន្ទាន់ផ្សេងៗទៀតដែលពាក់ព័ន្ធនឹងទឹក។
- អាជ្ញាប័ណ្ណទឹក គឺប័ណ្ណដែលផ្តល់សិទ្ធិប្រើប្រាស់ទឹក និងធនធានទឹកឲ្យបុគ្គលគ្រប់រូប ដើម្បីធ្វើអាជីវកម្ម និងអភិវឌ្ឍន៍។

Draft

– បុគ្គល គឺរួបវន្តបុគ្គល ឬនីតិបុគ្គលទោះក្នុងន័យជាឯកជន ឬសាធារណៈក៏ដោយ។

<u>មាត្រា៣</u>៖ ទឹក និងធនធានទឹក ជាសម្បត្តិរបស់រដ្ឋ។

<u>មាត្រា១១</u>៖ បុគ្គលគ្រប់រូបមានសិទ្ធិប្រើប្រាស់ធនធានទឹកក្នុងបរិមាណមួយ មិនលើសពីសេចក្តីត្រូវការចាំបាច់ជាមូលដ្ឋានសម្រាប់ការហូបចុក បោកគក់ ងូត និងតម្រូវការផ្សេងៗ រួមមានការចិញ្ចឹមសត្ត ការចិញ្ចឹមត្រី ការស្រោចស្រពសួនច្បារ និងដំណាំ ដោយជៀសវាងមិនឲ្យមានការប៉ះពាល់ដល់សិទ្ធិស្របច្បាប់របស់អ្នកដទៃ។ តម្រូវការខាងលើនេះ មិនតម្រូវឲ្យសុំអាជ្ញាប័ណ្ណឡើយ។

<u>មាត្រា១២</u>៖ ការបង្វែរទឹក ការយកទឹក ការប្រើប្រាស់ធនធានទឹក ក្នុងគោលបំណងកសិកម្ម ឬឧស្សាហកម្មលើសពីកំរិតដែលមានចែងក្នុងមាត្រា១១ និងសំណង់ការងារទឹកដែលពាក់ព័ន្ធ តម្រូវឲ្យមានការសុំជាអាជ្ញាប័ណ្ណទឹក ឬលិខិតអនុញ្ញាត។ បែបបទនៃការសុំនេះ មិនមានចែងក្នុងអនុក្រឹត្យ។ ការយកខ្សាច់ដី ឬគ្រួសប្រេងកាត និងឧស្ម័នពីបាត ច្រាំង ឆ្នេរសមុទ្រ ឆ្នេរទន្លេ ស្ទឹង ព្រែក អូរ បឹងបួតម្រូវឲ្យមានការសុំអាជ្ញាប័ណ្ណទឹក។ បែបបទបច្ចេកទេសជលសាស្ត្រដែលពាក់ព័ន្ធនឹងការងារនេះ នឹងមានចែងលំអិតនៅក្នុងអនុក្រឹត្យ។ ការលប់ទន្លេ ស្ទឹង ព្រែក អូរ ប្រឡាយ បឹងបួ អាងទឹក និងអាងធម្មជាតិតម្រូវឲ្យមានការសុំអាជ្ញាប័ណ្ណទឹក ឬលិខិតអនុញ្ញាត។ បែបបទនៃការសុំនេះនឹងមានចែងនៅក្នុងអនុក្រឹត្យ។ ការសាងសង់ស្ពានតូចធំ កាត់ទន្លេ ស្ទឹង កំពង់ជ្រៃ ឬសំណង់អាគារតូចធំ លើច្រាំង និងឆ្នេរទន្លេតម្រូវឲ្យមានការឯកភាពផ្នែកបច្ចេកទេសជាមុនពីក្រសួងធនធានទឹក និងឧតុនិយម។ ការបង្វែរទឹកពីប្រភពដើមចេញពីទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវមានការអនុញ្ញាត និងយល់ព្រមពីរាជរដ្ឋាភិបាលកម្ពុជាដោយមានការអនុម័តយល់ព្រមពីស្ថាប័ននីតិបញ្ញត្តិ។

<u>មាត្រា១៤</u>៖ មុនពេលផ្តល់អាជ្ញាប័ណ្ណទឹកដល់បុគ្គលណាមួយ ក្រសួងធនធានទឹក និងឧតុនិយម ត្រូវពិគ្រោះយោបល់ជាមួយស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋានលើការប្រើប្រាស់ទឹក និងការសាងសង់ សំណង់ការងារទឹកដែលបុគ្គលនោះស្នើឡើង។

<u>មាត្រា២២</u>៖ រាល់ការបញ្ចេញចោល ការទុកចោល ឬការរក្សាទុកនូវសារធាតុពុលដែលអាចធ្វើឱ្យប៉ះពាល់ដល់គុណភាពទឹក និងអាចបង្កគ្រោះថ្នាក់ដល់មនុស្ស សត្ត និងរុក្ខជាតិ ត្រូវតែសុំអាជ្ញាប័ណ្ណទឹក ឬការអនុញ្ញាត។ ប្រភេទសារធាតុពុលដែលមានចែងខាងលើ និងស្តង់ដារបច្ចេកទេសនៃការបញ្ចេញទឹក សំណល់នឹងមានកំណត់ដោយអនុក្រឹត្យ។ រាល់កិច្ចដំណើរការក្នុងមាត្រានេះ ក្រសួងធនធានទឹក និងឧតុនិយម ត្រូវពិគ្រោះយោបល់ជាមួយក្រសួងពាក់ព័ន្ធនានា។

<u>មាត្រា២៣</u>៖ ក្រសួងធនធានទឹក និងឧតុនិមយ អាចប្រកាសទុកជាតំបន់អាសន្ន ឬជាតំបន់ហាមឃាត់ការប្រើប្រាស់ទឹកក្នុងករណីដែល:

- ទឹកលើដី ឬទឹកក្រោមដីត្រូវបានប៉ះពាល់ផ្នែកបរិមាណ គុណភាព ឬតុល្យភាពអេកូឡូស៊ី។
- ទឹកលើទីជំរាលដែលកំពុងរងការគំរាមគំហែងដោយសកម្មភាពមនុស្ស ឬធម្មជាតិ។
- ទឹកដែលបណ្តាលឲ្យប៉ះពាល់ដល់សុខភាពប្រជាពលរដ្ឋ។

ដែនភូមិសាស្ត្រនៃតំបន់អាសន្ន ឬតំបន់ហាមឃាត់នោះ ត្រូវកំណត់តាមករណីនីមួយៗ ដោយប្រកាសរបស់ក្រសួងធនធានទឹក និងឧតុនិយម។

<u>មាត្រា២៣</u>៖ រាល់វិវាទដែលពាក់ព័ន្ធនឹងការបង្កើត និងដំណើការសេវា ក្នុងការប្រើប្រាស់ទឹកត្រូវសម្រួលដោះស្រាយដោយក្រសួងធនធានទឹក និងឧតុនិយម ក្រសួងពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន។

៣.៥ ច្បាប់ស្តីពីជលផល (២០០៦)

ច្បាប់ស្តីពីជលផលត្រូវបានអនុម័តដាក់ឱ្យប្រើប្រាស់ចាប់ពីថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦។ ច្បាប់នេះមានឥទ្ធិពលលើការគ្រប់គ្រង អភិរក្ស និងប្រើប្រាស់ធនធានជលផលឱ្យមាននិរន្តរភាព។ ក្នុងច្បាប់ស្តីពីជលផល មានមាត្រាមួយចំនួនពាក់ព័ន្ធទៅនឹងការគ្រប់គ្រងធនធានជលផលសមុទ្រ ដូចជា៖

<u>ប្រការ១</u>៖ បានចែងថា "ច្បាប់នេះមានគោលបំណងធានានូវការគ្រប់គ្រងជលផល និងធនធានជលផល ជំរុញកិច្ចអភិវឌ្ឍន៍វារីវប្បកម្មជលិតកម្ម និងការកែច្នៃលើកស្ទួយជីវភាពរស់នៅរបស់ពលរដ្ឋក្នុងសហគមន៍មូលដ្ឋាន ដើម្បីជលប្រយោជន៍សង្គម សេដ្ឋកិច្ច និងបរិស្ថាន រួមទាំងការអភិរក្សជីវចម្រុះផង ទាំងមរតកវប្បធម៌ធម្មជាតិផង ប្រកបដោយនិរន្តរភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា។"

<u>ប្រការ៣</u>៖ បានចែងថា "ការគ្រប់គ្រងជលផល ត្រូវស្ថិតនៅក្រោមដែនសមត្ថកិច្ចទូទៅ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ការគ្រប់គ្រង ព្រៃលិចទឹក និងព្រៃកោងកាងដែលពាក់ព័ន្ធនឹងវដ្តជីវិតធនធានជលផលត្រូវស្ថិតនៅក្រោមវិសាលភាពនៃច្បាប់នេះ។

រដ្ឋផ្តល់សិទ្ធិគ្រប់គ្រងតំបន់ការពារធម្មជាតិដល់ក្រសួងបរិស្ថាន ក្រោមបទបញ្ញត្តិទាំងឡាយនៃច្បាប់ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ និងច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ និងលិខិតបទដ្ឋានគតិយុត្តិផ្សេងៗទៀត។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសិទ្ធិសហការធ្វើសកម្មភាពពង្រឹកការអនុវត្តច្បាប់ ចំពោះរាល់បទល្មើសជលផលដែលកើតមានចែងក្នុងជំពូកទី១៤នៃច្បាប់នេះ។ សកម្មភាពនេសាទនេះ នឹងមិនធ្វើឲ្យប៉ះពាល់ដល់ដែនសមត្ថកិច្ចគ្រប់គ្រងរបស់ក្រសួងបរិស្ថាន ដូចមានចែងក្នុងច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិឡើយ"។

<u>មាត្រា៤៖</u> ធនធានជលផលមានសរីរាង្គទឹកសាប និងសមុទ្រ ជាសត្វ និងរុក្ខជាតិ មានជីវិតឬគ្មានជីវិត ជាអាទ៍ មច្ឆាជាតិ សិប្បីសត្វ ថលជលិកសត្វ បាណកសត្វ ឧរង្គសត្វ ថនិកសត្វ សត្វ ឥតឆ្អឹងកងផ្សេងទៀតដែលបង្កកំណើតនៅក្នុងទឹក ប្លង់តុង សារ៉ាយ ស្មៅសមុទ្រ ផ្កាថ្ម ព្រៃលិចទឹក ព្រមទាំងព្រៃកោងកាងជាដើម។

<u>មាត្រា៦៖</u> រដ្ឋបាលជលផល គឺជាអាជ្ញាធររដ្ឋាភិបាលដែលចំណុះក្រោមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានភារកិច្ចគ្រប់គ្រងជលផល និងធនធានជលផល ស្របតាមគោលនយោបាយវិស័យជលផលជាតិ និងខ្លឹមសារនៃច្បាប់នេះ។

<u>ប្រការ២២៖</u> បានចែងថា "ហាមឃាត់ ការចាក់ចោល ការបោះចោល ការបង្ហូរ ឬការបាចពង្រាយទៅក្នុងដែននេសាទនូវកាកសំណល់រឹង ឬរាវ ឬសារធាតុពុលដែលបានកំណត់ដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិនៃព្រះរាជាណាចក្រកម្ពុជា និងអនុសញ្ញា ឬសន្ធិសញ្ញាអន្តរជាតិ ស្តីពីការបំពុលបរិស្ថាន ឬការប្រព្រឹត្តិសកម្មភាពដែលធ្វើឲ្យពុល ឬការបង្កគ្រោះថ្នាក់ដល់វារីសត្វ និងវារីរុក្ខជាតិ។"

<u>មាត្រា៩៦៖</u> ត្រូវទទួលពិន័យអន្តរការណ៍ពីរដ្ឋបាលជលផលជាប្រាក់ពីប្រាំលាន (៥.000.000) រៀល ទៅដប់លាន(១0.000.000)រៀល ឯវត្ថុតាងទាំងអស់ត្រូវប្រគល់ឱ្យសាមីជនវិញ ចំពោះជនណាដែលបានប្រព្រឹត្តបទល្មើសណាមួយដូចខាងក្រោម ៖

៤- គាស់កកាយយកថ្ម ដី ខ្សាច់ រ៉ែ ដែលមាននៅក្នុងដែននេសាទដោយគ្មានការអនុញ្ញាត។ ជនណាប្រព្រឹត្តបទល្មើស ដូចមានចែងក្នុងមាត្រានេះចាប់ពីពីរ(២)ដងឡើងទៅត្រូវទទួលការពិន័យអន្តរការណ៍ពីរដ្ឋបាលជលផលទ្វេដង នៃប្រាក់ដែលត្រូវពិន័យអន្តរការណ៍ក្នុងមាត្រានេះ។

<u>មាត្រា៩៨៖</u> ត្រូវផ្តន្ទាទោសក្រោមបទល្មើសជលផលថ្នាក់ទី១ ដែលត្រូវដាក់ពន្ធនាគារពីបី (៣) ឆ្នាំទៅប្រាំ (៥)ឆ្នាំ និងវត្ថុតាងទាំងអស់ត្រូវរឹបអូសជាសម្បត្តិរដ្ឋ ឬបំផ្លាញចោល និងដកហូតកិច្ចព្រមព្រៀង ឬលិខិតអនុញ្ញាត ចំពោះជនណាដែលបានប្រព្រឹត្តបទល្មើសណាមួយដូចខាងក្រោម ៖

១-កាប់ឆ្ការគាស់រាន ឈូសឆាយព្រៃលិចទឹក និងព្រៃកោងកាង ឬហ៊ុមព័ទ្ធកាន់កាប់ព្រៃលិចទឹក និងព្រៃកោងកាង។

៣- ចាក់ចោល បោះចោល បង្ហូរ បាចពង្រាយសារធាតុពុល ឬប្រព្រឹត្តសកម្មភាពធ្វើឱ្យពុល ឬបង្កគ្រោះថ្នាក់ដល់វារីសត្វ និងវារីរុក្ខជាតិនៅក្នុងដែននេសាទ។

១0- បំផ្លាញស្មៅសមុទ្រ ឬផ្កាថ្ម នឹងធ្វើឱ្យអន្តរាយដល់អេកូឡូស៊ីស្មៅសមុទ្រ ឬផ្កាថ្ម។

Draft

ជនណាប្រព្រឹត្តបទល្មើសជលផលថ្នាក់ទី១ចាប់ពីពីរ(២)ដងឡើងទៅ ត្រូវផ្តន្ទាទោសទ្វេដងនៃបទល្មើសជលផលថ្នាក់ទី១ នៃមាត្រានេះ។

អនុលោមតាមបណ្តាច្បាប់ និងលិខិតបទដ្ឋានទាំងអស់នេះ ការអភិវឌ្ឍផ្សេងៗនៅតាមបណ្តោយព្រៃកនេះ ត្រូវគិតគូរទៅលើការថែរក្សាឱ្យបាននូវប្រភេទធនធានជលផលសមុទ្រ ជាពិសេស ផ្កាថ្ម ស្មៅសមុទ្រ ព្រៃកោងកាង ប្រភេទធនធានជលផលកំពុងរងគ្រោះថ្នាក់ និងប្រពន្ធ័អេកូឡូស៊ី។

៣.៦ ច្បាប់ភូមិបាល (ឆ្នាំ២០០១)

ច្បាប់ភូមិបាល ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២០ ខែកក្កដា ឆ្នាំ២០០១ នាសម័យប្រជុំពេញអង្គលើកទី៦ នីតិកាលទី២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី១៣ ខែសីហា ឆ្នាំ២០០១ នាសម័យប្រជុំពេញអង្គលើកទី៥ នីតិកាលទី១។ ច្បាប់នេះប្រកាសឲ្យប្រើប្រាស់តាមរយៈព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែសីហា ឆ្នាំ២០០១ ហើយដែលមានសេចក្តីសំខាន់ៗដូចតទៅ:

<u>មាត្រា១</u>៖ ច្បាប់នេះមានគោលដៅកំណត់អំពីរបបកម្មសិទ្ធិលើអចលនវត្ថុទាំងឡាយ នៅព្រះរាជាណាចក្រកម្ពុជាក្នុងគោលបំណងធានាការពារសិទ្ធិនៃកម្មសិទ្ធិ និងសិទ្ធិផ្សេងៗទៀតលើអចលនវត្ថុស្របតាមបទបញ្ញត្តិនៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣នៃព្រះរាជាណាចក្រកម្ពុជា។

<u>មាត្រា៣</u>៖ ជនគ្រប់រូបត្រូវគោរពទ្រព្យសម្បត្តិរបស់រដ្ឋ និងកម្មសិទ្ធិឯកជន ស្របច្បាប់លើអចលនវត្ថុ។ ការគ្រប់គ្រងផ្នែករដ្ឋបាលសុរិយោដីលើអចលនវត្ថុ ដែលជាទ្រព្យសម្បត្តិរបស់រដ្ឋ និងការចេញប័ណ្ណកម្មសិទ្ធិលើអចលនវត្ថុទូទាំងព្រះរាជាណាចក្រកម្ពុជា ជាសមត្ថកិច្ចរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ បទបញ្ជា និងនីតិវិធីនៃការគ្រប់គ្រងអចលនវត្ថុដែលជាទ្រព្យសម្បត្តិរបស់រដ្ឋនឹងត្រូវកំណត់ដោយអនុក្រឹត្យ។

<u>មាត្រា៨</u>៖ មានតែរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិជាខ្មែរទេ ទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីនៃព្រះរាជាណាចក្រកម្ពុជា។ អ្នកមានឧបនិស្ស័យជាកម្មសិទ្ធិលើដីនៅកម្ពុជាគឺពលរដ្ឋខ្មែរទាំងអស់សមូហភាពដែនដីសាធារណៈ គ្រឹះដ្ឋានសាធារណៈ សហគមន៍ ឬសមាគមកម្ពុជា សហគ្រាសសាធារណៈ និងក្រុមហ៊ុនស៊ីវិល ឬពាណិជ្ជកម្មកម្ពុជា និងគ្រប់អង្គការកម្ពុជា ដែលបានទទួលស្គាល់ដោយច្បាប់ថាជានីតិបុគ្គល។ ជនបរទេសដែលបានក្លែងបន្លំប័ណ្ណសញ្ជាតិដើម្បីឲ្យក្លាយជាកម្មសិទ្ធិករលើដីនៅកម្ពុជានឹងត្រូវផ្តន្ទាទោសដូចចែងក្នុងមាត្រា២៥១ នៃច្បាប់នេះ។ ទ្រព្យដែលបានមកក្នុងលក្ខខណ្ឌនេះត្រូវរឹបអូសយកទុកជាសម្បត្តិរដ្ឋ ដោយរដ្ឋមិនចេញសំណងឲ្យឡើយ។

<u>មាត្រា១២</u>៖ រដ្ឋជាកម្មសិទ្ធិករនៃទ្រព្យសម្បត្តិទាំងឡាយក្នុងដែនដី នៃព្រះរាជាណាចក្រកម្ពុជាដែលបានចែងក្នុងមាត្រា៥៨ នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ និងទ្រព្យនិទាយាទភាពទាំងអស់ ឬ

ទ្រព្យដែលម្ចាស់ប្រគល់ឲ្យរដ្ឋដោយស្ម័គ្រចិត្ត ឬទ្រព្យ ដែលមិនមែនជាកម្មវត្ថុនៃការយកធ្វើជារបស់ឯកជនតាមច្បាប់ ឬមិនមែនជាទ្រព្យ ដែលកំពុងកាន់កាប់ជារបស់ឯកជនស្របតាមបទបញ្ញត្តិនៃជំពូកទី៤ នៃច្បាប់នេះ។

<u>មាត្រា១៦</u>៖ ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋមិនអាចលក់ដូរបានឡើយ ហើយកម្មសិទ្ធិនៃទ្រព្យទាំងនោះមិនអាចកំណត់អាយុកាលបានទេ។ ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មិនអាចបិតនៅក្រោមការកាន់កាប់ដោយលទ្ធកម្មពិសេសនៃជំពូកទី៤នៃច្បាប់នេះបានទេ។ ប៉ុន្តែទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋអាចជាកម្មវត្ថុនៃការអនុញ្ញាតឲ្យកាន់កាប់ ឬ ប្រើប្រាស់ជាបណ្តោះអាសន្នមិនទៀងហើយអាចដកហូតវិញបាន បើមិនបានបំពេញកាតព្វកិច្ចបង់ពន្ធផ្សេងៗ លើកលែងតែបានអនុញ្ញាតតាមជំពូកទី៣នៃច្បាប់នេះ។ ការអនុញ្ញាតទាំងនេះមិនអាចប្រែក្លាយទៅជាកម្មសិទ្ធិ ឬជាសិទ្ធិភណ្ឌិកជាប្រយោជន៍ដល់អ្នកកាន់កាប់ទ្រព្យទាំងនេះបានឡើយ។ ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនៅពេលបាត់បង់ផលប្រយោជន៍សាធារណៈ អាចត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋតាមរយៈច្បាប់អនុបយោគ។

<u>មាត្រា១៨</u>៖ ត្រូវទុកជាមោយៈ និងគ្មានអានុភាព ហើយមិនអាចត្រូវបានធ្វើនិយ័តកម្ម ទោះតាមរូបភាពណាក៏ដោយនូវ៖

- រាល់ការចូលកាន់កាប់ទ្រព្យសម្បត្តិសាធាណៈរបស់រដ្ឋ និងនីតិបុគ្គលសាធារណៈ និងរាល់ការបំប្លែងការកាន់កាប់ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ទៅជាសិទ្ធិកម្មសិទ្ធិ ទោះបីការកាន់កាប់ និងការបំប្លែងនេះកើតឡើងនៅពេលណាក៏ដោយ ដែលមិនសមស្របតាមលិខិតបទដ្ឋានគតិយុត្ត និងនីតិវិធីដែលបានកំណត់កន្លងមក។
- រាល់ការបំប្លែងទៅជាសិទ្ធិកម្មសិទ្ធិនៃដីសម្បទាន ទោះជាការបំប្លែងនោះកើតឡើងមុនពេលច្បាប់នេះចូលជាធរមានក៏ដោយ លើកលែងតែសម្បទានដែលឆ្លើយតបទៅនឹងប្រយោជន៍សង្គម។
- រាល់សម្បទានមិនស្របនឹងបញ្ញត្តិទាំងឡាយនៃជំពូកទី៥។
- រាល់ការចូលកាន់កាប់ទ្រព្យសម្បត្តិ ឯកជនរបស់រដ្ឋ ទោះជាតាមរូបភាពណាក៏ដោយដែលបានកើតឡើងក្រោយច្បាប់នេះចូលជាធរមាន។

<u>មាត្រា២០</u>៖ បុគ្គលទាំងឡាយដែលបានអាស្រ័យផលនៃភោគៈដោយសន្តិវិធី និងមិនមានការជំទាស់ចាប់ពី៥(ប្រាំ)ឆ្នាំយ៉ាងតិច គិតមកដល់ការបរិច្ឆេទនៃការប្រកាសឲ្យប្រើច្បាប់នេះ លើអចលនវត្ថុ ដែលមានលក្ខណៈត្រឹមត្រូវតាមច្បាប់ក្នុងការកាន់កាប់ជាឯកជន មានសិទ្ធស្នើសុំប័ណ្ណកម្មសិទ្ធិស្តាពរ។ ក្នុងករណីមានការជំទាស់ដល់ការផ្តល់ប័ណ្ណកម្មសិទ្ធិស្តាពរនេះ អ្នកតវ៉ាត្រូវយកភស្តុតាងមកបញ្ជាក់ថាខ្លួនឯងផ្ទាល់បានបំពេញលក្ខខណ្ឌនៃ

ភោគ:ដោយសន្តិវិធី និងមិនមានការជំទាស់ចាប់ពី៥(ប្រាំ)ឆ្នាំនៅលើអចលនវត្ថុដែលមានទំនាស់ឬយកភស្តុតាង ដែលថាខ្លួនបានទិញអចលនវត្ថុនោះពីភាគីដើម ឬពីសិទ្ធិវន្តស្របច្បាប់ ឬអ្នកទទួលផ្ទេរកម្មសិទ្ធិពីសន្តិជនរបស់ខ្លួន។

<u>មាត្រា៣៤៖</u> អ្នកកាន់កាប់ថ្មីលើអចលនវត្ថុរបស់នីតិបុគ្គលសាធារណៈ ឬរបស់បុគ្គលឯកជនដោយគ្មានប័ណ្ណក្រោយច្បាប់នេះចូលជាធរមាន ត្រូវចាត់ទុកជាអ្នកកាន់កាប់ដោយខុសច្បាប់ ហើយត្រូវទទួលទោសដូចមានចែងក្នុងមាត្រា២៥៩ នៃច្បាប់នេះ។

<u>មាត្រា៣៥៖</u> មានតែអាជ្ញាធរមានសមត្ថកិច្ចក្នុងនាមរដ្ឋ និងនីតិបុគ្គលសាធារណៈប៉ុណ្ណោះ ដែលអាចឲ្យអ្នកកាន់កាប់អចលនវត្ថុគ្មានប័ណ្ណ ឬមានប័ណ្ណមិនគ្រប់គ្រាន់ចាកចេញពីទីតាំងអចលនវត្ថុនោះ។ សាមញ្ញជន ឬអាជ្ញាធរដែលមិនតាងនាមរដ្ឋ ឬនីតិបុគ្គលសាធារណៈគ្មានសមត្ថកិច្ចដេញអ្នកកាន់កាប់ដោយសន្តិភាពមានប័ណ្ណត្រឹមត្រូវ ដោយប្រើកម្លាំងបានឡើយ។ ការដេញអាចធ្វើបានតាមការបង្គាប់របស់តុលាការ យោងតាមបណ្តឹងរបស់បុគ្គលដែលបានប្តឹងទាមទារទ្រព្យ។ តុលាការ ត្រូវពិនិត្យបញ្ជាក់រូបភាពប្រភពកាលបរិច្ឆេទ និងលក្ខខ័ណ្ឌទាំងឡាយនៃប័ណ្ណដែលបានបង្ហាញ។ តុលាការមិនអាចប្រកែកក្នុងការបង្គាប់ឲ្យចាកចេញ ដើម្បីជាប្រយោជន៍ដល់បុគ្គលដែលបង្ហាញប័ណ្ណត្រឹមត្រូវ និងពេញលេញរបស់សុរិយោដីបានឡើយ។

<u>មាត្រា៤៤៖</u> ក្នុងករណីដែលអាជ្ញាធរមានសមត្ថកិច្ច មិនព្រមចេញប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុអ្នកកាន់កាប់អចលនវត្ថុនោះអាចធ្វើពាក្យប្តឹងទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

<u>មាត្រា៤៧៖</u> វិវាទរវាងភាគីចំពោះអចលនវត្ថុមួយ នឹងត្រូវដាក់ឲ្យធ្វើការស៊ើបអង្កេត និងដោះស្រាយតាមនីតិវិធីកំណត់។ លទ្ធផលនៃការស៊ើបអង្កេតត្រូវដាក់ជូនគណៈកម្មាការសុរិយោដីដែលបង្កើតឡើងនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ គណៈកម្មាការនេះត្រូវធ្វើសេចក្តីសំរេចលើបដិវាទកម្មនោះ។ ក្នុងករណីមិនសុខចិត្ត គូវិវាទអាចប្តឹងទៅតុលាការបាន។ ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការនេះដោយអនុក្រឹត្យ។

<u>មាត្រា៤៧៖</u> កម្មសិទ្ធិករនៃដីអាចធ្វើនៅលើដីរាល់ការដាំដុះ ការរៀបចំ និងការសាងសង់តាមបំណងរបស់ខ្លួនលើកលែងតែមានច្បាប់ហាមឃាត់។ ការរៀបចំ ឬការសាងសង់ទាំងនោះ ជាកម្មសិទ្ធិរបស់ខ្លួនទាំងអស់ស្របតាមបញ្ញត្តិនៃផ្នែកទី៣នៃជំពូកនេះ។

<u>មាត្រា១១៤៖</u> បែបបទសំណង់ និងលក្ខខ័ណ្ឌទាំងឡាយនៃការរៀបចំដែនដី និងនគរូបនីយកម្មចំពោះកម្មសិទ្ធិករនឹងកំណត់ដោយអនុក្រឹត្យ។

<u>មាត្រា១៧៤៖</u> សហកម្មសិទ្ធិ គឺជាកម្មសិទ្ធិលើទ្រព្យជាអចលនវត្ថុរបស់បុគ្គលច្រើននាក់បែងចែកតាមឡូត៍ដែលម្នាក់ៗបានមួយចំណែកជាឯកជនហើយមួយចំណែកទៀតជាផ្នែកនៃទ្រព្យរួម

<u>មាត្រា១៧៦</u>៖ សហកម្មសិទ្ធិករទាំងឡាយអាចរៀបចំបទបញ្ជាផ្ទៃក្នុងដែលកំណត់របៀបគ្រប់គ្រងនិងវិធានការនៃការថែទាំព្រមទាំងកាតព្វកិច្ចរបស់សហកម្មសិទ្ធិករ ជាពិសេសចំពោះផ្នែករួមដោយគោរពតាមបទបញ្ញត្តិទាំងឡាយនៃច្បាប់នេះ។ ក្នុងករណីដែលគ្មានបទបញ្ជាផ្ទៃក្នុងនេះទេសហកម្មសិទ្ធិត្រូវស្ថិតនៅក្រោមបទបញ្ញត្តិទាំងឡាយ ដែលបានកំណត់ពីមាត្រា១៧៧ ដល់មាត្រា១៨៥នៃច្បាប់នេះ។

៣.៧ ច្បាប់ស្តីពីការងារ (ឆ្នាំ១៩៩៧)

ច្បាប់ស្តីពីការងារ ដែលរដ្ឋសភាបានអនុម័តនៅកាលពីថ្ងៃទី ១០ ខែមករា ឆ្នាំ១៩៩៧។ នាសម័យប្រជុំលើកទី៧ នីតិកាលទី១ ហើយបានដាក់ឱ្យប្រើប្រាស់ដោយព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលមានមាត្រាពាក់ព័ន្ធ និងគម្រោងនេះដូចតទៅ៖

<u>មាត្រា១០២</u>៖ តាមន័យនៃច្បាប់នេះពាក្យថា ប្រាក់ឈ្នួលទោះបីការកំណត់ ឬរបៀបគិតយ៉ាងណាក៏ដោយ មានន័យថា ឈ្នួលការងារ ឬឈ្នួលសេវាដែលអាចគិតជាប្រាក់បាន ឬកំរិតបានដោយការព្រមព្រៀងគ្នា ឬដោយច្បាប់ជាតិដែលនិយោជក ត្រូវបើកឲ្យកម្មករនិយោជកតាមកិច្ចសន្យាជួលការងារ ឬសេវាដោយលាយលក្ខណ៍អក្សរឬដោយមាត់ ទៅចំពោះការងារដែលបានធ្វើក្តី ឬដែលត្រូវធ្វើក្តីចំពោះសេវាដែលបានបំពេញ ឬត្រូវបំពេញក្តី។

<u>មាត្រា១៦១</u>៖ រៀងរាល់ឆ្នាំក្រសួងទទួលបន្ទុកវិស័យការងារ ចេញប្រកាសកំណត់ថ្ងៃបុណ្យដែលត្រូវមានប្រាក់ឈ្នួលសំរាប់កម្មករនិយោជិកនៃសហគ្រាសទាំងអស់។ ថ្ងៃបុណ្យឈប់សំរាកមានប្រាក់ឈ្នួលទាំងឡាយនេះ មិនផ្តាច់ចិរវេលាធ្វើការដែលត្រូវគិតដើម្បីឲ្យឈប់សំរាកប្រចាំថ្ងៃ ឆ្នាំនោះដែរ។

<u>មាត្រា១៦២</u>៖ ក្នុងករណីថ្ងៃបុណ្យដែលត្រូវបានឈប់សំរាកចំថ្ងៃអាទិត្យនោះ កម្មករនិយោជិកនឹងត្រូវបានឈប់សម្រាកមួយថ្ងៃ (០១ថ្ងៃ) បន្តទៀត។ ការឈប់សំរាកថ្ងៃបុណ្យមិនមែនជាហេតុនាំបន្ថយប្រាក់ឈ្នួលប្រចាំខែ ប្រចាំឆមាស ឬប្រចាំសប្តាហ៍ឡើយ។

<u>មាត្រា១៦៣</u>៖ កម្មករនិយោជិកធ្វើការតាមម៉ោងប្រចាំថ្ងៃ ឬតាមបរិមាណផលិតផលត្រូវមានសិទ្ធិ បានប្រាក់បំណាច់ស្មើនឹងប្រាក់ឈ្នួលដែលបង់ខាតមកពីការឈប់បុណ្យ មានចែងក្នុងមាត្រា១៦១ ខាងលើ។ ប្រាក់បំណាច់ នេះត្រូវនៅក្នុងបន្ទុកនៃនិយោជក។

<u>មាត្រា១៦៤</u>៖ នៅក្នុងគ្រឹះស្ថានសហគ្រាសណា ដែលមិនអាចបញ្ឈប់ការងារបាន ដោយសារសកម្មភាពរបស់ខ្លួនតម្រូវឲ្យកម្មករ និយោជិក ទាំងឡាយដែលជាប់ធ្វើការក្នុងថ្ងៃឈប់បុណ្យត្រូវមានសិទ្ធិទទួលក្រៅអំពីប្រាក់ឈ្នួលនៃការងារ ដែលខ្លួនបានធ្វើនូវប្រាក់

Draft

របាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាននិងសង្គមពេញលេញ លើគម្រោង ខ្សែកាន់ម៉ូ២ និច ២ ១ ១ ១

បំណាច់ដែលនៅលើបន្ទុកនិយោជកដែរ ហើយដែលកម្រិតក្នុងប្រការក្រសួងទទួលបន្ទុកវិស័យការងារ។

<u>មាត្រា២៧១</u>៖ និយោជកមានសិទ្ធិអនុញ្ញាតឲ្យកម្មករនិយោជិកខ្លួន ឈប់សំរាកជាពិសេសក្នុងឱកាសមានព្រឹត្តិការណ៍ដែលប៉ះពាល់ផ្ទាល់ដល់គ្រួសារនៃកម្មករនិយោជិក។

- ក្នុងករណីដែលកម្មករនិយោជិកមិនទាន់ អនុវត្តការឈប់សំរាកប្រចាំឆ្នាំទាំងអស់របស់ខ្លួនទេ និយោជកអាចធ្វើការកាត់កងការឈប់សំរាកពិសេសខាងលើ ពីការឈប់សំរាកប្រចាំឆ្នាំរបស់កម្មករនិយោជិកបានទេ។
- ក្នុងករណីដែលកម្មករនិយោជិកបានអនុវត្ត ការឈប់សំរាកប្រចាំឆ្នាំរបស់ខ្លួនរួចអស់ហើយនិយោជកមិនអាចធ្វើការកាត់កងការឈប់សំរាក ពិសេសខាងលើពីការឈប់សំរាកប្រចាំឆ្នាំសំរាប់ឆ្នាំខាងមុខរបស់កម្មករ និងនិយោជិកបានទេ។
- ម៉ោងធ្វើការដែលបង់ក្នុងឱកាសឈប់សំរាកពិសេសនេះ អាចនឹងបំពេញវិញបានតាមល័ក្ខខ័ណ្ឌដូចមានក្នុងកំរិតប្រកាសពីក្រសួងទទួលបន្ទុកក្នុងវិស័យការងារ។

<u>មាត្រា២៣៨</u>៖ សហគ្រាស និងគ្រឹះស្ថានដែលចង្អុលក្នុងមាត្រា១ នៃច្បាប់នេះត្រូវរៀបចំឲ្យមានការព្យាបាលបឋមសម្រាប់កម្មករនិយោជិករបស់ខ្លួន។

<u>មាត្រា២៤៣</u>៖ កាលណាសហគ្រាសដែលចង្អុលក្នុងមាត្រា២២៨ មានសាខា ឬការដ្ឋានមួយ ឬច្រើនដែលមានប្រើកម្មករនិយោជិកយ៉ាងតិចហាសិប (៥០នាក់) ហើយស្ថិតនៅចម្ងាយលើសពីប្រាំ (០៥) គីឡូម៉ែត្រពីការដ្ឋានធំ និយោជកត្រូវតែផ្តល់ចំពោះសាខា ឬការដ្ឋានទាំងនោះឲ្យដូចចំពោះការដ្ឋានធំដែរ នូវមធ្យោបាយសង្គ្រោះ និងព្យាបាល កម្មករនិយោជិកខ្លួនឲ្យបានសព្វគ្រប់ដូចជា បុគ្គលិកពេទ្យសំណង់ សំភារៈ វត្ថុរបួស និង ថ្នាំព្យាបាល។

៣.៨ ច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានព្រៃ (២០០១)

ច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មព្រៃ ដែលរដ្ឋសភាបានអនុម័តកាលពី ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០១ នាសម័យប្រជុំពេញអង្គលើកទី៦ នីតិកាលទី២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមលើទំរង់ និងគតិនៃច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០១ នាសម័យប្រជុំពេញអង្គលើកទី៥ នីតិកាលទី១។ មាត្រាសំខាន់ៗនៃច្បាប់នេះមានសេចក្តីដូចខាងក្រោម៖

<u>មាត្រា១</u>៖ ច្បាប់នេះមានគោលដៅកំណត់ការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានព្រៃ ការប្រើប្រាស់អណ្តូងព្រៃ ព្រមទាំងរាល់សកម្មភាពទាំងឡាយដែលទាក់ទងទៅនឹងប្រតិបត្តិការ

ធនធានរ៉ែនៅព្រះរាជាណាចក្រកម្ពុជា។ លើកលែងតែប្រតិបត្តិការប្រេងកាត និងឧស្ម័នត្រូវស្ថិតនៅក្រោមច្បាប់មួយដោយឡែក។

<u>មាត្រា២</u>៖ ធនធានរ៉ែទាំងអស់ដែលបិតនៅក្នុងដី លើដី ឬក្រោមដីនៃដែនគោក ភ្នំ ខ្ពង់រាប ដែនទឹក ដែនសមុទ្រ កោះ បាតសមុទ្រ ក្រោមបាតសមុទ្រ ក្នុងបូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជាជាសម្បត្តិរដ្ឋ។

<u>មាត្រា៣</u>៖ ធនធានរ៉ែ គឺជាសារធាតុទាំងឡាយណា ទោះជាក្នុងទម្រង់រឹង រាវ ឧស្ម័ន ដែលកើតឡើងដោយធម្មជាតិតាមដំណើរវិវត្តភូគព្ភសាស្ត្រ ឬជាលទ្ធផលនៃការជីកយកពីក្នុងដី លើដី ក្នុងសមុទ្រ ក្រោមបាតសមុទ្រ មានជាអាទ៍ត្សុងថ្ម ធ្យូងថ្ម រ៉ែអលោហៈ ទឹកខនិជ ថ្ម ក្រូស ខ្សាច់ ដី ឥដ្ឋ ប្រេងកាត និងឧស្ម័ន។

ប្រតិបត្តិការធនធានរ៉ែ គឺជាការធ្វើសកម្មភាពបុរេសនា ស្វែងរុករក និងអាជីវកម្មធនធានរ៉ែ។

បុរេសនា គឺជាការស្វែងរុករកជំហានដំបូងនៅស្រទាប់ដីលើ ដោយប្រើប្រាស់ឧបករណ៍សាមញ្ញ ហើយមានការប៉ះពាល់បន្តិចបន្តួចដល់ផ្ទៃដី ដើម្បីកំណត់វត្តមានធនធានរ៉ែ ដែលមានតំលៃពាណិជ្ជកម្ម និងអាចជាទិសដៅសម្រាប់ការ ស្នើសុំអាជ្ញាប័ណ្ណស្វែងរុករក និងអាជីវកម្មធនធានរ៉ែ។

ការស្វែងរុករក គឺជាការសិក្សាស្រាវជ្រាវក្នុងបំណងរកឲ្យឃើញ ធ្វើតេស្តសន្ទស្សន៍រ៉ែ ដើម្បីកំណត់សក្តានុពល ទំហំគុណភាព បរិមាណ ព្រមទាំងលទ្ធភាពសេដ្ឋកិច្ច អាជីវកម្មតាមរយៈការធ្វើបុរេសនា ការស្រាវជ្រាវភូគព្ភសាស្ត្រ រូបភូគព្ភសាស្ត្រ និងគីមីភូគព្ភសាស្ត្រ ការជីកកកាយ ការខួង ការដឹកជញ្ជូន និងការធ្វើវិភាគដី ដីល្បាប់ ទឹក ថ្ម និងគំរូរ៉ែផ្សេងៗទៀត។

អាជីវកម្មធនធានរ៉ែ គឺជាប្រតិបត្តិការជីកយកធនធានរ៉ែដែលក្នុងនោះធនធានរ៉ែ ត្រូវបានយកចេញពីជម្រករ៉ែធ្វើប្រព្រឹត្តកម្ម ដឹកជញ្ជូន លក់ដូរ ឬការនាំចេញក្នុងគោលបំណងពាណិជ្ជកម្ម។ ដោយឡែកការលក់ដូរ ការនាំចេញការនាំចូលលោហធាតុមានតំលៃ ត្សុងថ្មមានតំលៃដែលមិនទាន់ច្នៃនិងកែច្នៃរួចហើយត្រូវស្ថិតនៅក្រោមបញ្ញត្តិច្បាប់នៃព្រះរាជាណាចក្រកម្ពុជាដែលមានជាធរមាន។

<u>មាត្រា៤</u>៖ អាជ្ញាប័ណ្ណធនធានរ៉ែ គឺជាលិខិតអនុញ្ញាតដែលផ្តល់នូវសិទ្ធិឲ្យទៅសម្បទានិកដោយស្ថាប័នមានសមត្ថកិច្ចដើម្បីអនុវត្តសកម្មភាពប្រតិបត្តិការធនធានរ៉ែ។

<u>មាត្រា៥</u>៖ គ្មានរូបវន្តបុគ្គល ឬនីតិបុគ្គលណាអាចធ្វើការស្វែងរុករក ឬធ្វើអាជីវកម្មធនធានរ៉ែដោយគ្មានអាជ្ញាប័ណ្ណធនធានរ៉ែ ដែលចេញឲ្យដោយស្ថាប័នមានសមត្ថកិច្ចឡើយ លើកលែងតែម្ចាស់កម្មសិទ្ធ ឬអ្នកកាន់កាប់ស្របច្បាប់លើដីធ្លី ដែលជាឯកជនអាចប្រើប្រាស់ គ្រួស ខ្សាច់ ថ្ម ដីឥដ្ឋ ដោយមិនចាំបាច់មានអាជ្ញាប័ណ្ណ តែមិនអនុញ្ញាតឲ្យដឹកជញ្ជូនចេញផុតពីព្រំដែនដី ធ្លី ជាកម្មសិទ្ធិដើម្បីធ្វើអាជីវកម្មនោះទេ។

ប្រជាពលរដ្ឋខ្មែរអាចធ្វើបុរេសនានៅលើដីរបស់រដ្ឋ ឲ្យតែដីនោះរដ្ឋមិនទាន់ចេញអាជ្ញាប័ណ្ណធនធានរ៉ែទៅបុគ្គលដទៃ។

<u>មាត្រា៦</u>៖ រូបវន្តបុគ្គល ឬនីតិបុគ្គលអាចនឹងទទួលអាជ្ញាប័ណ្ណធនធានរ៉ែបានទៅតាមការពិនិត្យពិចារណានៅ លើសមត្ថភាពបច្ចេកទេស ហិរញ្ញវត្ថុ និងការចុះបញ្ជីពាណិជ្ជកម្ម។

<u>មាត្រា៧</u>៖ មុននឹងចូលទៅក្នុងដីដែលជាកម្មសិទ្ធិឯកជនដើម្បីធ្វើការស្វែងរុករក និងជីកយករ៉ែ សម្បទានិកត្រូវមានការព្រមព្រៀងជាលាយលក្ខណ៍អក្សរជាមួយម្ចាស់កម្មសិទ្ធិដីធ្លី ស្តីពីការមិនជ្រៀតជ្រែង មិនប៉ះពាល់ដល់ទ្រព្យសម្បត្តិ និងការងារព្រមទាំងធ្វើការទូទាត់សងលើការខូចខាត ដែលកើតមាននៅលើផ្ទៃដី ដែលបណ្តាលមកពីសកម្មភាពប្រតិបត្តិការធនធានរ៉ែ។

មុននឹងចូលក្នុងតំបន់ដែលជាកម្មសិទ្ធិរបស់រដ្ឋដែលកំណត់ថា ជាតំបន់ការពារ តំបន់បំរុងទុក ឬតំបន់ហាមឃាត់ដើម្បីស្វែងរុករក និងជីកយករ៉ែ សម្បទានិកត្រូវមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីស្ថាប័នមានសមត្ថកិច្ច ឬស្ថាប័នអន្តរក្រសួងដែលមានតួនាទីគ្រប់គ្រងលើតំបន់នោះ។

<u>មាត្រា៨</u>៖ ការធ្វើបុរេសនា ការស្វែងរុករក និងធ្វើអាជីវកម្មធនធានរ៉ែនៅលើដីជាកម្មសិទ្ធិរដ្ឋ ដែលបានកំណត់ជាតំបន់វប្បធម៌ ទីតាំងប្រវត្តិសាស្ត្រ តំបន់បេតិកភ័ណ្ឌជាតិ ត្រូវហាមឃាត់។

<u>មាត្រា៩</u>៖ មិនអាចចេញអាជ្ញាប័ណ្ណធានធានរ៉ែឲ្យត្រួតគ្នានៅតំបន់ណាមួយ ដែលស្ថិតនៅក្រោមការកាន់កាប់របស់សម្បទានិកមួយផ្សេងទៀតរួចទៅហើយ ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីរដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែដែលបញ្ជាក់ថា សិទ្ធិផ្តាច់មុខរបស់សម្បទានិកមុនពុំមានលក្ខណៈគ្រប់គ្រាន់តាមផ្លូវច្បាប់ឡើយ។

៣.៩ ច្បាប់ស្តីពីការវិនិយោគ និងច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា

ក. ច្បាប់ស្តីពីការវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា អនុម័តនៅថ្ងៃទី០៤ ខែសីហា ឆ្នាំ ១៩៩៤ នាសម័យប្រជុំវិសាមញ្ញនីតិកាលទី១ ហើយដែលមានសេចក្តីសំខាន់ៗដូចតទៅ:

<u>មាត្រា១</u>៖ ច្បាប់នេះមានវិសាលភាពគ្របដណ្តប់លើការវិនិយោគនានា ដែលអនុវត្តនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ដោយអ្នកវិនិយោគជាជនជាតិខ្មែរនិង /ឬជនបរទេស។

<u>មាត្រា២</u>៖ អ្នកវិនិយោគទាំងអស់ត្រូវស្ថិតនៅក្រោមច្បាប់នេះ ហើយអាចជារូបវន្តបុគ្គល ឬជានីតិបុគ្គល។

មាត្រា៣៖ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាអង្គការមានសមត្ថកិច្ច និងជាច្រកចេញចូលតែមួយគត់ក្នុងការទទួលបន្ទុកការងារនីតិសម្បទាអភិវឌ្ឍន៍ និងការវិនិយោគ។ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាសេនាធិការរបស់រាជរដ្ឋាភិបាល ក្នុងការពិនិត្យ និងសំរេចការងារនីតិសម្បទា និងអភិវឌ្ឍន៍ និងការវិនិយោគនានា។

មាត្រា៤៖ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានគណៈកម្មាធិការពីរសម្រាប់ជំនួយការគឺ៖

១.គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍

២.គណៈកម្មាធិការវិនិយោគកម្ពុជា។

មាត្រា៥៖ ការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវកំណត់ដោយអនុក្រឹត្យ។

មាត្រា៦៖ អ្នកវិនិយោគត្រូវដាក់ពាក្យសុំទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីពិនិត្យ និងសំរេច។

មាត្រា៧៖ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវឆ្លើយតបអំពីការសំរេចរបស់ខ្លួនទៅអ្នកវិនិយោគ ក្នុងរយៈពេល៤៥ថ្ងៃយ៉ាងយូរ គិតពីថ្ងៃទទួលពាក្យសុំដែលបានបំពេញបែបបទត្រឹមត្រូវ និងគ្រប់គ្រាន់។ បើគ្មានមូលហេតុត្រឹមត្រូវ មន្ត្រីរាជការណាដែលប្រកែកមិនព្រមពិនិត្យ និងឆ្លើយតបអំពីការសំរេចរបស់ខ្លួនទៅអ្នកវិនិយោគវិញ ហួសកាលកំណត់ខាងលើ ត្រូវផ្តន្ទាទោសតាមបញ្ញត្តិច្បាប់។

មាត្រា៨៖ អ្នកវិនិយោគត្រូវបានទទួលស្គាល់ និងចាត់ទុកដោយស្មើភាពគ្នាចំពោះមុខច្បាប់ គ្មានការរើសអើងអំពីសញ្ជាតិ ឬពូជសាសន៍ទេ លើកលែងតែចំពោះកម្មសិទ្ធិលើដីធ្លី ដូចដែលមានចែងក្នុងបទបញ្ញត្តិនៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា។

មាត្រា៩៖ រាជរដ្ឋាភិបាលនឹងមិនធ្វើជាគូបនីយកម្ម ដែលនាំឲ្យប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់អ្នកវិនិយោគក្នុងព្រះរាជាណាចក្រកម្ពុជាឡើយ។

មាត្រា១០៖ រាជរដ្ឋាភិបាលមិនត្រូវត្រួតពិនិត្យលើថ្លៃផលិតផល ឬថ្លៃសេវានានា របស់អ្នកវិនិយោគដែល បានទទួលការអនុញ្ញាតរួចហើយនោះឡើយ។

មាត្រា១១៖ ដោយអនុលោមទៅតាមច្បាប់ទាំងឡាយដែលពាក់ព័ន្ធ ព្រមទាំងបទបញ្ញត្តិទាំងឡាយដែលបានកំណត់ និងប្រកាសផ្សាយដោយធនាគារជាតិកម្ពុជា រាជរដ្ឋាភិបាលអនុញ្ញាតដល់អ្នកវិនិយោគ មានសិទ្ធិទិញរូបិយប័ណ្ណបរទេសតាមរយៈប្រព័ន្ធធនាគារ សម្រាប់បង្វិលទៅបរទេសវិញ ដើម្បីទូទាត់កាតព្វកិច្ចខាងហិរញ្ញវត្ថុដែលពាក់ព័ន្ធ និងការវិនិយោគរបស់ខ្លួន។ ការទូទាត់ខាងលើនេះរួមមាន៖

១- ការទូទាត់ខាងការនាំចូល ការបង្វិលទៅក្រៅប្រទេសទាំងដើមទាំងការនូវប្រាក់ចងការ។

២- ការទូទាត់ចំណាយសួយសារ និងថ្លៃសេវាគ្រប់គ្រង។

៣-ការផ្ទេរប្រាក់ចំណេញ។

៤- ការបង្វិលដើមទុនវិនិយោគទៅក្រៅប្រទេសវិញ ដូចមានចែងក្នុងជំពូកទី៨។

<u>មាត្រា១២</u>៖ រាជរដ្ឋាភិបាលលើកទឹកចិត្ត ដើម្បីជំរុញការវិនិយោគលើវិស័យសំខាន់ៗដូចតទៅ៖

១- ឧស្សាហកម្មនាំមុខ ឬឧស្សាហកម្មដែលមានបច្ចេកវិទ្យាខ្ពស់

២- ការបង្កើតការងារ

៣-ការបង្កើនការនាំចេញ

៤- ឧស្សាហកម្មទេសចរណ៍

៥- ការផលិតទំនិញកសិ-ឧស្សាហកម្ម និងឧស្សាហកម្មកែច្នៃ

៦- ការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការផលិតថាមពល

៧-អភិវឌ្ឍន៍ខេត្ត និងជនបទ

៨- ការការពារបរិស្ថាន

៩- ការវិនិយោគក្នុងតំបន់អភិវឌ្ឍន៍ពិសេស ដែលនឹងត្រូវបង្កើតឡើងដោយច្បាប់។

<u>មាត្រា១៣</u>៖ ការលើកទឹកចិត្តមាន ការលើកលែងទាំងស្រុង ឬមួយផ្នែកនៃពន្ធគយ និងពន្ធអាករ។

<u>មាត្រា១៤</u>៖ ការលើកទឹកចិត្តទាំងឡាយ រួមមានដូចខាងក្រោមនេះ៖

១- អត្រាពន្ធលើប្រាក់ចំណេញសុទ្ធ ៩% លើកលែងតែអត្រាពន្ធផ្សេងៗលើការរុករក និងអាជីវកម្មធនធានធម្មជាតិ ព្រៃឈើ ប្រេងកាត ផ្ការ៉ែ មាស ត្បូងថ្មមានតំលៃ។ល។ ដែលត្រូវចែងក្នុងច្បាប់ដោយឡែក។

២- ពន្ធលើប្រាក់ចំណេញ អាចលើកលែងបានរហូតដល់រយៈពេល៨ឆ្នាំ គឺអាស្រ័យលើលក្ខណៈសម្បត្តិរបស់អ្នកវិនិយោគនីមួយៗ និងអាទិភាព ដែលរាជរដ្ឋាភិបាលនឹងកំណត់ដោយអនុក្រឹត្យ។ ការលើកលែងពន្ធលើប្រាក់ចំណេញ នឹងត្រូវអនុវត្តចាប់ពីឆ្នាំដែលទទួលបានប្រាក់ចំណេញលើកទីមួយ។ ការខាតបង់រយៈពេល៥ឆ្នាំបន្តបន្ទាប់ ត្រូវបានអនុញ្ញាតឲ្យយកមកទូទាត់គិតប្រាក់ចំណេញ។ ក្នុងករណី យកប្រាក់ចំណេញមកធ្វើវិនិយោគបន្ត ប្រាក់ចំណេញត្រូវបានអនុញ្ញាតឲ្យរួចពន្ធទាំងស្រុង។

៣- មិនយកអាករលើការបែងចែកប្រាក់ចំណេញ នៃការវិនិយោគទុន ជាប្រាក់ទាំងនោះត្រូវផ្ទេរទៅបរទេសក្តី ឬបែងចែកក្នុងប្រទេសក្តី។

៤- ការលើកលែងពន្ធគយ និងពន្ធអាករ ១០០% ក្នុងការនាំចូលសម្ភារៈសំណង់ មធ្យោបាយផលិតកម្ម គ្រឿងសម្ភារៈបរិក្ខារ ទំនិញពាក់កណ្តាលសំរេច វត្ថុធាតុដើម និងគ្រឿងបន្លាស់សម្រាប់ប្រើប្រាស់ ត្រូវមានលក្ខខ័ណ្ឌណាមួយដូចតទៅ៖

ក. ការវិនិយោគដែលមានទិសដៅសម្រាប់បំពេញការនាំចេញ ក្នុងកំរិតអប្បបរមា ៨០% នៃផលិតផលសរុប។

ខ. មានទីតាំងនៅក្នុងតំបន់អភិវឌ្ឍន៍ពិសេស ដែលមានក្នុងបញ្ជីអាទិភាពសម្រាប់អភិវឌ្ឍន៍ប្រកាសដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

Draft

គ. ឧស្សាហកម្មទេសចរណ៍

ឃ. ឧស្សាហកម្មប្រើប្រាស់កម្លាំងពលកម្មច្រើន ឧស្សាហកម្មកែច្នៃ កសិ-ឧស្សាហកម្ម

ង. ការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការផលិតថាមពល។

ការលើកលែងពន្ធគយ និងពន្ធអាករ ១០០% ខាងលើនេះ ត្រូវអនុវត្តជារៀងរហូតស្របតាមរយៈពេលដែលកំណត់ក្នុងកិច្ចសន្យា ឬសៀវភៅបន្ទុក សម្រាប់ការវិនិយោគដែលផលិតផលទំនិញនាំចេញក្នុងកំរិតអប្បបរមា ៨០% នៃផលិតកម្មសរុប ដូចមានចែងក្នុងចំណុច (៤)ក ខាងលើ និងសម្រាប់ការវិនិយោគដែលមានទីតាំងក្នុងតំបន់អភិវឌ្ឍន៍ពិសេស ដូចមានចែងក្នុងចំណុច (៤)ខ។

ក្រៅពីប្រភេទការវិនិយោគដែលមានចែងក្នុងចំណុច (៤)ក និង (៤)ខ ខាងលើនេះ ការលើកលែងពន្ធគយ និងពន្ធអាករ ១០០% ត្រូវបានអនុញ្ញាតិឲ្យសម្រាប់តែក្នុងរយៈពេលនៃការរៀបចំកសាងសហគ្រាស រោងចក្រ អាគារ និងការចាប់ដំណើរការអាជីវកម្ម ផលិតកម្មនៅឆ្នាំដំបូងប៉ុណ្ណោះ។

៥- ការលើកលែងពន្ធគយ ១០០% ក្នុងការនាំចេញផលិតផលទៅក្រៅប្រទេស។

៦- ការអនុញ្ញាតឲ្យយកចូលមកក្នុងព្រះរាជាណាចក្រកម្ពុជានូវជនបរទេសណាដែលជា៖

- បុគ្គលិក និង អ្នកជំនាញការខាងគ្រប់គ្រង
- បុគ្គលិកបច្ចេកទេស
- កម្មករជំនាញ
- សហព័ន្ធ និងអ្នកក្នុងបន្ទុករបស់ខ្លួន ដែលអនុញ្ញាតដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ហើយស្របទៅតាមច្បាប់អន្តោប្រវេសន៍ និងច្បាប់ការងារ។

ខ. ច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា

ច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០០៣ នាសម័យប្រជុំពេញអង្គលើកទី៩ នីតិកាលទី២ ហើយដែលព្រឹទ្ធសភាបានយល់ស្របតាមលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ២៧ ខែកុម្ភៈ ឆ្នាំ២០០៣ នាសម័យប្រជុំពេញអង្គលើកទី៩ នីតិកាលទី១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

<u>មាត្រា១.ថ្មី</u>៖ ច្បាប់នេះ មានវិសាលភាពចំពោះរាល់គម្រោងវិនិយោគ មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងកំណត់នីតិវិធីនៃការបង្កើតគម្រោងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងកំណត់នីតិវិធីនៃការបង្កើតគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលធ្វើឡើងដោយបុគ្គលណាមួយ។ មានតែគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទេ ដែលមានសិទ្ធិទទួលបាននូវផលប្រយោជន៍ដែលស្ថិតក្នុងក្របខ័ណ្ឌនៃច្បាប់នេះ ។

មាត្រា២.ថ្នឹ៖ ក្នុងន័យនៃច្បាប់នេះ វាក្យសព្ទដូចខាងក្រោម ៖

- គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ហៅកាត់ **គ.ល.គ** មានន័យថា គម្រោងវិនិយោគដែលទទួលបានវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ
- ថ្ងៃធ្វើការ មានន័យថា ថ្ងៃប្រតិទិនដែលជាថ្ងៃធ្វើការជាផ្លូវការរបស់រាជរដ្ឋាភិបាលកម្ពុជា
- នីតិបុគ្គលសញ្ជាតិខ្មែរ មានន័យថា ក្រុមហ៊ុនដែលមានទីកន្លែងធ្វើអាជីវកម្ម និងដែលបានធ្វើការចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងភាគហ៊ុន ៥១% (ហាសិបមួយភាគរយ) ឬលើសក្នុងក្រុមហ៊ុន ត្រូវបានកាន់កាប់ដោយបុគ្គលមានសញ្ជាតិជាខ្មែរ
- បុគ្គល មានន័យថា រូបវន្តបុគ្គល ឬនីតិបុគ្គល
- អ្នកដាក់ពាក្យសុំ មានន័យថាបុគ្គល ឬក្រុមបុគ្គល ដែលដាក់សំណើវិនិយោគនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- អ្នកវិនិយោគ មានន័យថា បុគ្គលដែលអនុវត្តគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ។

មាត្រា១៤.ថ្នឹ៖ ការលើកទឹកចិត្តដែលមានចែងក្នុងមាត្រា ១៣ រួមមានដូចខាងក្រោម ៖

- គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ មានសិទ្ធិទទួលការលើកលែងពន្ធលើប្រាក់ចំណេញ ដែលមានកំណត់ក្នុងច្បាប់ស្តីពីសារពើពន្ធ ដោយទទួលបាននូវរយៈពេលលើកលែងពន្ធលើប្រាក់ចំណេញ។ រយៈពេលលើកលែងពន្ធរួមមាន ៖ រយៈពេលគន្លឹះបូករយៈពេល ៣(បី)ឆ្នាំបូករយៈពេលអាទិភាព។ រយៈពេលអាទិភាពនឹងត្រូវកំណត់ក្នុងច្បាប់ស្តីពី ការគ្រប់គ្រងហិរញ្ញវត្ថុ។ រយៈពេលគន្លឹះជាអតិបរមាគឺជាឆ្នាំទី ១ ដែលគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ទទួលប្រាក់ចំណូលដំបូងរបស់ខ្លួនដោយជ្រើសយកជម្រើសណាមួយដែលឆាប់ជាង ។
- គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ មានសិទ្ធិទទួលបាននូវការលើកទឹកចិត្តផ្អែកតាមកថាខណ្ឌ ១ ខាងលើ លុះត្រាតែគម្រោងនោះទទួលបានពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា នូវវិញ្ញាបនប័ត្រប្រចាំឆ្នាំ បញ្ជាក់ពីការបំពេញបាននូវកាតព្វកិច្ចចំពោះរដ្ឋដែលត្រូវកំណត់ដោយអនុក្រឹត្យ ។
- បន្ទាប់ពីផុតរយៈពេលលើកលែងពន្ធ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ត្រូវជាប់ពន្ធលើប្រាក់ចំណេញ ។
- គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលប្រើប្រាស់សិទ្ធិទទួលបាននូវការលើកទឹកចិត្តផ្អែកតាមកថាខណ្ឌ១ ខាងលើ ពុំមានសិទ្ធិធ្វើការទាមទារការរំលោះពិសេសណាមួយឡើយ ។

Draft

- គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលបម្រើទីផ្សារក្នុងស្រុក មានសិទ្ធិនាំចូលដោយរួចពន្ធគយនូវគ្រឿងសម្ភារៈបរិក្ខាផលិតកម្ម ដែលបម្រើទីផ្សារក្នុងស្រុក មានសិទ្ធិនាំចូលដោយ រួចពន្ធគយនូវគ្រឿងសម្ភារៈបរិក្ខាផលិតកម្ម សម្ភារៈសាងសង់បម្រើផលិតកម្ម ដែលត្រូវកំណត់ដោយអនុក្រឹត្យ
- ក្រៅពីគម្រោងវិនិយោគ មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ បម្រើឲ្យការនាំចេញ ដែលជ្រើសរើស ឬបានជ្រើសរើសយកយន្តការ ភណ្ឌាគារផលិតកម្មក្រោមការគ្រប់គ្រងរបស់គយ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់បម្រើឲ្យការនាំចេញដទៃទៀត មានសិទ្ធិនាំចូលដោយរួចពន្ធគយនូវគ្រឿងសម្ភារៈបរិក្ខាផលិតកម្ម សម្ភារៈសាងសង់ វត្ថុធាតុដើម ផលិតផលពាក់កណ្តាលសម្រេច និងសម្ភារៈបន្ទាប់បន្សំបម្រើផលិតកម្ម ដែលត្រូវកំណត់ដោយអនុក្រឹត្យ ។
- គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលជាប្រភេទឧស្សាហកម្មគាំទ្រមានសិទ្ធិនាំចូល ដោយរួចពន្ធគយ នូវគ្រឿងសម្ភារៈបរិក្ខាផលិតកម្ម សម្ភារៈ សាងសង់ វត្ថុធាតុដើម ផលិតផលពាក់កណ្តាលសម្រេច និងសម្ភារៈបន្ទាប់បន្សំបម្រើផលិតកម្មដែលត្រូវកំណត់ដោយអនុក្រឹត្យ ។
- បុគ្គលណាដែលបានទិញ ឬវិនិយោគ ដែលបានរំលាយបញ្ចូលគ្នាជាមួយអ្នកវិនិយោគណាមួយ អាចទទួលស្គងពីគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដោយធ្វើសំណើទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជានូវរាល់ការធានា សិទ្ធិ បុព្វសិទ្ធិ និងកាតព្វកិច្ចទាំងអស់ ដោយយោងទៅតាមនិតិវិធីនៃការទិញ ឬការរំលាយបញ្ចូលគ្នា ដែលត្រូវកំណត់ដោយអនុក្រឹត្យ ។
- គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលមានទីតាំងនៅក្នុងតំបន់អភិវឌ្ឍន៍ពិសេស ឬតំបន់ផលិតកែច្នៃនាំចេញ ដែលមានក្នុងបញ្ជីអាទិភាពសម្រាប់អភិវឌ្ឍន៍ ប្រកាសដោយក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា មានសិទ្ធិទទួលបាននូវការលើកទឹកចិត្ត និងបុព្វសិទ្ធិដូចគ្នានឹងគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ផ្សេងៗទៀតដូចមានចែងនៅក្នុងច្បាប់ ។
- គម្រោងវិនិយោគ មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ មានសិទ្ធិទទួលបាននូវការលើកលែងពន្ធនាំចេញ ១០០% (មួយរយភាគរយ) លើកលែងតែចំពោះសកម្មភាពទាំងឡាយ ដូចមានចែងនៅក្នុងច្បាប់ជាធរមាន ។
- គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ មានសិទ្ធិទទួលបាននូវទិដ្ឋាការ និងប័ណ្ណការងារ ដើម្បីធ្វើការនៅក្នុងព្រះរាជាណាចក្រកម្ពុជាសម្រាប់ជនបរទេសដែលធ្វើជាអ្នកគ្រប់គ្រង អ្នកបច្ចេកទេស និងកម្មករជំនាញ រួមទាំងទិដ្ឋាការស្នាក់នៅសម្រាប់សហព័ទ្ធ និងអ្នកនៅក្នុងបន្ទុករបស់ជនបរទេសទាំងនោះ ដែលអនុញ្ញាត

ដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ស្របតាមច្បាប់ស្តីពីអន្តោប្រវេសន៍ និងច្បាប់ស្តីពីការងារ ។

<u>មាត្រា១៨.ថ្មី</u>៖ អ្នកវិនិយោគត្រូវបានអនុញ្ញាតឲ្យជួលនិយោជិតបរទេសតាមលក្ខខណ្ឌដូចតទៅ៖

- គុណភាព សមត្ថភាព និងជំនាញមិនអាចរកបាននៅព្រះរាជាណាចក្រកម្ពុជាក្នុងចំណោមប្រជាពលរដ្ឋខ្មែរ។ ក្នុងករណីមានការជួលនិយោជិតប្រភេទនេះត្រូវផ្ញើជូនមកក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា នូវឯកសាររួមមាន សេចក្តីចម្លងលិខិតឆ្លងដែន សញ្ញាប័ត្រ និងប្រវត្តិរូបសង្ខេបរបស់និយោជិតនោះ
- ត្រូវមានលិខិតអះអាងពីតម្រូវការជួលនិយោជិតបរទេស។ អ្នកវិនិយោគត្រូវមានការយល់ព្រម និងលិខិតអនុញ្ញាតពីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
- មុននឹងចូលបម្រើការងារឲ្យអ្នកវិនិយោគ និយោជិតបរទេសត្រូវមានលិខិតអនុញ្ញាតឲ្យធ្វើការនៅព្រះរាជាណាចក្រកម្ពុជាពីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

អ្នកវិនិយោគមានកាតព្វកិច្ចដូចតទៅ ៖

- ធ្វើការបណ្តុះបណ្តាលសមស្របជូននិយោជិតខ្មែរជាប្រចាំ
- ជំរុញលើកកំពស់ដល់និយោជិតខ្មែរ ដើម្បីអាចក្លាយទៅជាអ្នកមានតួនាទីដែលមានកម្រិតខ្ពស់ ត្រូវធ្វើជាប្រចាំ ។

<u>មាត្រា២២.ថ្មី</u>៖ ប្រសិនបើ អ្នកវិនិយោគមានបំណងចង់បញ្ឈប់សកម្មភាព នៃគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់របស់ខ្លួនក្រៅផ្លូវការ អ្នកវិនិយោគត្រូវផ្តល់ជូនក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា នូវភ័ស្តុតាងបញ្ជាក់ថា គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ បានដោះស្រាយជំរះបំណុលរបស់ខ្លួនយ៉ាងត្រឹមត្រូវ រួមមានអ្នកប្តឹង ឬការទាមទារណាមួយពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទើបអ្នកវិនិយោគនោះត្រូវបានអនុញ្ញាតឲ្យបញ្ឈប់សកម្មភាព នៃគម្រោងវិនិយោគ មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាផ្លូវការ ឬរំលាយដោយយោងទៅតាមច្បាប់ជាធរមានពាក់ព័ន្ធនឹងវិស័យពាណិជ្ជកម្ម

៣.១០ ច្បាប់ប្រៃសណីយ៍

ច្បាប់ស្តីពី វិស័យប្រៃសណីយ៍ ដែលរដ្ឋសភាបានអនុម័តកាល ពីថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០២ នាសម័យប្រជុំពេញអង្គលើកទី ៨ នីតិកាលទី ២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២០ ខែ មិថុនា ឆ្នាំ ២០០២ នាសម័យប្រជុំពេញអង្គលើកទី ៧ នីតិកាលទី១ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅ ៖

Draft

<u>មាត្រា២</u>៖ ការងារសេវាកម្ម និងអាជីវកម្មប្រៃសណីយ៍ ត្រូវបំពេញប្រជាពលរដ្ឋគ្រប់រូប ដោយមិនប្រកាន់ពូជសាសន៍ ពណ៌សម្បុរ និន្នាការនយោបាយនិងសាសនា។

<u>មាត្រា៣</u>៖ ច្បាប់នេះមានវិសាលភាពអនុវត្តលើសេវាប្រៃសណីយ៍៖

- សេវាបញ្ជីប្រៃសណីយ៍
- សេវាបញ្ជីឆាប់រហ័ស
- សេវាបញ្ជូនប្រាក់តាមប្រៃសណីយ៍
- សេវាបញ្ជូនតាមរូបភាពទូរគមនាគម៍ និង
- សេវាប្រៃសណីយ៍តាមសំណូមពរ ។

<u>មាត្រា៦</u>៖ ប្រៃសណីយ៍បញ្ជូនប្រាក់គឺការបញ្ជូនប្រាក់របស់អតិថិជនតាមផ្លូវប្រៃសណីយ៍ និងទូរគមនាគមន៍នៅក្នុងប្រទេស ក្រោមរូបភាពអាណាត្តិប្រៃសណីយ៍ ឬ អាណត្តិទូរលិក ។

<u>មាត្រា៧</u>៖ សេវាប្រៃណីយ៍បញ្ជូនតាមរូបភាពទូរគមនាគមន៍ គឺជាសេវាប្រៃសណីយ៍តាម បច្ចេកវិទ្យាទំនើបដែលបញ្ជូនលិខិត ឬពត៌មានតាមឧបករណ៍អេឡិចត្រូនិក ឬអេឡិចត្រូម៉ាញ៉េទិករបស់វិស័យទូរគមនាគមន៍។

<u>មាត្រា១៤</u>៖ ការកំណត់តម្លៃនិងការបោះពុម្ពតែមប្រៃសណីយ៍ លិខិតអេរ៉ូហ្ក្រាមប័ណ្ណ ប្រៃសណីយ៍ និងការប្រើប្រាស់ម៉ាស៊ីនតែម សម្រាប់បម្រើសម្រាប់បំពេញការងារក្នុងវិស័យប្រៃសណីយ៍ ជាសមត្ថកិច្ចរបស់ក្រសួងប្រៃសណី និងទូរគមនាគន៍។

<u>មាត្រា១៥</u>៖ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ កំណត់តម្លៃសេវា ទូទាត់តម្លៃសេវាអន្តរជាតិ រវាងបណ្តាប្រទេសលើពិភពលោក ដោយអនុវត្តតាមអនុសញ្ញាសហភាពប្រៃសណីយ៍សកល និងយកប្រាក់និមិត្តរូបមួយមកអនុវត្ត ដែលកំណត់ការប្តូរប្រាក់ដោយមូលនិធិរូបិយវត្ថុអន្តរជាតិ។

<u>មាត្រា២៣</u>៖ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍អាចចេញអាជ្ញាប័ណ្ណឲ្យឯកជនធ្វើអាជីវកម្មខាងវិស័យប្រៃសណីយ៍ ក្រៅពីសេវាប្រៃសណីយ៍ដែលស្ថិតក្រោមអាជីវកម្មរបស់រដ្ឋ ដើម្បីជួយបំពេញ និងទ្រទ្រង់សេវាប្រៃសណីយ៍ទាំងអស់ជូនប្រជាពលរដ្ឋ។

-ល័ក្ខខ័ណ្ឌលើការចេញអាជ្ញាប័ណ្ណ ការកែសម្រួល ការព្យួរ ការដកហូត ឬការបដិសេធ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងប្រៃសណីយ៍ និងទូគមនាគមន៍។

<u>មាត្រា២៤</u>៖ គ្មានរូបវន្តបុគ្គល ឬនិតិបុគ្គលណាមួយអាចធ្វើអាជីវកម្មខាង វិស័យប្រៃសណីយ៍ ដោយគ្មានអាជ្ញាប័ណ្ណមានសុពលភាពដែលបានចេញដោយក្រសួងប្រៃសណីយ៍និងទូគមនាគមន៍។រូបវន្តបុគ្គល ឬនិតិបុគ្គលដែលទទួលបាននូវអាជ្ញាប័ណ្ណខាងលើមានសិទ្ធិធ្វើអាជីវកម្មខាងវិស័យប្រៃសណីយ៍ក្នុងកំរិតជាក់លាក់និងត្រឹមត្រូវតាមខ្លឹមសារនៃអាជ្ញាប័ណ្ណនោះតែប៉ុណ្ណោះ។

Draft

<u>មាត្រា២៥</u>៖ អាជ្ញាប័ណ្ណត្រូវចេញឲ្យតែចំពោះបុគ្គលណា ដែលមានសមត្ថភាពសមស្របទៅនឹងលក្ខខ័ណ្ឌតម្រូវរបស់ក្រសួងប្រៃសណីយ៍ និងទូគមនាគមន៍ ដើម្បីដំណើរការជាក្រុមហ៊ុនសេវាកម្មប្រៃសណីយ៍ និងដើម្បីបំពេញកាតព្វកិច្ច និងលក្ខខ័ណ្ឌសេវាកម្មដែលមានកំណត់នៅក្នុងអាជ្ញាប័ណ្ណនោះ។

-អ្នកកាន់អាជ្ញាប័ណ្ណនីមួយៗ ត្រូវគោរពលក្ខខណ្ឌទាំងឡាយ ដែលមានចែងក្នុងអាជ្ញាប័ណ្ណរបស់ខ្លួន លិខិតបទដ្ឋាននានារបស់ក្រសួងប្រៃសណីយ៍ និងទូគមនាគមន៍ ព្រមទាំងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

<u>មាត្រា២៦</u>៖ អ្នកកាន់អាជ្ញាប័ណ្ណមិនអាចជួល លក់ ឬបញ្ចាំអាជ្ញាប័ណ្ណរបស់ខ្លួនទៅឲ្យជនណាផ្សេងទៀតបានឡើយ។ ការបោះបង់ ឬការផ្ទេរអាជ្ញាប័ណ្ណរបស់ខ្លួនឲ្យទៅជនណាផ្សេងទៀតអាចធ្វើទៅបាន លុះត្រាតែមានការអនុញ្ញាតជាថ្មី ពីក្រសួងប្រៃសណីយ៍ និងទូគមនាគមន៍។

<u>មាត្រា២៧</u>៖ -ក្រសួងប្រៃសណីយ៍ និងទូគមនាគមន៍ អាចផ្តល់សិទ្ធិឲ្យរួបវន្តបុគ្គលធ្វើជាកត្តាប្រៃសណីយ៍នៅតាមជនបទ ដែលពុំទាន់មានទីស្នាក់ការប្រៃសណីយ៍និងទូគមនាគមន៍ដើម្បីសម្រួលដល់ការទទួល និងចែកចាយបញ្ជើឲ្យបានទូទាំងប្រទេស។ កត្តាប្រៃសណីយ៍នេះ ជាមន្ត្រីជាប់កិច្ចសន្យារបស់ក្រសួង។

-លក្ខខ័ណ្ឌនៃការផ្តល់សិទ្ធិនេះ និងលក្ខន្តិក:របស់កត្តាប្រៃសណីយ៍ជាប់កិច្ចសន្យាព្រមទាំងភារកិច្ច និងប្រាក់កម្រៃត្រូវកំណត់ដោយប្រកាសរបស់ក្រសួងប្រៃសណីយ៍ និងទូគមនាគមន៍។

<u>មាត្រា៣០</u>៖ ក្រសួងប្រៃសណីយ៍ និងទូគមនាគមន៍ ត្រូវភ្ជាប់ទំនាក់ទំនងជាមួយបណ្តាញប្រៃសណីយ៍គ្រប់ប្រទេស និងគោរពអនុវត្តទៅតាមសេចក្តីសំរេចទាំងឡាយ ដែលបានកំណត់ដោយសហភាពប្រៃសណីយ៍សកល ដើម្បីធានានូវចរន្ត ការប្រៃសណីយ៍ជាមួយអន្តរជាតិ។ក្រសួងប្រៃសណីយ៍ និងទូគមនាគមន៍ ត្រូវកំណត់អំពីការបែងចែកការទទួលខុសត្រូវក្នុងក្របខ័ណ្ឌអន្តរជាតិ ដើម្បីធានានូវប្រសិទ្ធិភាពខ្ពស់ និងឯកភាពទូទាំងពិភពលោក។

<u>មាត្រា៣៧</u>៖ ក្រោយពីបានទទួលសិទ្ធិប្រទានពីរាជរដ្ឋាភិបាល តាមករណីនីមួយៗ ការធ្វើអាជីវកម្មប្រៃសណីយ៍អន្តរជាតិ ក្រសួងប្រៃសណីយ៍ និងទូគមនាគមន៍មានសិទ្ធិចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាទ្វេភាគី ឬពហុភាគីលើវិស័យបច្ចេកទេសប្រៃសណីយ៍ ជាមួយបណ្តាប្រទេសលើពិភពលោកដោយអនុលោមទៅតាម របស់សហភាពប្រៃសណីយ៍សកល និងប្រៃសណីយ៍ប្រចាំតំបន់។

៣.១១ ច្បាប់ស្តីពីទេសចរណ៍ (២០០៩)

ច្បាប់ស្តីពីទេសចរណ៍ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៩ ខែមេសា ឆ្នាំ២០០៩ នាសម័យប្រជុំរដ្ឋសភាលើកទី២ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់ទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៩ នាសម័យប្រជុំវិសាមញ្ញ ហើយដែលមានសេចក្តីសំខាន់ៗដូចខាងក្រោម៖

<u>មាត្រា១</u>៖ ច្បាប់នេះមានគោលដៅកំណត់វិធាន និងយន្តការសម្រាប់គ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍នៃព្រះរាជាណាក្រកម្ពុជា។

<u>មាត្រា២</u>៖ ច្បាប់នេះមានគោលបំណងដូចតទៅ៖

- គ្រប់គ្រង និងអភិវឌ្ឍន៍វិស័យទេសចរណ៍ប្រកបដោយប្រសិទ្ធភាព គុណភាព និងនិរន្តរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្រ។
- រួមចំណែកការពារ និងថែរក្សាធនធានធម្មជាតិ វប្បធម៌ និងទំនៀមទំលាប់ដែលជាមូលដ្ឋានបម្រើឲ្យវិស័យទេសចរណ៍។
- ធានា និងលើកកម្ពស់គុណភាពសេវាកម្មទេសចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា តាមរយៈការបង្កើតប្រព័ន្ធធានាគុណភាពដោយផ្តល់សន្តិសុខ សុវត្ថិភាព ជាសុកភាព និងបង្កើនការពេញចិត្តដល់ទេសចរណ៍។
- ទាញយកផលប្រយោជន៍ក្នុងវិស័យទេសចរណ៍ ឲ្យបានជាអតិបរមា ធានាការបែងចែកប្រកបដោយសមធម៌ និងទប់ស្កាត់ផលប៉ះពាល់អវិជ្ជមាន នៃវិស័យទេសចរណ៍។
- លើកកម្ពស់កិច្ចសហប្រតិបត្តិការទូលំទូលាយ រកទីផ្សារ និងជំរុញការផ្សព្វផ្សាយទេសចរណ៍កម្ពុជាឲ្យកាន់តែមានប្រសិទ្ធភាព ដោយមានការចូលរួមពីផ្នែកសាធារណៈ និងផ្នែកឯកជន។
- អភិវឌ្ឍន៍ធនធានមនុស្សក្នុងវិស័យទេសចរណ៍។
- រួមចំណែកកសាងមិត្តភាព និងការយោគយល់ជាអន្តរជាតិ តាមរយៈឧស្សាហកម្មទេសចរណ៍។

<u>មាត្រា៦</u>៖ ផែនការអភិវឌ្ឍន៍ទេសចរណ៍ថ្នាក់ជាតិត្រូវ៖

ក. កំណត់គោលនយោបាយ យុទ្ធសាស្ត្រ និងផែនការជាតិសម្រាប់ការអភិវឌ្ឍន៍ និងផ្សព្វផ្សាយអំពីវិស័យទេសចរណ៍។

ខ. លើកឡើងរាល់វិធានការ ដើម្បីកាត់បន្ថយភាពក្រីក្រ និងធានាឲ្យបាននូវនិរន្តរភាព នៃការអភិវឌ្ឍវិស័យទេសចរណ៍ថ្នាក់ជាតិ។

គ. ធ្វើសមាហរណកម្មជាមួយផែនការទេសចរណ៍អាស៊ាន និងផែនការទេសចរណ៍អន្តរជាតិនានា។

មាត្រា៧៖ ផែនការអភិវឌ្ឍន៍ទេសចរណ៍ថ្នាក់តំបន់ និងផែនការអភិវឌ្ឍន៍ទេសចរណ៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវ៖

ក. កំណត់យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យទេសចរណ៍តាមតំបន់ និងនៅថ្នាក់រដ្ឋបាលរបស់ខ្លួន។

ខ. លើកឡើងនូវវិធានការនានា ដើម្បីកាត់បន្ថយភាពក្រីក្រ និងដើម្បីធានាឲ្យបាននូវនិរន្តរភាពនៃការអភិវឌ្ឍន៍ និងការគ្រប់គ្រងវិស័យទេសរណ៍ នៅតាមតំបន់ និងនៅតាមរដ្ឋបាលថ្នាក់ក្រោមជាតិ។

ផែនការអភិវឌ្ឍន៍ទេសចរណ៍ថ្នាក់តំបន់ ត្រូវរៀបចំឡើងឲ្យស្របទៅតាម ផែនការអភិវឌ្ឍន៍ទេសចរណ៍ថ្នាក់ជាតិ។ ផែនការអភិវឌ្ឍទេសចរណ៍របស់រដ្ឋបាល ថ្នាក់ក្រោមជាតិ ត្រូវរៀបចំឡើងឲ្យស្របទៅតាមផែនការអភិវឌ្ឍទេសចរណ៍ថ្នាក់តំបន់។

មាត្រា១១៖ ក្រសួងទេសចរណ៍ត្រូវមានការទទួលខុសត្រូវរួមគ្នាជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធដទៃទៀតក្នុងការចេញបទបញ្ញត្តិសំខាន់ៗ ដែលប៉ះពាល់ទៅលើ ឬទទួលរងការប៉ះពាល់ដោយឧស្សាហកម្មទេសចរណ៍។ ផ្នែកសំខាន់ៗទាំងនោះរួមមាន៖

- សមាគមន៍ឧស្សាហកម្មទេសចរណ៍
- ការការពារបរិស្ថាន
- ការការពារ និងការបង្ហាញពីមរតកវប្បធម៌
- ការវិនិយោគវិស័យទេសចរណ៍ និងការលើកទឹកចិត្ត
- ការគ្រប់គ្រង និងឯកជនភាវូបនីយកម្ម នៃសហគ្រាសទេសចរណ៍របស់រដ្ឋ
- ការគ្រប់គ្រងដីធ្លីរបស់រដ្ឋ ដែលបានជួលសម្រាប់គោលបំណងទេសចរណ៍
- ការទប់ស្កាត់ការធ្វើអាជីវកម្មផ្លូវភេទ
- ការអភិវឌ្ឍន៍ផលិតផលទេសចរណ៍
- អេកូទេសចរណ៍
- សហគមន៍ទេសចរណ៍មូលដ្ឋាន
- ការកាត់បន្ថយភាពក្រីក្រ
- អនាម័យ និងសុវត្ថិភាពចំណីអាហារ
- សន្តិសុខ និងសុវត្ថិភាពទេសចរ
- នគរបាលទេសចរណ៍។

ក្រសួងទេសចរណ៍ ក្រសួង ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធត្រូវសហការគ្នា ដើម្បីធានាថាផ្នែកនានានៅក្នុងឧស្សាហកម្មទេសចរណ៍ត្រូវបានចាត់ចែង និងគ្រប់គ្រងប្រកបដោយប្រសិទ្ធិភាព និងឆ្លើយតបទៅតាមផែនការអភិវឌ្ឍន៍ទេសចរណ៍។

Draft

<u>មាត្រា១២</u>៖ ក្រសួង ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធដែលការងាររបស់ខ្លួនប៉ះពាល់ទៅដល់ឧស្សាហកម្មទេសចរណ៍ និងផែនការអភិវឌ្ឍន៍ ត្រូវពិគ្រោះយោបល់ ផ្នែកជំនាញទេសចរណ៍ពីក្រសួងទេសចរណ៍។ ផ្នែកដែលប៉ះពាល់ទៅលើ ឬទទួលរងការប៉ះពាល់ដោយឧស្សាហកម្មទេសចរណ៍អាចរួមមាន៖

- ផែនការប្រើប្រាស់ដីធ្លី
- ផែនការរូបវន្ត និងផែនការអភិវឌ្ឍន៍
- ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មសាធារណៈ
- ការផ្តល់ឲ្យភាពជាម្ចាស់កម្មសិទ្ធ ភតិសន្យា ឬសម្រាប់គោលបំណងទេសចរណ៍
- ការកសាងគោលនយោបាយពន្ធដារ លើអាជីវកម្មទេសចរណ៍
- ទិដ្ឋាការ
- គោលនយោបាយអាកាសចរណ៍។

ដើម្បីធានាការអនុវត្តឲ្យមានប្រសិទ្ធភាព រាល់គម្រោងសាងសង់សំណង់បម្រើឲ្យសកម្មភាពងទេសចរណ៍ ត្រូវធ្វើឡើងឲ្យស្របតាមផែនការអភិវឌ្ឍន៍ទេសចរណ៍ និងត្រូវមានការជួយជាយោបល់ផ្នែកជំនាញទេសចរណ៍ពីក្រសួងទេសចរណ៍។

ក្រសួងទេសចរណ៍ ជួយផ្តល់ដំបូន្មានបច្ចេកទេស ទៅដល់គណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍រាជធានី ខេត្ត និងថ្នាក់មូលដ្ឋាន ក្រុមប្រឹក្សាភិបាលសិក្សាទីផ្សា និងផ្សព្វផ្សាយទេសចរណ៍កម្ពុជា សមាគមឧស្សាហកម្មទេសចរណ៍ និងប្រតិបត្តិករទេសចរណ៍។

<u>មាត្រា២២</u>៖ ក្រសួងទេសចរណ៍ត្រូវត្រួតពិនិត្យលើ ការចាត់ចែងរាល់អាជីវកម្ម និងសកម្មភាពទេសចរណ៍តាមរយៈការផ្តល់អាជ្ញាប័ណ្ណ ការបង្កើតប្រព័ន្ធចំណាត់ថ្នាក់កំណត់ស្តង់ដារ អប្បបរមា និងប្រព័ន្ធអនុវត្តនានាដើម្បីបង្កើត កែលម្អ និងរក្សាគុណភាពសេវាកម្មទេសចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

<u>មាត្រា២៣</u>៖ ក្រសួងទេសចរណ៍ត្រូវកំណត់ស្តង់ដារ និងការតម្រូវលើបញ្ហាបច្ចេកទេស សេវាកម្មទេសចរណ៍ឲ្យស្របទៅនឹងលក្ខខ័ណ្ឌអនុវត្តដ៏ប្រសើរបំផុត នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ អាជីវកម្មទេសចរណ៍ទាំងអស់ត្រូវអនុវត្តទៅតាមស្តង់ដារ និងការតម្រូវដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

<u>មាត្រា២៤</u>៖ ក្រសួងទេសចរណ៍ត្រូវរៀបចំបង្កើតប្រព័ន្ធចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ និងសេវាកម្មទេសចរណ៍ផ្សេងៗទៀត ស្របទៅតាមស្តង់ដារអន្តរជាតិ និងលក្ខខ័ណ្ឌអនុវត្តដ៏ប្រសើរបំផុតនៅក្នុងព្រះរាជាណាក្រកម្ពុជា។ ប្រព័ន្ធចំណាត់ថ្នាក់សម្រាប់សេវាកម្មទេសចរណ៍ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

មាត្រា២៨៖ ក្រោយពេលប្រព័ន្ធចំណាត់ថ្នាក់ត្រូវបង្កើតឡើង សម្រាប់សកម្មភាពអាជីវកម្មទេសចរណ៍ណាមួយនោះ អាជ្ញាប័ណ្ណទេសចរណ៍ដែលចេញក្រោមច្បាប់នេះ ត្រូវបញ្ជាក់ពីកម្រិតថ្នាក់របស់អាជីវកម្មនោះ។

មាត្រា៣៨៖ ក្រសួងទេសចរណ៍ ដោយមានការពិគ្រោះយោបល់ ជាមួយផ្នែកឯកជន ក្រសួងស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធត្រូវកំណត់ស្តង់ដារអប្បបរមា និងលក្ខណៈវិនិច្ឆ័យដទៃទៀត សម្រាប់ប្រភេទនីមួយៗនៃអាជ្ញាប័ណ្ណទេសចរណ៍ ដែលរៀបចំឡើងដើម្បីបង្កើតកែលម្អ និងរក្សាគុណភាពសេវាកម្មទេសចរណ៍។

លក្ខណៈវិនិច្ឆ័យទាំងនោះត្រូវស្របទៅតាមប្រភេទនីមួយៗ នៃអាជ្ញាប័ណ្ណទេសចរណ៍ និងត្រូវមានទំនាក់ទំនងជាមួយកម្មវត្ថុមួយចំនួន ឬទាំងអស់ក្នុងចំណោមកម្មវត្ថុទាំងឡាយ ដូចខាងក្រោម:

ក. សញ្ជាតិ គុណវុធ្ឍ បទពិសោធ ចំណេះដឹង និងអត្តចរិតរបស់ប្រតិបត្តិករ និងបុគ្គលិកសំខាន់ៗ។

ខ. ទីតាំង អគារ បរិក្ខារ ការចុះបញ្ជី និងសមត្ថភាពហិរញ្ញវត្ថុរបស់ប្រតិបត្តិករ។ លក្ខណៈវិនិច្ឆ័យសម្រាប់ប្រភេទនៃអាជ្ញាប័ណ្ណទេសចរណ៍នីមួយៗ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

មាត្រា៤៩៖ មន្ត្រីមានសមត្ថកិច្ចដែលពាក់ព័ន្ធ នឹងវិស័យទេសចរណ៍ ត្រូវមានកាតព្វកិច្ចដូចតទៅ៖

ក. ផ្តល់ដល់ទេសចរនូវព័ត៌មានឥតលាក់លៀម និងមិនលំអៀង។

ខ. ជួយយកអាសារដោយភាពស្មោះត្រង់ និងផ្តល់ភាពរាក់ទាក់ក្នុងនាមជាម្ចាស់ផ្ទះ។

គ. សម្រួលការធ្វើដំណើរដល់ទេសចរ សម្រួលកិច្ចការលិខិតស្នាម និងបែបបទនានាឲ្យសាមញ្ញ។

ឃ. មិនពើសអើងសញ្ជាតិ ពូជសាសន៍ ពណ៌សម្បុរ និងសាសនា។

ង. ចាត់វិធានការចាំបាច់ ដើម្បីការពារថែរក្សាទ្រព្យសម្បត្តិរបស់ទេសចរ និងរក្សាសន្តិសុខសុវត្ថិភាព។

ច. ប្រតិបត្តិស្របតាមក្រមសីលធម៌វិជ្ជាជីវៈ របស់អង្គការទេសចរណ៍ ពិភពលោកឲ្យបានល្អ។

មាត្រា៥០៖ ទេសចរណ៍ ឬអ្នកដំណើរកម្សាន្តត្រូវមានកាតព្វកិច្ចដូចតទៅ៖

- គោរពច្បាប់ និងបទបញ្ញត្តិជាធរមានរបស់ព្រះរាជាណាចក្រកម្ពុជា
- គោរពប្រពៃណី ទំនៀមទំលាប់ និងវប្បធម៌ខ្មែរ និងមិនត្រូវចូលរួមក្នុងសកម្មភាពណាមួយដែលបំពាន ឬធ្វើឲ្យខូចខាតដល់វប្បធម៌ខ្មែរ។
- មិនត្រូវធ្វើឲ្យខូចខាតដល់បរិស្ថាន ឬមរតកវប្បធម៌ និងមរតកធម្មជាតិ។

- មិនត្រូវចូលរួមក្នុងសកម្មភាពណាមួយ ដែលពាក់ព័ន្ធដល់ការជួញដូរ និងការប្រើប្រាស់គ្រឿងញៀន ការជួញដូរ និងការបង្ខាំងមនុស្ស ការជួញដូរកុមារ ការធ្វើអាជីវកម្មផ្លូវភេទ ការផ្សព្វផ្សាយរូបភាព និងសម្ភារៈអាសអាភាសន៍ ការលាងលុយកខ្វក់ និងការបង្កឲ្យមានអសន្តិសុខក្នុងសង្គម។
- មិនធ្វើឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សង្គម និងសុខុមាលភាពជាទូទៅ។
- មិនត្រូវគំរាមកំហែងដល់សន្តិសុខ ឬជាប់ពាក់ព័ន្ធដល់ក្រុមភេរវកម្ម។
- អនុវត្តឲ្យបានខ្ជាប់ខ្ជួននូវក្រមប្រតិបត្តិវិជ្ជាជីវៈ និងក្រមសីលធម៌វិជ្ជាជីវៈ ដែលចេញដោយក្រសួងទេសចរណ៍ ឬដែលបង្កើតឡើងដោយសមាគម ឧស្សាហកម្មទេសចរណ៍ ហើយយល់ព្រមដោយក្រសួងទេសចរណ៍។
- ប្រតិបត្តិស្របតាមក្រមសីលធម៌វិជ្ជាជីវៈ របស់អង្គការទេសចរណ៍ពិភពលោកឲ្យបានល្អ។
- ចំពោះទេសចរ ឬអ្នកធ្វើដំណើរកម្សាន្តជាជនបរទេស មិនត្រូវប្រើប្រាស់ទិសដៅទេសចរណ៍ ជាឱកាសដើម្បីស្វែងរកការងារ ឬការតាំងលំនៅដ្ឋាន។

<u>មាត្រា៨៦</u>៖ អនីតិជនមិនត្រូវបានអនុញ្ញាត ឲ្យចូលទៅកាន់ទីបរិវេណមណ្ឌលកំសាន្តទេសចរណ៍សម្រាប់មនុស្សពេញវ័យឡើយ។

<u>មាត្រា៨៧</u>៖ អ្នកគ្រប់គ្រង និងម្ចាស់អាជ្ញាប័ណ្ណនៃមណ្ឌលកម្សាន្តទេសចរណ៍សម្រាប់មនុស្សពេញវ័យត្រូវហាមឃាត់ និងចាត់វិធានការសមស្របដើម្បីធានាថា មិនមានវត្តមានអនីតិជននៅក្នុងទីបរិវេណនោះ និងត្រូវត្រួតពិនិត្យផ្ទៀងផ្ទាត់អត្តសញ្ញាណប័ណ្ណអតិថិជនវ័យក្មេងទាំងអស់ដើម្បីធានាឲ្យមានការប្រតិបត្តិតាមកាតព្វកិច្ចក្រោមមាត្រានេះ។

<u>មាត្រា៨៨</u>៖ ក្រសួងទេសចរណ៍ត្រូវដឹកនាំការងារអធិការកិច្ច៖

- បញ្ជូនមន្ត្រីចុះត្រួតពិនិត្យ ធ្វើអធិការកិច្ចលើទីកន្លែងប្រកបអាជីវកម្មលើទីបរិវេណ ឬសម្ភារៈដែលបានប្រើប្រាស់ ឬសង្ស័យថាបានប្រើប្រាស់សម្រាប់គោលបំណងអាជីវកម្មទេសចរណ៍ និងដែលបានប្រើប្រាស់ ឬដែលបានសង្ស័យថាបានប្រើប្រាស់ផ្ទុយនឹងច្បាប់។ ក្នុងការធ្វើអធិការកិច្ចក្រសួងទេសចរណ៍អាចសហការ និងសម្របសម្រួលជាមួយមន្ត្រីពីក្រសួងស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចផ្សេងៗទៀត។
- ប្រសិនបើទីបរិវេណប្រកបអាជីវកម្មនោះ ត្រូវបានប្រើប្រាស់ជាលំនៅដ្ឋានផងដែរ ការធ្វើអធិការកិច្ចអាចប្រព្រឹត្តទៅបានតែក្នុងអំឡុងម៉ោងអាជីវកម្មប៉ុណ្ណោះ។

<u>មាត្រា៨៩</u>៖ មន្ត្រីអធិការកិច្ចត្រូវបង្ហាញអត្តសញ្ញាណប័ណ្ណមុខងារ និងប័ណ្ណបេសកកម្ម ឬលិខិតអនុញ្ញាតឲ្យបំពេញបេសកកម្មមុនចាប់ផ្តើមធ្វើអធិការកិច្ច។ មន្ត្រីអធិការកិច្ចទេសចរណ៍ត្រូវមាននីតិសម្បទាជានគរបាលយុត្តិធម៌។

<u>មាត្រា៦០</u>៖ ម្ចាស់អាជ្ញាប័ណ្ណ ប្រតិបត្តិករទេសចរណ៍ និងបុគ្គលដែលកាន់កាប់ទីកន្លែង ប្រកបអាជីវកម្ម ទីបរិវេណ ឬសម្ភារៈបរិក្ខារជាកម្មវត្ថុនៃអធិការកិច្ច ត្រូវសហការជាមួយមន្ត្រីអធិការកិច្ចទេសចរណ៍ដោយផ្តល់ព័ត៌មានត្រឹមត្រូវពិតប្រាកដ គ្រប់គ្រាន់ និងការពន្យល់មកស្រាយរាល់ការចោទសួរណាមួយ ដើម្បីធានាឲ្យមន្ត្រីអធិការកិច្ច អាចអនុវត្តភារកិច្ចបាន។ គ្មានបុគ្គលណាម្នាក់អាចរារាំង បង្អាក់ ឬជ្រៀតជ្រែក ក្នុងការងារអធិការកិច្ចដែលមានចែងក្នុងច្បាប់នេះឡើយ។

<u>មាត្រា៦១</u>៖ ប្រសិនបើមន្ត្រីអធិការកិច្ចពិនិត្យឃើញថា មានការរំលោភបទបញ្ញត្តិនៃច្បាប់នេះ មន្ត្រីអធិការកិច្ចនោះអាចចាត់វិធានការតាមច្បាប់នេះ និងក្នុងករណីចាំបាច់ត្រូវស្នើរសុំឲ្យមានកិច្ចសហការពីសមត្ថកិច្ចពាក់ព័ន្ធ។ បើជាករណីធ្ងន់ធ្ងរ ត្រូវរាយការណ៍ជាបន្ទាន់ជូនក្រសួងទេសចរណ៍ដើម្បីចាត់វិធានការតាមច្បាប់។

ក្នុងករណីដែលពិនិត្យឃើញ ឬមានហេតុផលជាមូលដ្ឋានអាចជឿជាក់ថាមានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ មន្ត្រីអធិការកិច្ចនោះត្រូវរាយការណ៍ជាបន្ទាន់ជូនព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌មានសមត្ថកិច្ចនៃតំបន់ពាក់ព័ន្ធនោះ ដើម្បីចាត់វិធានការតាមនីតិវិធីនៃច្បាប់។

<u>មាត្រា៦៣</u>៖ ការពិន័យអន្តរការណ៍ ដែលកំណត់ដោយច្បាប់នេះ ត្រូវធ្វើដោយមន្ត្រីអធិការកិច្ចទេសចរណ៍ និង/ឬ នគរបាលទេសចរណ៍។ នីតិវិធី និងលក្ខខ័ណ្ឌក្នុងការពិន័យអន្តរការណ៍ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។
ការបែងចែកសមត្ថកិច្ចរវាងមន្ត្រីអធិការកិច្ចទេសចរណ៍ និងនគរបាលទេសចរណ៍ ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

<u>មាត្រា៦៤</u>៖ ការដាក់ពិន័យអន្តរការណ៍ មិនធ្វើឲ្យអ្នកប្រព្រឹត្តអំពើនោះរួចផុតពីការទទួលខុសត្រូវខាងរដ្ឋប្បវេណី និង/ឬ ការទទួលខុសត្រូវខាងព្រហ្មទណ្ឌ ដែលមានចែងដោយច្បាប់ និងបទបញ្ញត្តិជាធរមាន។

<u>មាត្រា៦៥</u>៖ បុគ្គលណាដែលប្រកបអាជីវកម្មទេសចរណ៍ ដោយគ្មានអាជ្ញាប័ណ្ណទេសចរណ៍ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ ដែលអប្បបរមាស្មើនឹង២.000.000(ពីរលាន) រៀល និងអតិបរមាមិនលើសពី២0.000.000(ម្ភៃលាន) រៀល។ ទំហំទឹកប្រាក់នៃការ ពិន័យអន្តរការណ៍សម្រាប់ប្រភេទអាជីវកម្មទេសចរណ៍នីមួយៗ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

<u>មាត្រា៦៦</u>៖ ការប្រព្រឹត្តិរំលោភលើកាតព្វកិច្ច ដូចមានចែងក្នុងមាត្រា៤៨ នៃច្បាប់នេះអាចជាកម្មវត្ថុនៃការពិន័យអន្តរការណ៍។ អំពើដែលជាកម្មវត្ថុ និងទំហំទឹកប្រាក់នៃការពិន័យអន្តរការណ៍នេះ ត្រូវកំណត់លំអិតដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

មាត្រា៦៧៖ មន្ត្រីមានសមត្ថកិច្ចដែលមិនគោរពតាមបទប្បញ្ញត្តិនៃច្បាប់នេះ ត្រូវទទួលទណ្ឌកម្មខាងរដ្ឋបាល ដោយមិនទាន់គិតពីទណ្ឌកម្មផ្សេងទៀត ស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមានឡើយ។

មាត្រា៦៨៖ ទេសចរ ឬអ្នកដំណើរកម្សាន្តដែលប្រព្រឹត្តល្មើសនឹងមាត្រា៥០ នៃច្បាប់នេះ អាចត្រូវបានលុបចោលទិដ្ឋាការទេសចរណ៍ ហើយបណ្តេញចេញ ឬហាមឃាត់វត្តមានក្នុងតំបន់គោលដៅទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជា ក្នុងរយៈពេលកំណត់ណាមួយដែលមិនលើសពី០៥ ឆ្នាំ ឬជាអចិន្ត្រៃយ៍។

មាត្រា៧១៖ ប្រតិបត្តិការទេសចរណ៍ដែលមិនអនុញ្ញាត ឬរារាំងមន្ត្រីអធិការកិច្ចទេសចរណ៍បំពេញការងាររបស់ខ្លួនដូចមានចែងក្នុងច្បាប់នេះ ត្រូវទទួលពិន័យអន្តរការណ៍ ជាប្រាក់ពី ១,០០០,០០០ (មួយលាន)រៀល ដល់ ១០,០០០,០០០(ដប់លាន)រៀល ដោយមិនទាន់គិតដល់វិធានការរដ្ឋបាលផ្សេងទៀត ក្នុងករណីមិនរាងចាលត្រូវពិន័យជាប្រាក់ទ្វេដង។

មាត្រា៧២៖ ជនណាដែលបង្កឲ្យមានការប្រព្រឹត្តល្មើស ឬការពារអាជីវកម្មទេសចរណ៍ដែលប្រព្រឹត្តរំលោភនឹងបទបញ្ញត្តិនៃច្បាប់នេះ ត្រូវប្រឈមនឹងទណ្ឌកម្មខាងរដ្ឋបាល ឬការទទួលខុសត្រូវខាងព្រហ្មទណ្ឌ និងសំណងរដ្ឋប្បវេណីដែលមានចែងដោយច្បាប់ និងបទបញ្ញត្តិជាធរមានផ្សេងទៀត។

មាត្រា៧៣៖ ជនណាដែលបន្ទំ ឬបោកបញ្ឆោតក្នុងការលក់ផលិតផល ឬសេវាកម្មទេសចរណ៍ក្លែងក្លាយដល់ភ្ញៀវ ត្រូវទទួលពិន័យអន្តរការណ៍ដែលមានចំនួនទ្វេដងនៃថ្លៃលក់ផលិតផលឬសេវាកម្មទេសចរណ៍។ ប្រសិនបើអំពើនោះបង្កើតជាបទល្មើសព្រហ្មទណ្ឌត្រូវផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាន។ ក្នុងករណីនេះ ក្រសួងទេសចរណ៍អាចលុបចោល ឬព្យួរ ឬបញ្ចុះថ្នាក់អាជ្ញាប័ណ្ណទេសចរណ៍មកជាអាជ្ញាប័ណ្ណបណ្តោះអាសន្ន។

៣.១២ អនុក្រឹត្យស្តីពីកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន (ឆ្នាំ ១៩៩៩)

អនុក្រឹត្យលេខ ៧២ អនក្រ.បក ស្តីពីកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន បានអនុម័តនៅ ថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៩ ដោយរាជរដ្ឋាភិបាលកម្ពុជា។

មាត្រា១៖ អនុក្រឹត្យនេះមានគោលបំណង៖

- កំណត់ការវាយតំលៃហេតុប៉ះពាល់បរិស្ថានលើរាល់គម្រោង និងសកម្មភាពរបស់ឯកជនឬសាធារណៈ ហើយត្រូវបានពិនិត្យ និងវាយតំលៃហេតុប៉ះពាល់បរិស្ថានលើរាល់គម្រោង និងសកម្មភាពរបស់ឯកជន ឬសាធារណៈ ហើយត្រូវបានពិនិត្យ និងវាយតំលៃដោយក្រសួងបរិស្ថានមុននឹងដាក់ជូនរដ្ឋាភិបាលសំរេច។
- កំណត់ប្រភេទ និងទំហំនៃគម្រោងសកម្មភាព ដែលបានស្នើឡើងព្រមទាំង

សកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការទាំងឯកជន ទាំងសាធារណៈ ដែលត្រូវវាយតំលៃហេតុប៉ះពាល់បរិស្ថាន។

- បំផុសឲ្យមានការចូលរួមពីសាធារណៈជនក្នុងកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ព្រមទាំងទទួលយកមតិយោបល់មកធ្វើការពិចារណាក្នុងកិច្ចដំណើរការអនុម័តគម្រោង។

<u>មាត្រា២</u>៖ អនុក្រឹត្យនេះមានវិសាលភាព អនុវត្តចំពោះគម្រោងដែលស្នើឡើង ព្រមទាំងសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការ ដែលជាបុគ្គលឯកជន ជាក្រុមហ៊ុនឯកជន ជាក្រុមហ៊ុនចំរុះរដ្ឋ ឬជាក្រុមហ៊ុនរដ្ឋ ជាក្រសួង-ស្ថាប័នរដ្ឋ លើកលែងតែគម្រោងដែលមានលក្ខណៈពិសេស និងចាំបាច់បន្ទាន់ ដែលសំរេចដោយរាជរដ្ឋាភិបាល។

<u>មាត្រា៣</u>៖ ក្រសួងបរិស្ថានមានភារៈកិច្ច៖

ក- ពិនិត្យ និងវាយតំលៃលើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ដោយសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ។

ខ- តាមដាន ឃ្លាំមើល និងចាត់វិធានការឲ្យម្ចាស់គម្រោងប្រតិបត្តិតាមផែនការគ្រប់គ្រងបរិស្ថានក្នុងដំណាក់កាលសាងសង់ ប្រតិបត្តិ និងបញ្ចប់គម្រោង ដូចមានចែងក្នុងរបាយការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ដែលបានអនុម័តរួច។

<u>មាត្រា៤</u>៖ ស្ថាប័ន និងក្រសួងដែលមានសិទ្ធអនុម័តលើគម្រោង មានភារៈកិច្ច ពិនិត្យ និងសំរេចលើគម្រោងដែលក្រសួងបរិស្ថានបានពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន។

<u>មាត្រា១១</u>៖ ម្ចាស់គម្រោងត្រូវបង់ថ្លៃសេវាការងារ សំរាប់ការពិនិត្យលើរបាយការណ៍ វាយតំលៃហេតុប៉ះពាល់បរិស្ថាន និងតាមដានឃ្លាំមើលការអនុវត្តគម្រោង។ តំលៃសេវាការងារនេះ ត្រូវកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើររបស់ក្រសួងបរិស្ថាន ដែលត្រូវបញ្ចូលក្នុងថវិកាជាតិ។

<u>មាត្រា១២</u>៖ ម្ចាស់គម្រោងត្រូវបង់វិភាគទាន ចូលក្នុងមូលនិធិទាយជួទានបរិស្ថាន សំរាប់កិច្ចការពារបរិស្ថាន ដូចមានចែងក្នុងមាត្រា១៩ នៃច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ។

<u>មាត្រា១៤</u>៖ ម្ចាស់គម្រោងត្រូវរៀបចំ និងបញ្ជូនរបាយការណ៍ ដូចមានចែងក្នុងមាត្រា ៧ ទៅក្រសួងបរិស្ថាន និងផ្តល់លិខិតចំលងទៅស្ថាប័នអនុម័តគម្រោង។

<u>មាត្រា១៥</u>៖ ក្រសួងបរិស្ថានត្រូវពិនិត្យរបាយការណ៍ ដូចមានចែងក្នុងមាត្រា ១៤ ព្រមទាំងចាត់បញ្ជូនយោបល់ និងសំណើរទៅម្ចាស់គម្រោង និងស្ថាប័នអនុម័តគម្រោងក្នុងរយៈពេល ៣០ ថ្ងៃ

Draft

គិតថ្ងៃធ្វើការ ចាប់ពីថ្ងៃដែលក្រសួងបានទទួលរបាយការណ៍សិក្សាបុរេលទ្ធភាព និងរបាយការវាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង ពីម្ចាស់គម្រោង។

<u>មាត្រា១៧</u>៖ ក្រសួងបរិស្ថានត្រូវពិនិត្យរបាយការណ៍ ដូចមានចែងក្នុងមាត្រា ១៦ ព្រមទាំងចាត់បញ្ជូនយោបល់ និងសំណើរទៅម្ចាស់គម្រោង និងស្ថាប័នអនុម័តគម្រោងក្នុងរយៈពេល ៣០ ថ្ងៃ គិតថ្ងៃធ្វើការ ចាប់ពីថ្ងៃដែលក្រសួងបានទទួលរបាយការណ៍សិក្សាបុរេលទ្ធភាព និងរបាយការវាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូងពីម្ចាស់គម្រោង។

<u>មាត្រា១៨</u>៖ ក្នុងករណីដែលក្រសួងបរិស្ថានខកខានមិនបានបញ្ជូនយោបល់ និងសំណើដូចមានចែងក្នុងមាត្រា ១៥ និងមាត្រា ១៧ នោះ ស្ថាប័នអនុម័តគម្រោងអាចកំណត់ថា គម្រោងនោះត្រូវបានបំពេញតាមតម្រូវការនៃអនុក្រឹត្យនេះ។

<u>មាត្រា១៩</u>៖ ក្នុងសមត្ថកិច្ចជាស្ថាប័នអនុម័តគម្រោងផង និងជាម្ចាស់គម្រោងផងនោះ ម្ចាស់គម្រោងត្រូវមានភារៈកិច្ចអនុវត្តតាមកិច្ចដំណើរការ ដូចដែលបានចែងខាងលើ។

<u>មាត្រា២០</u>៖ មុនចាប់ដំណើរការអនុវត្តគម្រោង ម្ចាស់គម្រោងត្រូវទទួលយោបល់ឯកភាពពីក្រសួងបរិស្ថាន លើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង ឬរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ។

<u>មាត្រា២៣</u>៖ ម្ចាស់កម្មសិទ្ធ ឬម្ចាស់ទទួលខុសត្រូវ ត្រូវអនុវត្តផែនការគ្រប់គ្រងបរិស្ថាន ដែលមានចែងក្នុងរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ក្នុងរយៈពេល ០៦ ខែ គិតចាប់តាំងពីថ្ងៃដែលក្រសួងបរិស្ថានបានចេញសេចក្ដីជូនដំណឹងថា របាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានបានបំពេញតាមតម្រូវការនៃអនុក្រឹត្យនេះ។

<u>មាត្រា២៧</u>៖ ស្ថាប័នអនុម័តគម្រោង ត្រូវណែនាំម្ចាស់គម្រោង ឬម្ចាស់កម្មសិទ្ធឲ្យអនុវត្តតាមផែនការគ្រប់គ្រងបរិស្ថាននៃគម្រោង ដូចបានរៀបចំក្នុងរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ដែលបានអនុម័តដោយក្រសួងបរិស្ថាន។

<u>មាត្រា២៨</u>៖ ក្រសួងបរិស្ថាន ត្រូវសហការជាមួយស្ថាប័នពាក់ព័ន្ធ ចេញបញ្ជាឲ្យផ្អាកសកម្មភាពចំពោះម្ចាស់គម្រោង ឬម្ចាស់កម្មសិទ្ធណា ដែលពុំបានអនុវត្តតាមផែនការគ្រប់គ្រងបរិស្ថាននៃគម្រោង ដូចបានចែងក្នុងរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដែលបានឯកភាពរួចហើយ។

<u>មាត្រា២៩</u>៖ ម្ចាស់គម្រោង ឬម្ចាស់កម្មសិទ្ធដែលខកខានមិនបានផ្ដល់ ឬបកស្រាយខុសនូវពត៌មាន ឬមិនបានអនុវត្តតាមផែនការគ្រប់គ្រងបរិស្ថាន ដូចបានពិពណ៌នានៅក្នុងរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ឬបំពាននឹងបទប្បញ្ញត្តិណាមួយ នៃអនិក្រឹត្យនេះ ត្រូវ

ផ្ត្ទន្ទាទោស ដូចមានចែងក្នុងមាត្រា ២០ ២១ ២២ ២៣ និង ២៥ នៃជំពូកទី ៩ នៃច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ។

<u>មាត្រា៣០</u>៖ កំណត់ហេតុ និងការធ្វើបណ្តឹងចំពោះជនទាំងឡាយណា ដែលបានប្រព្រឹត្តផ្ទុយ ឬពុំអនុវត្តតាមមាត្រាណាមួយនៃអនុក្រឹត្យនេះ គឺជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន។

៣.១៣ អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលទឹក (ឆ្នាំ១៩៩៩)

អនុក្រឹត្យលេខ ២៧ អនក្រ.បក ស្តីពីការត្រួតពិនិត្យការបំពុលទឹក បានអនុម័តនៅថ្ងៃទី០៦ ខែមេសា ឆ្នាំ១៩៩៩ ដោយរដ្ឋាភិបាលកម្ពុជា។ មាត្រានៃអនុក្រឹត្យនេះមានចែងដូចតទៅ ៖

<u>មាត្រា១</u>៖ អនុក្រឹត្យនេះមានគោលដៅ កំណត់ការត្រួតពិនិត្យការបំពុលទឹក ដើម្បីទប់ស្កាត់ និងកាត់បន្ថយការបំពុលទឹកនៅតាមតំបន់ទឹកសាធារណៈ សំដៅធានាបានការការពារសុខភាពមនុស្ស និងការអភិរក្សជីវៈចម្រុះ។

<u>មាត្រា៨</u>៖ ហាមឃាត់ជាដាច់ខាតនូវការចាក់ចោលសំរាម សំណល់រឹង ឬសារធាតុប្រកបដោយគ្រោះថ្នាក់ ទៅក្នុងតំបន់ទឹកសារធារណៈ ឬប្រព័ន្ធលូសាធារណៈ ដែលនាំឲ្យមានការបំពុលទឹកនៅតំបន់ទឹកសាធារណៈ។

<u>មាត្រា៩</u>៖ ហាមឃាត់ជាដាច់ខាតនូវការបង្ហូរទឹកលូចេញពីលំនៅស្តាន ឬពីអគារសាធារណៈ ចូលទៅក្នុងតំបន់ទឹកសាធារណៈ ដោយពុំឆ្លងកាត់ប្រព័ន្ធលូសាធារណៈ ឬប្រព័ន្ធច្រោះសំអាតនានា។

<u>មាត្រា១០</u>៖ ការបញ្ចេញចោល ឬការដឹកចេញនូវសំណល់រាវពីប្រភពបំពុលទៅកន្លែងដ៏ទៃ ក្នុងគោលបំណងណាមួយ ត្រូវសុំការអនុញ្ញាតពីក្រសួងបរិស្ថានជាមុនសិន និងត្រូវធ្វើសេចក្តីចំលងនៃពាក្យស្នើសុំនោះទៅក្រសួង និងស្ថាប័នពាក់ព័ន្ធ។

<u>មាត្រា១២</u>៖ ការសុំអនុញ្ញាតលើការបញ្ចេញសំណល់ ឬការដឹកសំណល់រាវចេញពីប្រភពបំពុលទៅកន្លែងដ៏ទៃ ដូចមានចែងនៅក្នុងមាត្រាទី ១០ នៃអនុក្រឹត្យនេះ នឹងត្រូវអនុវត្តទៅលើប្រភពបំពុលទាំងគម្រោងថ្មី និងទាំងគម្រោងកំពុងដំណើរការ លើកលែងតែគម្រោងប្រភពបំពុលថ្មី ដែលរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានរបស់គម្រោងនោះ ត្រូវបានអនុម័ត នឹងត្រូវបានរួចផុតពីការតំរូវឲ្យសុំការអនុញ្ញាត លើការបញ្ចេញចោលឬដឹកសំណល់រាវរបស់ខ្លួនទៅកន្លែងដ៏ទៃ។

<u>មាត្រា១៣</u>៖ ម្ចាស់កម្មសិទ្ធ ឬអ្នកទទួលខុសត្រូវប្រភពបំពុល ដូចមានចែងក្នុងមាត្រា១១ នៃអនុក្រឹត្យនេះ ដែលមានបំណងធ្វើការបញ្ចេញចោល ឬដឹកសំណល់រាវរបស់ខ្លួនទៅកាន់កន្លែងដ៏ទៃ ត្រូវដាក់សុំ ការអនុញ្ញាតមកក្រសួងបរិស្ថាន ៖

- អោយបានមុន ៤ ថ្ងៃ សំរាប់គម្រោងនៅភ្នំពេញ និង ៦០ ថ្ងៃសំរាប់គម្រោងនៅតាមខេត្តក្រុង នៃការចាប់ផ្តើមដំណើរការ សំរាប់ប្រភពបំពុលដែលជាគម្រោងថ្មី។

- អោយបានក្នុងរយៈពេល ៣០ ថ្ងៃ សំរាប់ប្រភពបំពុលនៅភ្នំពេញ និង ៥០ ថ្ងៃ សំរាប់គម្រោងនៅតាមខេត្តក្រុង ក្រោយពេលទទួលបានការណែនាំពីក្រសួងបរិស្ថាន សំរាប់ប្រភពបំពុលដែលកំពុងដំណើរការ។

<u>មាត្រា១៨</u>៖ លិខិតអនុញ្ញាតលើការបញ្ចេញចោល ឬដឹកសំណល់ចេញពីប្រភពបំពុលទៅកាន់កន្លែងដ៏ទៃ នឹងត្រូវបានផ្តល់ជូន ប្រសិនបើបែបបទនៃការសុំអនុញ្ញាតនោះ ត្រូវបានបំពេញទៅតាមគោលការណ៍ណែនាំបច្ចេកទេស ដែលកំណត់ដោយក្រសួងបរិស្ថាន។

<u>មាត្រា១៧</u>៖ លិខិតអនុញ្ញាតលើការបញ្ចេញចោល ឬដឹកសំណល់រាវចេញពីប្រភពបំពុល ដែលបានផ្តល់ជូនទៅឲ្យម្ចាស់កម្មសិទ្ធ ឬអ្នកទទួលខុសត្រូវប្រភពបំពុល នឹងត្រូវបានដកហូតជាបណ្តោះអាសន្ន ឬជាស្ថាពរ បន្ទាប់ពីមានការពិគ្រោះយោបល់ជាមុនជាមួយក្រសួង ឬស្ថាប័នពាក់ព័ន្ធ ប្រសិនបើម្ចាស់កម្មសិទ្ធ ឬអ្នកទទួលខុសត្រូវប្រភពបំពុលនោះ ប្រព្រឹត្តល្មើសធ្ងន់ធ្ងរទៅនឹងមាត្រាណាមួយនៃមាត្រា ១៤ និង១៥ ឬមាត្រា ១៦ នៃអនុក្រឹត្យនេះ។

<u>មាត្រា១៨</u>៖ ការត្រួតពិនិត្យនូវរាល់ការចាក់ចោល ឬការបង្ហូរចេញសំណល់រាវពីប្រភពបំពុល ជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន។

<u>មាត្រា១៩</u>៖ ក្រសួងបរិស្ថាន ត្រូវចុះយកគំរូតាងសំណល់រាវ នៅគ្រប់ចំណុចបញ្ចេញរបស់ប្រភពបំពុល។ ម្ចាស់កម្មសិទ្ធ ឬអ្នកទទួលខុសត្រូវប្រភពបំពុល ត្រូវចូលរួមសហការ និងបង្ករលក្ខណៈងាយស្រួលដល់មន្ត្រីបរិស្ថាន ដែលចុះយកគំរូតាង ដើម្បីបំពេញការងារតាមលក្ខណៈបច្ចេកទេស។

<u>មាត្រា២០</u>៖ ការវិភាគគំរូតាងសំណល់រាវ ដែលយកបានមកបីប្រភពបំពុលក្នុងពេលចុះត្រួតពិនិត្យ ឬធ្វើអធិការកិច្ច ត្រូវធ្វើនៅក្នុងមន្ទីរពិសោធន៍ក្រសួងបរិស្ថាន។

<u>មាត្រា២១</u>៖ ម្ចាស់កម្មសិទ្ធ ឬអ្នកទទួលខុសត្រូវប្រភពបំពុល ត្រូវបង់ថ្លៃវិភាគសំណល់រាវរបស់ខ្លួនតាមបញ្ជីចំនួនទឹកប្រាក់ ដែលបានកំណត់ជាមុនដោយក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ចំណូលនេះ ត្រូវបញ្ចូលទៅក្នុងថវិការជាតិ ដើម្បីផ្តល់ជូនទៅគណនីមូលនិធិទាយជ្ជទានបរិស្ថាន។

<u>មាត្រា២២</u>៖ ម្ចាស់កម្មសិទ្ធ ឬអ្នកទទួលខុសត្រូវប្រភពបំពុល អាចសុំធ្វើការវិភាគគំរូតាងសំណល់រាវរបស់ខ្លួន នៅតាមមន្ទីរពិសោធន៍រដ្ឋ ឬឯកជនដ៏ទៃទៀត ដែលមានការទទួលស្គាល់ជាផ្លូវការ ហើយដែលមន្ទីរពិសោធន៍នោះអនុវត្តវិធីសាស្ត្រវិភាគ ដូចដែលបានអនុវត្តនៅក្នុងមន្ទីរពិសោធន៍របស់ក្រសួងបរិស្ថាន។

<u>មាត្រា២៨</u>៖ កំរិតកំណត់ស្តង់ដារគុណភាពទឹកនៅតាមតំបន់ទឹកសាធារណៈ សំរាប់អភិរក្សជីវៈចម្រុះនៅក្នុងទឹក និងសំរាប់សុខភាពសាធារណៈមានចែងនៅក្នុងតារាងឧបសម្ព័ន្ធ៥ នៃអនុក្រឹត្យនេះ។

<u>តារាងឧបសម្ព័ន្ធ១</u>៖ ប្រភេទសារធាតុប្រកបដោយគ្រោះថ្នាក់

1. សមាសធាតុសរីរាង្គអាឡូសែន និងសារធាតុដែលអាចបង្កើតបានជាសមាសធាតុសរីរាង្គអាឡូសែនទាំងនោះនៅក្នុងបរិស្ថានទឹក
2. សមាសធាតុសរីរាង្គផូស្វរ
3. សមាសធាតុសរីរាង្គទីន
4. សារធាតុដែលបង្កឲ្យមានជម្ងឺមហារីក
5. បារ៉ត និង សមាសធាតុរបស់វា
6. កាត់ម្ហ៊ូម និង សមាសធាតុរបស់វា
7. សមាសធាតុប្រេងសរីរាង្គដែលមិនបំបែកធាតុ និង ពពួកអ៊ីដ្រូកាបូនៃសមាសធាតុប្រេងឆៅ
8. សមាសធាតុសំយោគដែលមិនបំបែកធាតុ ដែលអាចអណ្តែតលើផ្ទៃទឹក ឬលិចក្នុងទឹកហើយដែលអាចជ្រាបចូលទៅក្នុងការប្រើប្រាស់ទឹក
9. សារធាតុវិទ្យុសកម្ម
10. លោហៈ និងសមាសធាតុរបស់វាដូចជា:

សង្កសី (Zn)	សេលីនីយ៉ូម (Se)	សំណប៉ាហាំង (Sn)	វ៉ាណាដ្យ៉ូម (V)
ទង់ដែង (Cu)	អាសេនិច (As)	បារីយ៉ូម (Ba)	កូប៉ាល់ (Co)
នីកែល (Ni)	អង់ទីម៉ូនី (Sb)	បេរីលីយ៉ូម (Be)	តាល់ស្យ៉ូម (Tl)
ក្រូម (Cr)	ម៉ូលីបដែន (Mo)	បរ (Br)	តេលុយរីយ៉ូម (Te)
សំណ (Pb)	ទីតានីយ៉ូម (Ti)	អ៊ុយរ៉ាញ៉ូម (U)	ប្រាក់ (Ag)

11. សមាសធាតុសរីរាង្គពុលមិនបំបែកធាតុស៊ីលីស្យ៉ូម
12. សមាសធាតុអសរីរាង្គផូស្វរ
13. សមាសធាតុប្រេងជាសរីរាង្គមិនបំបែកធាតុ និងពពួកអ៊ីដ្រូកាបូនៃសមាសធាតុប្រេងឆៅ
14. សមាសធាតុ ស៊ីអានីត និង ភ្លុយអរ
15. សារធាតុដែលមានឥទ្ធិពលលើអុកស៊ីសែនដូចជា អាម៉ូញ៉ាក់ នីទ្រីត។ល។

Draft

<u>តារាងឧបសម្ព័ន្ធ២៖</u> កំរិតកំណត់ស្តង់ដារនៃការបញ្ចេញសំណល់រាវ ពីប្រភពចំពុលចូលទៅក្នុងតំបន់ទឹកសាធារណៈ ឬទៅក្នុងប្រព័ន្ធបណ្តាញលូ

ល.រ	ប៉ារ៉ាម៉ែត្រ	ខ្នាត	<u>បរិមាណសារធាតុចំពុលដែលអាចអនុញ្ញាតឱ្យបញ្ចេញ</u>	
			<u>តំបន់ទឹកសាធារណៈដែលត្រូវបានការពារ</u>	<u>តំបន់ទឹកសាធារណៈនឹងលូ</u>
1	សីតុណ្ហភាព	^0C	<45	<45
2	pH		6-9	5-9
3	BOD_5	mg/l	<30	<80
4	COD	mg/l	<50	<100
5	សារធាតុរឹងអណ្តែតក្នុងទឹក	mg/l	<60	<120
6	សារធាតុរឹងដែលរលាយក្នុងទឹក	mg/l	<1000	<2000
7	ប្រេង ឬខ្លាញ់	mg/l	<5.0	<15
8	សាប៊ូ	mg/l	<5.0	<15
9	ផេណុល	mg/l	<0.1	<1.2
10	នីត្រាត	mg/l	<10	<20
11	ក្លរក្នុងទំរង់សេរី	mg/l	<1.0	<2.0
12	ក្លរជាអ៊ីយ៉ុង	mg/l	<500	<700
13	ស៊ុលផាត	mg/l	<300	<500
14	ស៊ុលហ្វីត	mg/l	<0.2	<1.0
15	ផូស្វាត	mg/l	<0.3	<6.0
16	ស៊ីអានីត (CN^{-1})	mg/l	<0.2	<1.5
17	បារ៉ូម (Ba)	mg/l	<4.0	<7.0
18	អាសេនិច (As)	mg/l	<0.10	<1.0
19	សំណប៉ាហាំង (Sn)	mg/l	<2.0	<8.0
20	ដែក (Fe)	mg/l	<1.0	<20
21	បរ (B)	mg/l	<1.0	<5.0
22	ម៉ង់កាណែស (Mn)	mg/l	<1.0	<5.0
23	កាត់ម្ហ៊ូម (Cd)	mg/l	<0.1	<0.5

Draft

24	ក្រូម $(Cr)^{+3}$	mg/l	<0.2	<1.0
25	ក្រូម $(Cr)^{+6}$	mg/l	<0.05	<0.5
26	ទង់ដែង (Cu)	mg/l	<0.2	<1.0
27	សំណ (Pb)	mg/l	<0.1	<1.0
28	បារត (Hg)	mg/l	<0.002	<0.05
29	នីកែល (Ni)	mg/l	<0.2	<1.0
30	សេលេញ៉ូម (Se)	mg/l	<0.05	<0.5
31	ប្រាក់ (Ag)	mg/l	<0.1	<0.5
32	ស័ង្កសី (Zn)	mg/l	<1.0	<3.0
33	ម៉ូលីបដែន (Mo)	mg/l	<0.1	<1.0
34	អាម៉ូញាក់ (NH_3)	mg/l	<5.0	<7.0
35	អុកស៊ីសែនដែលរលាយក្នុងទឹក	mg/l	>2.0	>1.0
36	ប៉ូលីក្លរ៉ូ ប៊ីផេនីល (PCB)	mg/l	<0.003	<0.003
37	កាល់ស្យូម (Ca)	mg/l	<150	<200
38	ម៉ាញ៉េស្យូម (Mg)	mg/l	<150	<200
39	កាបូនតេត្រាក្លរ	mg/l	<3	<3
40	អ៊ីចសាក្លរបង់សែន	mg/l	<2	<2
41	ដេដេតេ	mg/l	<1,3	<1,3
42	អង់ត្រ៊ីន	mg/l	<0,01	<0,01
43	ឌីអលត្រ៊ីន	mg/l	<0,01	<0,01
44	អេនត្រ៊ីន	mg/l	<0,01	<0,01
45	អ៊ីសូត្រ៊ីន	mg/l	<0,01	<0,01
46	ពែក្លរអេទីឡែន	mg/l	<2,5	<2,5
47	អ៊ីចសាក្លរប៊ីយតាឌីអែន	mg/l	<3	<3
48	ក្លរហ្វូម	mg/l	<1	<1
49	1,2 ឌីក្លរអេទីឡែន	mg/l	<2,5	<2,5
50	ទ្រីក្លអេទីឡែន	mg/l	<1	<1

Draft

51	ទ្រីក្លរបង់សែន	mg/l	<2	<2
52	អ៊ីចសាក្លរស៊ីក្លអ៊ីចសែន	mg/l	<2	<2

<u>កំណត់សំគាល់</u> ៖ ក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវសហការរៀបចំកំរិតកំណត់ស្តង់ដារថ្នាំពុលកលិកម្ម ដែលបញ្ចេញពីប្រភពបំពុល។

<u>តារាងខ្ចប្រសម្ព័ន្ធ៣</u>ៈ <u>កម្រិតស្តង់ដារគុណភាពទឹកនៅតាមតំបន់ទឹកសាធារណៈ សម្រាប់អនុវត្ត</u>ជីវៈចម្រុះនៅក្នុងទឹក

1- <u>សម្រាប់ទន្លេ</u>

<u>ល.រ</u>	<u>ប៉ារ៉ាម៉ែត្រ</u>	<u>ខ្នាត</u>	<u>កម្រិតស្តង់ដារ</u>
1	pH		6,5-8,5
2	BOD_5	mg/l	1-10
3	សារធាតុរឹងអណ្តែតក្នុងទឹក (SS)	mg/l	25-100
4	កម្រិតរលាយអុកស៊ីសែន (DO)	mg/l	7,5-2,0
5	កូលីហ្វម (Coliform)	MPN/100ml	<5000

2- <u>សម្រាប់បឹង និងអាងស្តុកទឹក</u>

<u>ល.រ</u>	<u>ប៉ារ៉ាម៉ែត្រ</u>	<u>ខ្នាត</u>	<u>កម្រិតស្តង់ដារ</u>
1	pH		6,5-8,5
2	COD	mg/l	1-8
3	សារធាតុសរីរាង្គអណ្តែតក្នុងទឹក(SS)	mg/l	1-15
4	កម្រិតរលាយអុកស៊ីសែន (DO)	mg/l	7,5-2,0
5	កូលីហ្វម (Coliform)	MPN/100ml	<1000
6	អាសូតសរុប (Total Nitrogen)	mg/l	0,1-0,6
7	ផូស្វរសរុប (Total Phosphorus)	mg/l	0,005-0,05

3- <u>សម្រាប់ទឹកសមុទ្រ</u>

<u>ល.រ</u>	<u>ប៉ារ៉ាម៉ែត្រ</u>	<u>ខ្នាត</u>	<u>កម្រិតស្តង់ដារ</u>
1	pH		7,0-8,3
2	COD	mg/l	2-8
3	កម្រិតរលាយអុកស៊ីសែន (DO)	mg/l	7,5-2,0
4	កូលីហ្វម (Coliform)	MPN/100ml	<1000
5	សមាសធាតុប្រេង (Oil Content)	mg/l	0

Draft

6	អាសូតសរុប (Total Nitrogen)	mg/l	0,2-1,0
7	ផូស្វរសរុប (Total Phosphorus)	mg/l	0,02-0,09

៣.១៤ អនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់រឹង (ឆ្នាំ១៩៩៩)

អនុក្រឹត្យលេខ ៣៦អនក្រ.បក ស្តីពីការគ្រប់គ្រងសំណល់រឹងបានអនុម័តនៅថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៩ ដោយរាជរដ្ឋាភិបាលកម្ពុជា។ មាត្រានៃអនុក្រឹត្យនេះមាន៖

- មានគោលដៅកំណត់ការគ្រប់គ្រងសំណល់រឹងប្រកបដោយលក្ខណៈបច្ចេកទេសសមស្រប និងប្រកបដោយសុវត្ថិភាព សំដៅធានាបាននូវការការពារសុខភាពសាធារណៈ គុណភាពបរិស្ថាន និងការអភិរក្សជីវៈចម្រុះ។
- មានវិសាលភាពអនុវត្តចំពោះរាល់សកម្មភាពបោះចោល ទុកដាក់ ស្តុក ប្រមូលដឹកជញ្ជូន កែច្នៃ និងបញ្ចេញចោលសំរាម និងសំណល់ប្រកបដោយគ្រោះថ្នាក់។
- មានភ្ជាប់ជាមួយនូវឧបសម្ព័ន្ធ ដែលកំណត់នូវប្រភេទសំណល់ប្រកបដោយគ្រោះថ្នាក់។

<u>មាត្រា១</u>៖ មានគោលដៅកំណត់ការគ្រប់គ្រងសំណល់រឹង ប្រកបដោយលក្ខណៈបច្ចេកទេសសមស្រប និងប្រកបដោយសុវត្ថិភាព សំដៅធានាបាននូវការការពារសុខភាពសាធារណៈ គុណភាពបរិស្ថាន និងការអភិរក្សជីវៈចម្រុះ ។

<u>មាត្រា២</u>៖ អនុក្រឹត្យនេះមានវិសាលភាពអនុវត្ត ចំពោះរាល់សកម្មភាពបោះចោល ទុកដាក់ ស្តុក ប្រមូល ដឹកជញ្ជូន កែច្នៃ និងបញ្ចេញចោលសំរាម និងសំណល់ប្រកបដោយគ្រោះថ្នាក់។

<u>មាត្រា៧</u>៖ ហាមឃាត់ជាដាច់ខាត ការបោះចោលសំរាមនៅទីសាធារណៈ ឬការចោលសំរាមខុសទីកន្លែង ដែលកំណត់ដោយអជ្ញាធរមានសមត្ថកិច្ច។

<u>មាត្រា១៣</u>៖ ម្ចាស់សំណល់ ត្រូវទទួលខុសត្រូវក្នុងការទុកដាក់ ឬស្តុកទុកជាបណ្តោះអាសន្ននូវសំណល់ប្រកបដោយគ្រោះថ្នាក់របស់ខ្លួន តាមលក្ខណៈបច្ចេកទេសសមស្រប និងមានសុវត្ថិភាព។

<u>មាត្រា១៤</u>៖ ម្ចាស់សំណល់ ត្រូវធ្វើនិងផ្ញើរៀងរាល់បីខែម្តងទៅក្រសួងបរិស្ថាន នូវរបាយការណ៍ដែលទាក់ទងនឹងសំណល់ប្រកបដោយគ្រោះថ្នាក់នៅក្នុងមូលដ្ឋានរបស់ខ្លួន រួមមាន៖

ក-ប្រភេទ និងបរិមាណសំណល់

ខ-វិធីសាស្ត្រក្នុងការទុកដាក់ ឬស្តុកទុកជាបណ្តោះអាសន្ន

គ-វិធីសាស្ត្រក្នុងការសំអាតសំណល់ ឬបំបាត់សំណល់។

<u>មាត្រា១៥</u>៖ ការទុកដាក់ ស្តុក ដឹកជញ្ជូន និងការបោះចោល ឬចាក់ចោលសំណល់ប្រកបដោយគ្រោះថ្នាក់ ត្រូវអនុវត្តដាច់ដោយឡែកពីសំរាមធម្មតា ដែលនឹងមានចែងនៅក្នុងប្រកាសរបស់ក្រសួងបរិស្ថាន។

Draft

ហាមឃាត់ជាដាច់ខាត ការបោះចោល ឬការចាក់ចោលសំណល់ប្រកបដោយគ្រោះថ្នាក់នៅតាមទីសាធារណៈ ប្រព័ន្ធលូសាធារណៈ ប្រភពឬបណ្តាញផ្លូវទឹក តំបន់ជនបទ និងតំបន់ព្រៃភ្នំ។

ឧបសម្ព័ន្ធ៖ ប្រភេទសំណល់ប្រកបដោយគ្រោះថ្នាក់

1. សំណល់សរសៃអំបោះ និងកំទេចកំណាត់ដែលមានពណ៌ (ក្នុងករណីយកទៅដុត)
2. សំណល់កំទេចក្រដាស ដែលសល់ពីការផលិតម្សៅក្រដាស
3. សំណល់ភក់ ដែលបង្កើតឡើងដោយរោងចក្រប្រព្រឹត្តិកម្មសម្អាតសំណល់រាវ និងទឹកលូ
4. សំណល់ដែលសល់ពីការឆេះមិនអស់នៅក្នុងឡឧស្សាហកម្ម
5. សំណល់ផ្លាស្ទិក "ប៉ូលីវីនីលក្លរ"
6. សំណល់សារធាតុជ័រប៉ូលីវីក្លរីណេតទីបប៊ីផេនីល (PCB) នៃម៉ាស៊ីនត្រជាក់ ទូរទស្សន៍ វិទ្យុ ម៉ាញ៉ូ ។ល។
7. សំណល់ជ័រ និងកៅស៊ូដែលមានសារធាតុប៉ូលីមែរប៊ីយ៉ូទីលីន
8. សំណល់ប្រេងឥន្ធនៈ និងប្រេងម៉ាស៊ីន
9. សំណល់ដែលមានផ្ទុកជាតិអាស៊ីត
10. សំណល់ដែលមានផ្ទុកជាតិបាស
11. សំណល់លោហៈ និងសមាសធាតុរបស់វា រួមមាន:

សង្កសី (ZN)	សេនីលីញ៉ូម (Se)	សំណប៉ាហាំង (Sn)	វ៉ាណាដ្យ៉ូម (V)
ទង់ដែង (Cu)	អាសេនិច (As)	ប៉ារីយ៉ូម (Ba)	កូប៉ាល់ (Co)
នីកែល (Ni)	អង់ទីម៉ូនី (Sb)	បេរីលីយ៉ូម (Be)	តាលយ៉ូម (Tl)
ក្រូម (Cr)	ម៉ូលីបដែន (Mo)	បរ (B)	តេលុយរីយ៉ូម (Te)
សំណ (Pb)	ទីតានីញ៉ូម (Ti)	អ៊ុយរ៉ានីញ៉ូម (U)	ប្រាក់ (Ag)
បារត (Hg)	កាត់ម៉ូម (Cd)	ដែក (Fe)	

12. លំអងផ្សែង និងធូលីដែលកើតមានក្នុងករណីសម្អាតផ្សែងបញ្ចេញពីមូលដ្ឋានផលិតកម្ម
13. សំណល់អំពូលអគ្គីសនី និងបន្ទះគ្រឿងអេឡិចត្រូនិចអគ្គិសនី
14. សំណល់អាគុយ និងថ្មពិល
15. សំណល់ថ្នាំលាប និង ថ្នាំជ្រលក់ពណ៌ និងសម្ភារៈវិចខ្ចប់ថ្នាំពណ៌
16. សំណល់បានមកពីការផលិត និងការប្រើប្រាស់ទឹកថ្នាំបោះពុម្ព
17. សំណល់គ្រឿងផ្ទុះ
18. សំណល់ដែលនាំឲ្យមានការចម្លងមេរោគ ឬជម្ងឺ
19. សំណល់ដែលសល់ពីការផលិតថ្នាំពុលកសិកម្ម និងសម្ភារៈវិចខ្ចប់
20. សំណល់ផេះនៃឡដុតសំរាម សំណល់រឹង និងសំណល់ប្រកបដោយគ្រោះថ្នាក់
21. ផលិតផលដែលមិនឆ្លើយតបទៅនឹងបទដ្ឋាននានា និងហួសកំណត់

Draft

22. សំណល់ហ្វីល ដូចជាហ្វីលភាពយន្ត វីដេអូ ហ្វីលកាសែតចំរៀង ហ្វីលថតរូប និងហ្វីលថតសរីរាង្គមនុស្សតាមមន្ទីរពេទ្យ
23. សំណល់ដែលបានពីក្រោយពេលធ្វើប្រព្រឹត្តកម្មសម្អាតដីកខ្វក់ ឬដីខូចគុណភាព
24. សំណល់ដែលបានមកពីការផលិតឱសថ និងឱសថដែលខូចគុណភាព
25. សំណល់ដែលជាសមាសធាតុភ្លុយអរីន
26. សំណល់ដែលជាសមាសធាតុស៊ីអានីត
27. សំណល់ដែលជាសមាសធាតុ អាសបេតូស
28. សំណល់ដែលជាសមាសធាតុផេណុល (C_6H_5OH)
29. សំណល់ដែលជាសមាសធាតុ អេទែ ($R\text{-}COO\text{-}R_1$)
30. សំណល់ដែលសារធាតុសរីរាង្គរំលាយដែលមានអាឡូសែន និងគ្មានអាឡូសែន
31. សំណល់ដែលជាសមាសធាតុ ឌីអុកស៊ីសែន និងហ្វូរ៉ាន
32. សំណល់ធាតុវិទ្យុសកម្ម
33. សំណល់ដែលជាផលិតផលបានមកពីការធ្វើប្រព្រឹត្តិកម្មសម្អាតសំណល់ ដែលមានចែងពីចំនុចទី1 ដល់ចំនុចទី 32។

៣.១៥ អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់និងការរំខានដោយសម្លេង (២000)

អនុក្រឹត្យលេខ ៤២អនក្រ.បក ស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសម្លេង ត្រូវបានអនុម័តនៅថ្ងៃទី ១0 ខែកក្កដា ឆ្នាំ២000 ដោយរាជរដ្ឋាភិបាលកម្ពុជា។ អនុក្រឹត្យនេះគោលដៅ៖

<u>មាត្រា១</u>៖ កំណត់ការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសម្លេង ដើម្បីទប់ស្កាត់និងកាត់បន្ថយសារធាតុដែលបំពុលខ្យល់ និងសម្លេងក្នុងបរិយាកាស សំដៅការពារគុណភាពបរិស្ថាន និងសុខភាពសាធារណៈ។

<u>មាត្រា២</u>៖ មានវិសាលភាពអនុវត្តនិងចាត់វិធានការចំពោះរាល់ប្រភពបំពុលចល័ត និងអចល័ត ទាំងឡាយណាដែលបង្កឲ្យមានការបំពុលខ្យល់ និងការរំខានដោយសម្លេងនៅក្នុងបរិយាកាស។

<u>មាត្រា៤</u>៖ កំរិតកំណត់ស្តង់ដារគុណភាពខ្យល់ មានចែងនៅក្នុងឧបសម្ព័ន្ធ ១ និងកំរិតកំណត់ស្តង់ដារអតិបរមានៃសារធាតុប្រកបដោយគ្រោះថ្នាក់ ដែលអនុញ្ញាតឲ្យមាននៅក្នុងខ្យល់ មានបែងចែកនៅក្នុងឧបសម្ព័ន្ធ ២។

<u>មាត្រា៥</u>៖ កំរិតកំណត់ស្តង់ដារអតិបរមានៃសារធាតុបំពុល ដែលអនុញ្ញាតឲ្យបញ្ចេញពីប្រភពអចល័តចូលទៅក្នុងបរិយាកាស មានចែងនៅក្នុងឧបសម្ព័ន្ធ៣ និងកំរិតកំណត់ស្តង់ដារនៃការបញ្ចេញឧស្ម័នពីប្រភពចល័ត មានចែងនៅក្នុងតារាងឧបសម្ព័ន្ធ៤។

Draft

<u>មាត្រា៦</u>៖ ក្នុងករណីចាំបាច់ កំរិតកំណត់ស្តង់ដារដូចមានចែងក្នុងមាត្រា៤ និងមាត្រា៥ នៃអនុក្រឹត្យ និងត្រូវពិនិត្យកែសំរួលរៀងរាល់ ៥ឆ្នាំម្តងតាមសំណើររបស់ក្រសួងបរិស្ថាន។

<u>មាត្រា៧</u>៖ កំរិតកំណត់ស្តង់ដារបញ្ចេញសំលេងពីប្រភពយានយន្ត ទីតាំងផលិតកម្ម និងកំរិតកំណត់ ស្តង់ដារសំលេងអតិបរមាសំរាប់ទីកន្លែងសាធារណៈ និងតំបន់លំនៅដ្ឋាន មានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ៥ ៦ និង ៧។

<u>មាត្រា៨</u>៖ ហាមឃាត់ដាច់ខាតនូវការបញ្ចេញសារធាតុពុលចូលទៅក្នុងបរិយាកាស ដែលមិនឆ្លើយតបទៅនឹងកំរិតកំណត់ស្តង់ដារ ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធ៣ និងឧបសម្ព័ន្ធ៤។

<u>មាត្រា៩</u>៖ ហាមឃាត់ដាច់ខាតនូវការបញ្ចេញសម្លេង ដែលមិនឆ្លើយតបទៅនឹងកំរិតកំណត់ស្តង់ដារ ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធ៥ ឧបសម្ព័ន្ធ៦ និងឧបសម្ព័ន្ធ៧។

<u>មាត្រា១០</u>៖ ការនាំចូល និងផលិតនូវសារធាតុឆេះ ដែលមានជាតិស្ពាន់ធ័រ សំណ បង់សែន និងសារធាតុអ៊ីដ្រូកាប៊ូប្រហើរ ត្រូវឆ្លើយតបទៅនឹងកំរិតកំណត់ស្តង់ដារដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ៨ ។

<u>មាត្រា១១</u>៖ ហាមឃាត់ដាច់ខាតនូវការនាំចូល ប្រើប្រាស់ ផលិតយានយន្ត និងគ្រឿងយន្តគ្រប់ប្រភេទនៅប្រទេសកម្ពុជា ដែលយានយន្ត និងគ្រឿងយន្តទាំងនោះបានបញ្ចេញសារធាតុបំពុល និងសំលេងមិនឆ្លើយតបទៅនឹងកំរិតស្តង់ដារដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ៤ និង ៥ ។

<u>មាត្រា១២</u>៖ ហាមដាច់ខាតការបង្ហូរ ឬការធ្វើអោយលេចធ្លាយសារធាតុឆេះ ប្រេងឥន្ធនៈ ធាតុវិទ្យុសកម្ម ឬសារធាតុគីមីផ្សេងៗទៀតចូលក្នុងបរិយាកាស ទឹក និងដី។

<u>មាត្រា១៣</u>៖ ការបញ្ចេញសារធាតុបំពុល និងសំលេងចូលទៅក្នុងបរិយាកាសពីប្រភពអចល័ត ត្រូវសុំការអនុញ្ញាតពីក្រសួងបរិស្ថាន និងត្រូវផ្ញើសេចក្តីចំលងនៃពាក្យសុំនោះទៅក្រសួងនិងស្ថាប័នពាក់ព័ន្ធ។

<u>មាត្រា១៤</u>៖ ការសុំអនុញ្ញាតនាំចូលនូវសារធាតុឆេះ ត្រូវមានភ្ជាប់នូវលទ្ធផលវិភាគ ដែលបញ្ជាក់ពីបរិមាណជាតិពុលស្ពាន់ធ័រ សំណ បង់សែន ឬអ៊ីដ្រូកាប៊ូប្រហើរពីប្រភេទដើម នៃការនាំចូល និងការផលិត។

<u>មាត្រា១៥</u>៖ ការសុំអនុញ្ញាតលើការបញ្ចេញសារធាតុបំពុល និងសំលេងមានដូចចែងនៅក្នុងមាត្រាទី១៣ នៃអនុក្រឹត្យនេះ នឹងត្រូវអនុវត្តទៅលើប្រភពបំពុលទាំងគម្រោងថ្មី និងសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការ លើកលែងតែគម្រោងដែលមានរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានរួចហើយ។

Draft

មាត្រា១៦៖ ម្ចាស់កម្មសិទ្ធ ឬម្ចាស់ទទួលខុសត្រូវប្រភពបំពុលដូចមានចែងក្នុងមាត្រា១៣ នៃអនុក្រឹត្យនេះ ត្រូវដាក់ពាក្យសុំការអនុញ្ញាតមកក្រសួងបរិស្ថាន៖

- អោយបានមុន ៤០ថ្ងៃ នៃការចាប់ផ្តើមដំណើរការ សំរាប់គម្រោងនៅភ្នំពេញ។
- អោយបានមុន ៦០ថ្ងៃ នៃការចាប់ផ្តើមដំណើរការ សំរាប់គម្រោងនៅតាមខេត្ត-ក្រុង

មាត្រា១៧៖ ការត្រួតពិនិត្យនូវបរិមាណជាតិពុលក្នុងសារធាតុឆេះ ការបញ្ចេញសារធាតុបំពុលខ្យល់ និងសំលេងពីប្រភពអចល័ត ជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន។

មាត្រា១៨៖ ការត្រួតពិនិត្យនៃការបញ្ចេញឧស្ម័ន និងសំលេងពីប្រភពចល័តជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន ដោយមានកិច្ចសហការពីក្រសួង និងស្ថាប័នពាក់ព័ន្ធ។ ចំពោះនីតិវិធីក្នុងការត្រួតពិនិត្យនេះ ត្រូវកំណត់ដោយប្រកាសរួមរបស់អន្តរក្រសួង។

មាត្រា១៩៖ ក្រសួងបរិស្ថានត្រូវរៀបចំគោលការណ៍ណែនាំបច្ចេកទេស ស្តីពីវិធីសាស្ត្រត្រួតពិនិត្យប្រភពបំពុល វិធីសាស្ត្រកំណត់ទីតាំងយកគំរូតាង និងវិធីសាស្ត្រវិភាគគុណភាពខ្យល់ និងសំលេង។

មាត្រា២០៖ ក្រសួងបរិស្ថានត្រូវចុះយកគំរូតាង នៅគ្រប់ចំណុចបញ្ចេញរបស់ប្រភពបំពុល។ ម្ចាស់កម្មសិទ្ធ ឬម្ចាស់ទទួលខុសត្រូវប្រភពបំពុលត្រូវចូលរួមសហការ និងបង្ករលក្ខណៈងាយស្រួលដល់មន្ត្រីបរិស្ថាន ដែលចុះយកគំរូតាង ដើម្បីបំពេញការងារតាមលក្ខណៈបច្ចេកទេស។

មាត្រា២១៖ ក្រសួងបរិស្ថានត្រូវធ្វើការត្រួតពិនិត្យតាមដានជាប្រចាំពីស្ថានភាព និងគុណភាពខ្យល់នៅទូទាំងប្រទេសកម្ពុជាដើម្បីមានវិធានការទប់ស្កាត់ និងកាត់បន្ថយការបំពុលខ្យល់បានទាន់ពេលវេលា។

មាត្រា២២៖ ក្រសួងបរិស្ថានត្រូវគ្រប់គ្រងទិន្នន័យលទ្ធផលវិភាគគុណភាព និងវាយតំលៃពីស្ថានភាពគុណភាពខ្យល់ ព្រមទាំងធ្វើការផ្សព្វផ្សាយជាសាធារណៈ ពីស្ថានភាពគុណភាព និងការបំពុលខ្យល់នៅទូទាំងប្រទេសកម្ពុជា។

មាត្រា២៣៖ ក្នុងករណីរកឃើញថាតំបន់ណាមួយត្រូវទទួលរងការបំពុលខ្យល់ ដែលបង្ករអោយមានការគំរាមកំហែងដល់អាយុជីវិតសាធារណៈ ឬគុណភាពបរិស្ថាន ក្រសួងបរិស្ថានត្រូវធ្វើការផ្សព្វផ្សាយ ជាសាធារណៈជាបន្ទាន់ពីបញ្ហាគ្រោះថ្នាក់ និងត្រូវស្នើបអង្កេតរកប្រភពដែលបង្កឲ្យមានការបំពុល ព្រមទាំងចាត់វិធានការទប់ស្កាត់ប្រភពបំពុលទាំងនោះ ដើម្បីស្តារនូវគុណភាពខ្យល់អោយបានប្រសើរឡើងវិញ។

Draft

តារាងខ្ទបសម្ព័ន្ធ១៖ កម្រិតស្តង់ដារគុណភាពខ្យល់

ល.រ	ប៉ារ៉ាម៉ែត្រ	រយៈពេល៨ម៉ោង ជាមធ្យម mg/m^3	រយៈពេល៨ម៉ោង ជាមធ្យមmg/m^3	រយៈពេល២៤ម៉ោង ជាមធ្យម mg/m^3	រយៈពេល១ឆ្នាំ ជាមធ្យម mg/m^3
1	កាបូនម៉ូណូអុកស៊ីតCO	40	20		
2	អាសូតឌីអុកស៊ីត NO_2	0,3		0,10	
3	ស្ពាន់ធ័រឌីអុកស៊ីត SO_2	0,5		0,30	0,10
4	អូសូន O_3	0,2			
5	សំណ Pb			0,005	
6	សារធាតុរឹងអណ្តែតក្នុងខ្យល់ TSP			0,33	0,10

កំណត់សម្គាល់៖

- កម្រិតស្តង់ដារនេះអនុវត្តសម្រាប់ធ្វើការវាយតម្លៃគុណភាពខ្យល់ទូទៅ និងអង្កេតតាមដានស្ថានភាពនៃការបំពុលខ្យល់។
- វិធីសាស្ត្រនៃការវិភាគគុណភាពខ្យល់ត្រូវកំណត់តាមគោលការណ៍ណែនាំរបស់ក្រសួងបរិស្ថាន។
- TSP – Total Suspended Particulate

តារាងខ្ទបសម្ព័ន្ធ២៖កំរិតកំណត់ស្តង់ដារសំលេងអតិបរមា ដែលអនុញ្ញាតនៅតំបន់សាធារណៈ និងតំបន់លំនៅដ្ឋាន (dB(A))

ល.រ	ទីតាំង	អំឡុងពេល		
		ពីម៉ោង ៦ព្រឹកដល់ម៉ោង១៨ល្ងាច	ពីម៉ោង ១៨ល្ងាចដល់ម៉ោង ២២យប់	ពីម៉ោង ២២យប់ដល់ម៉ោង ៦ព្រឹក
1	តំបន់ស្ងប់ស្ងៀម - មន្ទីរពេទ្យ បណ្ណាល័យ សាលារៀន មតេយ្យសាលា តំបន់លំនៅដ្ឋាន - សណ្ឋាគារ ទីកន្លែងរដ្ឋបាល	45	40	35
2	- ភូមិគ្រឹះ ផ្ទះល្វែង តំបន់ពាណិជ្ជកម្ម សេវាកម្ម	60	50	45

Draft

	និងចម្រុះ			
3	ឧស្សាហកម្មធន់ស្រាល លាយ	70	65	50
4	ចម្រុះ នៅក្នុងតំបន់លំនៅដ្ឋាន	75	70	50

កំណត់សំគាល់ៈកំរិតកំណត់ស្តង់ដារនេះអនុវត្តសំរាប់ការត្រួតពិនិត្យកំរិតសំលេងពីប្រភព ឬសកម្ម ភាពណាមួយ ដែលបញ្ចេញសំលេងចូលក្នុងតំបន់សាធារណៈ និងតំបន់លំនៅដ្ឋាន។

តារាងខ្ទបសម្ព័ន្ធ៧ៈ **កម្រិតស្តង់ដារសម្រាប់ត្រួតពិនិត្យសម្លេង ក្នុងទីតាំង រោងជាង រោងចក្រឧស្សាហកម្ម**

កម្រិតសម្លេង(dB (A))	រយៈពេលអតិបរមា(ម៉ោង)	កំណត់បង្ហាញ
75	32	ត្រូវផ្តល់ឧបករណ៍ការពារត្រចៀកដល់អ្នកបម្រើការដែលធ្វើការនៅកន្លែងមានសម្លេងលើសពី 80dB (A)
80	16	
85	8	
90	4	
95	2	
100	1	
105	0,5	
110	0,25	
115	0,125	

កំណត់សម្គាល់ៈ

កម្រិតសស្តង់ដារនេះអនុវត្តសម្រាប់ការត្រួតពិនិត្យកម្រិតសម្លេងនៅក្នុងទីតាំងរោងជាង រោងចក្រឧស្សាហកម្ម។

៣.១៦ សារាចរណ៍ណែនាំស្តីពីការអភិវឌ្ឍន៍តំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា

ការបង្កើតសារាចរណ៍ណែនាំស្តីពីការអភិវឌ្ឍន៍តំបន់ឆ្នេរសមុទ្រ នៃព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងគ្រប់គ្រង និងអភិវឌ្ឍន៍តំបន់ឆ្នេរឲ្យបានត្រឹមត្រូវ មានប្រសិទ្ធភាព និងចីរភាព ដើម្បីជៀសវាងនិងទប់ស្កាត់ផលប៉ះពាល់ដល់ការអភិវឌ្ឍន៍ទេសចរណ៍ សេដ្ឋកិច្ចសង្គម បរិស្ថាន វប្បធម៌ និងប្រពៃណីតំបន់ឆ្នេរ។ ការដាក់សារាចរនេះ ដើម្បីណែនាំដល់ក្រសួង ស្ថាប័ន ពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិអនុវត្តនូវគោលការណ៍គ្រប់គ្រង ប្រើប្រាស់ ថែរក្សា ការពារ និង

Draft

អភិវឌ្ឍតំបន់ឆ្នេរសមុទ្រព្រះរាជាណាចក្រកម្ពុជា ដែលរួមមានដែនគោក កោះ និងដែនទឹកដូចខាងក្រោម៖

១. ឆ្នេរសមុទ្រ

ឆ្នេរសមុទ្រត្រូវកំណត់ចាប់ពីខ្សែបន្ទាត់ទឹកជោរខ្ពស់បំផុតនៃទឹកសមុទ្រឡើងមកលើ រហូតដល់ខ្សែបន្ទាត់ហាមឃាត់ការកាន់កាប់ ឬសាងសង់នានាជាច្ម ដ ឬខ្សាច់ដែលបានកំណត់ទុកជាតំបន់សម្រាប់ប្រើប្រាស់ជាសាធារណៈ និងត្រូវចាត់ជាដីសាធារណៈរបស់រដ្ឋ។ ទំហំឆ្នេរសមុទ្រត្រូវកំណត់ដូចខាងក្រោម៖

- ឆ្នេរជម្រាល ត្រូវកំណត់យ៉ាងតិច៣០ម៉ែត្រ ចាប់ពីខ្សែបន្ទាត់ខ្ពស់បំផុតទៅខាងដីគោក
- ឆ្នេរចោទត្រូវកំណត់យ៉ាងតិច២០ម៉ែត្រ ចាប់ពីចំណុចកំពូលនៃផ្ទៃចោទមកខាងដីគោកក្នុងករណីដែលស្ថានភាពទីតាំងជាក់ស្តែង នៃឆ្នេរជម្រាលមិនអាចកំណត់តាមទំហំខាងលើបាន ទំហំឆ្នេរសមុទ្រត្រូវកែច្នៃ ឬពង្រីកបន្ថែម ដើម្បីបង្កើតជាឆ្នេរសម្រាប់ដើរលេងកំសាន្ត។

នៅលើឆ្នេរសមុទ្រ អាចអនុញ្ញតឲ្យដាក់ឆ័ត្រ កៅអី និងតុតូចៗតាមចំនួនសមស្របដែលអាចផ្លាស់ប្តូរទីតាំងបាន សម្រាប់គោលដៅសម្រាកលំហែរកាយ និងត្រូវរៀបចំដាក់តូបឆ្មាំសមុទ្រដោយបំពាក់សម្ភារៈ និងឧបករណ៍ចាំបាច់តាមតម្រូវការ ដើម្បីឃ្លាំមើល និងការពារសុវត្ថិភាពជូនសាធារណៈជន និងអ្នកទេសចរ។

២. ដីចំណីឆ្នេរសមុទ្រ និងការប្រើប្រាស់

ដីចំណីឆ្នេរសមុទ្រ ជាទូទៅប្រើប្រាស់សម្រាប់ជាសួនបៃតង និងបណ្តាញទេសភាពឬសម្រាប់ដាំដើមឈើសម្គាល់ព្រំឆ្នេរ និងចំណីឆ្នេរដោយបន្តទៅជាប់នឹងផ្លូវសាធារណៈដែលស្ថិតក្នុងទិសខាងដីគោក។

២.១ ដីចំណីឆ្នេរសមុទ្រ

ដីចំណីឆ្នេរសមុទ្រ គឺជាផ្ទៃដីដែលចាប់រាប់ពីខ្សែបន្ទាប់ឆ្នេរខាងលើមកទិសខាងដីគោក។ ដីចំណីឆ្នេរជាដីសាធារណៈរបស់រដ្ឋ លើកលែងតែមានការកាន់កាប់ស្របច្បាប់។ ប្រវែងឬទំហំដីចំណីឆ្នេរសមុទ្រត្រូវកំណត់ដូចខាងក្រោម៖

- ប្រវែងទទឹងដីចំណីឆ្នេរសមុទ្រ ត្រូវកំណត់យ៉ាងតិច៥០ម៉ែត្រ ពីខ្សែបន្ទាត់ឆ្នេរខាងលើទៅខាងដីគោក។
- ក្នុងករណីដែលតាមបណ្តោយឆ្នេរសមុទ្រ មានផ្លូវសាធារណៈរួចហើយ ដីចំណីឆ្នេរសមុទ្រអាចកំណត់មកទល់នឹងផ្លូវសាធារណៈនេះ។

២.២ ការប្រើប្រាស់ដីចំណីឆ្នេរសមុទ្រ

ការប្រើប្រាស់ដីចំណីឆ្នេរសមុទ្រមានលក្ខណៈពិសេសដោយឡែកៗពីគ្នា តាមស្ថានភាពទីតាំងនីមួយៗ៖

ដីចំណីឆ្នេរសមុទ្រ ដែលមានប្រជាជនរស់នៅច្រើន និងមានលក្ខណៈជាទីប្រជុំជន ឬមានសកម្មភាពទេសចរណ៍ ការប្រើប្រាស់ ត្រូវបានកំណត់ដូចខាងក្រោម៖

- អាចអនុញ្ញាតឲ្យសាងសង់ជាសំណង់តូបតូចៗ សម្រាប់បម្រើដល់សេវាកម្មទេសចរណ៍នៅចន្លោះដើមឈើ ដែលមានចម្ងាយពីតូបមួយ ទៅតូបមួយទៀតយ៉ាងតិច១៥ម៉ែត្រ ដើម្បីសម្រួលដល់ការឆ្លងកាត់របស់សាធារណជននិងអ្នកទេសចរ និងរក្សាគំហើញទៅលំហសមុទ្រ។ សំណង់តូបតូចៗនេះត្រូវរៀបចំឲ្យបានត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេសភាពបៃតង។
- អាចអនុញ្ញាតឲ្យមានសំណង់ជានិមិត្តរូបផ្សេងៗ ជាលក្ខណៈរូបចម្លាក់ស្តូប ឬសិល្ប:សាធារណ:។
- អាចអនុញ្ញាតឲ្យមានចំណតយានយន្តទេសចរណ៍គ្រប់ប្រភេទ ចូលក្នុងបរិវេណដីចំណីឆ្នេរសមុទ្រ ដែលមិនប៉ះពាល់ដល់ស្ពានច្បារ និងទេសភាពបៃតងអាចអនុញ្ញាតឲ្យសាងសង់ជាបង្គន់អនាម័យសាធារណ: ដែលមានលក្ខណ:សោភណភាព និងចំនួនសមស្រប សម្រាប់បម្រើដល់សាធារណជន និងអ្នកទេសចរ ដោយស្ថិតនៅតាមទីតាំងសមស្រប និងមិនប៉ះពាល់ដល់ទស្សនីយភាពតំបន់។
- មិនអាចអនុញ្ញាតឲ្យមានសំណង់រឹងមាំនៅលើដីចំណីឆ្នេរសមុទ្រ លើកលែងតែសំណង់នៅត្រូវសាងសង់ឡើង ក្នុងគោលបំណងបម្រើប្រយោជន៍សាធារណ: និងទេសចរណ៍ដូចជា៖
  - ច្រកចូលឬស្ពានសម្រាប់ភ្ជាប់ទៅកំពង់ផែ ដែលមានទូកទេសចរណ៍ឬទូកម៉ាស៊ីនតូចៗសម្រាប់ភ្ញៀវទេសចរ ឬសាធារណជនប្រើប្រាស់។ កំពង់ផែទាំងនេះត្រូវមានទីតាំងសមស្រប និងមិនរំខានដល់សកម្មភាពឆ្លងកាត់ឆ្នេរសមុទ្រ។
  - សារមន្ទីរជីវ:ចម្រុះ រុក្ខជាតិសមុទ្រ ត្រីសមុទ្រ ដែលនៅផ្នែកខាងមុខសំណង់ស្ថាបត្យកម្មនេះអាចឲ្យភ្ញៀវទេសចរ ឬសាធារណជនអាចឆ្លងកាត់បាន។

៣. កោះជាផ្ទៃដីហ៊ុមព័ទ្ធដោយទឹកសមុទ្រ

ព្រំប្រទល់ដីកោះក្នុងសមុទ្រ ត្រូវកំណត់ត្រឹមខ្សែទឹកជោរអតិបរមាឡើងលើ។ កោះអាចមានទំហំតូចធំខុសៗគ្នា ដែលអាចប្រើប្រាស់ក្នុងគោលដៅផ្សេងៗ លើកលែងតែមានការកំណត់ដោយឡែក។ កោះអាចជាកម្មវត្ថុសម្រាប់ការរស់នៅនិងការអភិវឌ្ឍន៍ ស្របតាមគោលដៅនៃការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច ការពារជាតិ និងទេសចរណ៍។

៣.១ ការប្រើប្រាស់និងការអភិវឌ្ឍន៍កោះក្នុងកម្មវត្ថុសម្រាប់ការរស់នៅ

លើកលែងតែមានការហាមឃាត់ដោយច្បាប់ កោះមួយចំនួនអាចត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ជាបណ្តោះអសន្ន និងមិនទៀងតាមរយ:កិច្ចសន្យាច្បាស់លាស់។ ការអភិវឌ្ឍន៍កោះក្នុងកម្មវត្ថុនេះ ត្រូវគោរពតាមប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីព្រមទាំងបទបញ្ញត្តិ ជាធរមាន ឬតាមផែនការអភិវឌ្ឍន៍ដែលរាជរដ្ឋាភិបាល ក្រសួង ស្ថាប័នមានសមត្ថកិច្ចបានអនុញ្ញាត។

ចំពោះកោះដែលអនុញ្ញាតឲ្យប្រើប្រាស់ក្នុងកម្មវត្ថុនេះ តែពុំទាន់មានប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវរៀបចំសេចក្តីណែនាំលម្អិតសម្រាប់ការអនុវត្ត ស្របតាមស្ថានភាពជាក់ស្តែង និងគោរពតាមគោលការណ៍ដូចខាងក្រោម ៖

ត្រូវរក្សា និងការធនធានធម្មជាតិ ព្រៃឈើដែលមានស្រាប់ឲ្យបានយ៉ាងតិច៦០%

- ត្រូវមានសន្ទស្សន៍ទាប ដោយមានផលធៀបក្រឡាផ្ទៃបាតសំណង់ទាបជាង៣៥% ហើយផ្ទៃដីដែលនៅសល់ត្រូវរៀបចំដាំដើមឈើ និងធ្វើយ៉ាងតិច៥០%។
- ត្រូវសាងសង់សំណង់ដែលមានលក្ខណៈជាខ្មែរ។
- ត្រូវរៀបចំឲ្យមានលំហសាធារណៈ និងតំបន់កំសាន្តនានាឲ្យបានច្រើនជាអតិបរមា ដើម្បីជំរុញការមកលេងកំសាន្តរបស់សាធារណជន និងអ្នកទេសចរ។
- ត្រូវរៀបចំឲ្យមានកំពង់ផែនាវាចម្លងខ្នាតតូច ឬកំពង់ផែទេសចរណ៍ដែលអាចអនុញ្ញាតឲ្យសាធារណជនទូទៅ ឬអ្នកទេសចរចេញចូលបាន។
- ត្រូវរៀបចំតំបន់កំសាន្តនានាក្នុងករណីមានឆ្នេរខ្សាច់ និងរៀបចំកសាងផ្លូវសាធារណៈនៅក្បែរឆ្នេរនេះ ស្របតាមស្ថានភាពនៃទីតាំងរបស់កោះ។ ក្រសួង ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធត្រូវផ្តួចផ្តើមរៀបចំគម្រោងកសាងផ្លូវនេះ និងដាក់ជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីពិនិត្យភាពសមស្របតាមគោលនយោបាយ និងបទដ្ឋានបច្ចេកទេសរៀបចំដែនដី និងនគរូបនីយកម្ម។ ផ្លូវសាធារណៈត្រូវមានទំហំសមស្របតាមបទដ្ឋានបច្ចេកទេស និងតម្រូវការនៃការប្រើប្រាស់ដ៏យូអង្វែង។
- ត្រូវរៀបចំឲ្យមានការគ្រប់គ្រងកាកសំណល់រឹង និងរាវតាមបទដ្ឋានបច្ចេកទេស ដើម្បីជៀសវាងការប៉ះពាល់ដល់បរិស្ថាន។
- ត្រូវធ្វើការថែរក្សា ការពារ កែច្នៃ និងប្រើប្រាស់ធនធានសមុទ្រ ប្រព័ន្ធអេកូឡូស៊ី ជីវចម្រុះគ្រប់ប្រភេទ ដូចជាផ្កាថ្ម ត្រី និងរុក្ខជាតិសមុទ្រជាដើម ដែលមាននៅជុំវិញកោះ សម្រាប់គោលដៅទេសចរណ៍។

៣.២ ការអភិវឌ្ឍន៍ និងការសាងសង់នៅលើកោះក្នុងកម្មវត្ថុផ្សេងក្រៅពីការរស់នៅ

រាជរដ្ឋាភិបាលកម្ពុជាអាចធ្វើការអភិវឌ្ឍន៍កោះដោយផ្ទាល់ ឬសហការជាមួយវិស័យឯកជន ឬផ្តល់សិទ្ធឲ្យឯកជនធ្វើការអភិវឌ្ឍន៍ ស្របតាមគោលការណ៍របស់រាជរដ្ឋាភិបាល។ បន្ទាប់ពីមានការសម្រេចពីរាជរដ្ឋាភិបាល បុគ្គលដែលទទួលបានសិទ្ធិត្រូវរៀបចំផែនការអភិវឌ្ឍន៍កោះ ជាលក្ខណៈរួបវន្តឲ្យបានសមស្រប និងដាក់ជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ពិនិត្យភាពសមស្របតាមគោលនយោបាយ និងបច្ចេកទេសរៀបចំដែនដី នគរូបណីយកម្ម និងសំណង់។ ការអភិវឌ្ឍន៍នេះ ត្រូវគោរពតាមគោលការណ៍ដូចខាងក្រោម៖

- ត្រូវមានសន្ទស្សន៍ទាប ឬមធ្យម
- ត្រូវការពារធនធានធម្មជាតិ និងរក្សាព្រៃឈើដែលមានស្រាប់ឲ្យបានយ៉ាងតិច៦០%

- ត្រូវសាងសង់សំណង់ដែលមានលក្ខណៈជាខ្មែរ
- ត្រូវរៀបចំប្លង់អភិវឌ្ឍន៍រូបវន្ត ដែលបង្ហាញពីការប្រើប្រាស់ដីតំបន់សាធារណៈ: សួនច្បារ សួនឧទ្យាន បណ្តាញបៃតង ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធដូចជាផ្លូវសាធារណៈ: ផ្លូវថ្មើរជើង ប្រព័ន្ធចម្រោះទឹកកខ្វក់ជាដើម ឲ្យបានត្រឹមត្រូវស្របតាមបទដ្ឋានបច្ចេកទេស និងស្ថានភាពភូមិសាស្ត្រ ត្រូវរៀបចំឲ្យមានកំពង់ផែនាវាចម្លងខ្នាតតូច ឬកំពង់ផែទេសចរណ៍ ដែលអាចឲ្យអ្នកដំណើរ និងសាធារណៈជនអាចចេញចូលបានតាមស្ថានភាពជាក់ស្តែង និងមានទីតាំងសមស្រប.
- ត្រូវរៀបចំឲ្យមានការគ្រប់គ្រងកាកសំណល់រឹង និងរាវ តាមបទដ្ឋានបច្ចេកទេស ដើម្បីជៀសវាងការបោះសំរាម និងការបង្ហូរទឹកកខ្វក់ចូលក្នុងសមុទ្រ ប្រព័ន្ធអេកូឡូស៊ី ជីវៈចម្រុះគ្រប់ប្រភេទដូចជាថ្ម ត្រី និងរុក្ខជាតិសមុទ្រ ដែលមាននៅជុំវិញកោះដើម្បីគោលដៅទេសចរណ៍។

រាល់ការអភិវឌ្ឍន៍ក្នុងតំបន់ឆ្នេរសមុទ្រ កោះ និងការធ្វើសកម្មភាពសេដ្ឋកិច្ច និងទេសចរណ៍ ត្រូវធានាដល់សុវត្ថិភាពសាធារណៈ: សង្គម និងបរិស្ថាន ដោយត្រូវគោរពតាមច្បាប់ បទដ្ឋានគតិយុត្តិ និងបទដ្ឋានបច្ចេកទេសជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

៣.១៧ គោលនយោបាយចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល

យុទ្ធសាស្ត្រចតុកោណ ត្រូវបានរៀបចំឡើងទៅតាមរចនាសម្ព័ន្ធជាមុំបួន នៃចតុកោណដែលប្រទាក់ក្រឡាគ្នា ហើយផ្សារភ្ជាប់នៅគ្រប់ជ្រុងទាំងអស់។ ជារួម សមាសធាតុនៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២នេះមានដូចតទៅ: ចតុកោណយុទ្ធសាស្ត្រទាំងបួនសំរាប់ជំរុញកំណើនរួមមាន៖

<u>ចតុកោណទី១</u> ៖ ការលើកស្ទួយវិស័យកសិកម្ម

មុំទី១ ៖ ការលើកកំពស់ផលិតភាព ពិពិធភាពរូបនីយកម្ម និងពាណិជ្ជូបនីយកម្ម

មុំទី២ ៖ ការលើកកម្ពស់ការចិញ្ចឹមសត្ត និងវារីវប្បកម្ម

មុំទី៣ ៖ កំណែទម្រង់ដីធ្លី ការបោសសម្អាតមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម

មុំទី៤ ៖ ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព

<u>ចតុកោណទី២</u>៖ ការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត

មុំទី១ ៖ ការអភិវឌ្ឍន៍វិស័យហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងហេដ្ឋារចនាសម្ព័ន្ធទីក្រុង

មុំទី២ ៖ ការគ្រប់គ្រងធនធានទឹក និងប្រព័ន្ធធារាសាស្ត្រ

មុំទី៣ ៖ ការអភិវឌ្ឍវិស័យថាមពលអគ្គិសនី

មុំទី៤ ៖ ការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍។

<u>ចតុកោណទី៣</u>៖ ការអភិវឌ្ឍវិស័យឯកជន និងការងារ

មុំទី១ ៖ ការពង្រឹងវិស័យឯកជន និងការជំរុញការវិនិយោគ និងធុរកិច្ច

មុំទី២ ៖ ការអភិវឌ្ឍឧស្សាហកម្ម និងសហគ្រាសធន់តូច និងមធ្យម

មុំទី៣ ៖ ការអភិវឌ្ឍទីផ្សារការងារ

មុំទី៤ ៖ ការអភិវឌ្ឍវិស័យធនាគារ និងហិរញ្ញវត្ថុ

<u>ចតុកោណទី៤</u>៖ ការកសាងសមត្ថភាព និងការអភិវឌ្ឍន៍ធនធានមនុស្ស

មុំទី១៖ ការពង្រឹង និងការលើកកម្ពស់វិស័យអប់រំ វិទ្យាសាស្ត្រ បច្ចេកវិទ្យា ព្រមទាំងការបណ្តុះបណ្តាលបច្ចេកទេស

មុំទី២ ៖ ការលើកកម្ពស់សុខភាព និងអាហារូបត្ថម្ភ

មុំទី៣ ៖ ការអភិវឌ្ឍន៍ប្រព័ន្ធគាំពារសង្គម

មុំទី៤ ៖ ការអនុវត្តគោលនយោបាយជាតិប្រជាជន និងសមភាពយេនឌ័រ។

ក្នុងកថាខណ្ឌទី៧៥៖ ក្នុងគោលដៅនេះ **យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣** បានឆ្លុះបញ្ចាំងឱ្យឃើញយ៉ាងច្បាស់នូវរបៀបវារៈគោលនយោបាយសង្គម-សេដ្ឋកិច្ចរបស់កម្ពុជាសម្រាប់រយៈពេល ៥ឆ្នាំខាងមុខ ដែលផ្តោតទៅលើ "**គោលដៅជាយុទ្ធសាស្ត្រ ៤**" និង "**អាទិភាព ៤**" ដូចបានគូសបញ្ជាក់ពីខាងដើម។ ដូច្នេះ ក្នុងរយៈពេល៥ឆ្នាំខាងមុខ **យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣** នឹងនាំកម្ពុជាឱ្យបន្តដំណើរឈានឡើងរបស់ខ្លួនយ៉ាងស្វាហាប់តទៅទៀត ដោយឆ្លងកាត់នូវដំណើរការផ្លាស់ប្តូរជាប្រវត្តិសាស្ត្រ នៅក្នុងទិដ្ឋភាពប្រទាក់ក្រឡាគ្នាចំនួនបួនសំខាន់ៗគឺ៖

ទី១-ដំណើរការនៃការផ្លាស់ប្តូរពីបរិមាណទៅគុណភាពនៅក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច តាមរយៈកំណែទម្រង់រចនាសម្ព័ន្ធ ការបង្កើនផលិតភាព និងការធ្វើពិពិធភាវូបនីយកម្មសេដ្ឋកិច្ច សំដៅលើកកម្ពស់ភាពប្រកួតប្រជែងរបស់កម្ពុជា បង្កើនបរិយាប័ន្ធ ឬការចូលរួមរបស់ប្រជាជន ព្រមទាំងលើកស្ទួយសមធម៌សង្គម។ ដំណើរការផ្លាស់ប្តូរនេះ នឹងត្រូវបានឆ្លុះបញ្ចាំងតាមរយៈ (១) ការបន្តជំរុញអនុវត្តកំណែទម្រង់ដ៏ស៊ីជម្រៅទាំងឡាយ ពិសេសកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ កំណែទម្រង់រដ្ឋបាលសាធារណៈ និងកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុទ្ធធម៌ និង(២) ការបន្តវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការកែលម្អថែមទៀតនូវកិច្ចសម្រួលពាណិជ្ជកម្ម និងបរិស្ថានវិនិយោគ។

ទី២- ដំណើរការនៃការអភិវឌ្ឍឧស្សាហកម្ម តាមរយៈការដាក់ចេញ និងជំរុញអនុវត្តន៍ "**គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម**" និងការធ្វើពាណិជ្ជកម្មបនីយកម្មវិស័យកសិកម្ម ដើម្បីបង្កើនតម្លៃបន្ថែម ពោលគឺការអភិវឌ្ឍន៍វិស័យកសិកម្មកម្ពុជា ពីកសិកម្មបែបវិបុលកម្ម មានផលិតផលទាប និងផលិតសម្រាប់ផ្គត់ផ្គង់ខ្លួនឯង ទៅជាកសិកម្មបែបប្រពលកម្មមានផលិតភាពខ្ពស់ និងផលិតសម្រាប់ធ្វើពាណិជ្ជកម្ម។

ទី៣- ដំណើរការនៃការផ្លាស់ប្តូរពីការសង្កត់ធ្ងន់លើការវិនិយោគលើ "**មូលធនរូបវន្ត**" ទៅរកការផ្តល់សារៈសំខាន់កាន់តែខ្លាំងឡើងលើការវិនិយោគលើ "**មូលធនពុទ្ធិ**" ពោលគឺការអភិវឌ្ឍ

"**មូលធនមនុស្ស**" ពិសេសតាមរយៈការបង្កើនការវិនិយោគលើយុវជន និងការលើកកម្ពស់តួនាទីរបស់ យុវជននៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ព្រមទាំងការលើកស្ទួយសុខុមាលភាពរបស់ប្រជាជន ដោយផ្តោតជាសំខាន់លើស្ត្រី ទារក និងកុមារ។

ទី៤- ដំណើរការនៃការធ្វើសមាហរណកម្ម កាន់តែស៊ីជម្រៅទៅក្នុងសហគមន៍តំបន់ និងពិភពលោក ពិសេសការចូលរួមក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាន នៅឆ្នាំ២០១៥ ខាងមុខ ដោយខិតខំ ប្រើប្រាស់ឱ្យបានប្រកបដោយប្រសិទ្ធភាពខ្ពស់បំផុត នូវបណ្តាកាលានុវត្តភាព និងលក្ខខណ្ឌអំណោយផលទាំងឡាយ ដែលកើតចេញមកពីកិច្ចដំណើរការសមាហរណកម្មក្នុងតំបន់នេះ សំដៅទាក់ទាញប្រយោជន៍ជាអតិបរមាសម្រាប់កម្ពុជា ពិសេសតាមរយៈការតភ្ជាប់សេដ្ឋកិច្ចកម្ពុជាទៅនឹង បណ្តាញផលិតកម្មតំបន់ និងខ្សែសង្វាក់តម្លៃសកល។

៣.១៨ គោលការណ៍ណែនាំទូទៅក្នុងការធ្វើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញ

ប្រការ១៖ ប្រការនេះ មានគោលបំណងអនុវត្តគោលការណ៍ណែនាំទូទៅស្តីពី ការរៀបចំរបាយការណ៍ វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញ និងតារាងសង្ខេបដូចមានភ្ជាប់ក្នុង ឧបសម្ព័ន្ធ១ និង២ នៃប្រការនេះ។

ប្រការ២៖ ម្ចាស់គម្រោងជាបុគ្គលឯកជន ជាក្រុមហ៊ុន ជាក្រុមហ៊ុនចម្រុះរដ្ឋ ឬក្រុមហ៊ុនរដ្ឋ ជាក្រសួង\ស្ថាប័នរដ្ឋ ត្រូវរៀបចំរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញលើគម្រោងស្នើរឡើង ព្រមទាំងសកម្មភាពដែលមានស្រាប់ និងកំពុងដំណើការ ដូចមានចែងក្នុងឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៩ ស្តីពី "កិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន" ដើម្បីដាក់ជូនក្រសួងបរិស្ថានពិនិត្យនិងផ្តល់យោបល់ លើកលែងតែគំរោងដែលមានលក្ខណៈពិសេស និងចាំបាច់បន្ទាន់ដែលសម្រេចដោយរដ្ឋាភិបាល។

ប្រការ៣៖ ម្ចាស់គម្រោងដូចមានចែងនៅក្នុងប្រការ២ខាងលើ ត្រូវរៀបចំរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញលើគម្រោងដែលបានស្នើឡើង ព្រមទាំងសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការ ដូចមានចែងនៅក្នុងតារាង ឧបសម្ព័ន្ធនៃប្រការលេខ ២៣០ ប្រក.បស្ត ចុះថ្ងៃទី២៩ ខែ កក្កដា ឆ្នាំ ២០០៥ ស្តីពី "ប្រតិភូកម្មអំណាច ក្នុងការធ្វើសេចក្តីសម្រេចក្នុងនាមក្រសួង ចំពោះគម្រោងវិនិយោគជូន មន្ទីរបរិស្ថានខេត្ត-ក្រុង" ដើម្បីដាក់ជូនមន្ទីរបរិស្ថានរាជធានី-ខេត្តពិនិត្យ និងផ្តល់យោបល់ លើកលែងតែគម្រោងដែលមានលក្ខណៈពិសេស និងចាំបាច់បន្ទាន់ដែលសម្រេចដោយរាជរដ្ឋាភិបាល។

ប្រការ៨៖ ម្ចាស់គម្រោងដូចមានចែងនៅក្នុងប្រការ២ និង៣ខាងលើអាចប្រើបាស់សេវាកម្មរបស់ក្រុមហ៊ុនទីប្រឹក្សា ដែលជាអ្នកទទួលខុសត្រូវផ្ទាល់ក្នុងការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ដោយគោរពទៅតាមគោលរណ៍ណែនាំទូទៅនេះ។

ប្រការ៨៖ ករណីគម្រោងអាចសរសេររបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញដោយខ្លួនឯងផ្ទាល់ នោះក្រុមសរសេររបាយការណ៍ត្រូវតែមានសមត្ថភាពគ្រប់គ្រាន់ក្នុងការរៀបចំរបាយការណ៍ ដោយមានការទទួលស្គាល់ពីក្រសួងបរិស្ថាន។

ប្រការ៦៖ ក្រុមហ៊ុនមានចែងនៅក្នុងប្រការ៤ ត្រូវមានលក្ខណៈសម្បត្តិ សមត្ថភាពជំនាញគ្រប់គ្រាន់ក្នុងការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ មានចុះបញ្ជីការនៅក្រសួងពាណិជ្ជកម្ម និងមានការទទួលស្គាល់ពីក្រសួងបរិស្ថាន។

ប្រការ៧៖ នាយកដ្ឋានអង្កេត ពិនិត្យការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឬមន្ទីរបរិស្ថានរាជធានី-ខេត្តត្រូវពិនិត្យ និងផ្តល់យោបល់លើទីតាំងគម្រោង ដូចមានចែងនៅក្នុងប្រការ២ និង៣ ខាងលើ ដើម្បីកំណត់ឲ្យបានច្បាស់លាស់ថា គម្រោងនេះគួរតម្រូវឲ្យរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ។

ប្រការ៩៖ នាយកដ្ឋានអង្កេត ពិនិត្យការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឬមន្ទីរបរិស្ថានរាជធានី-ខេត្ត មានភារកិច្ចពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍តម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង ឬពេញលេញ ដោយអនុវត្តទៅតាមគោលការណ៍ណែនាំទូទៅនេះ។

Draft

ច្បាប់អន្តរជាតិ

Draft

ច្បាប់ Marpol 73/78

៣.១៩ Annex IV: បទប្បញ្ញត្តិសម្រាប់ការការពារនៃការបំពុលដោយទឹកស្អុយពីនាវា

បទប្បញ្ញត្តិទី១៖ និយមន័យ

១. លូទឹកស្អុយ៖

(a). ការបង្ហូរទឹកនិងកាកសំណល់ណាមួយដែលមានលក្ខណៈជា បង្គន់ ទឹកនោម និង ទឹកចេញពីបន្ទប់ទឹក។

(b). ការបង្ហូរទឹកពីបរិវេណពេទ្យ (កន្លែងចែកឱសថ បន្ទប់អ្នកជំងឺលើប៉ាល ។ល។) តាមរយៈអាងទឹក បំពង់ទឹក និង កន្លែងបង្ហូរទឹកចេញពីនាវា ដែលមានទីតាំងស្ថិតនៅក្នុងបរិវេណនោះ។

(c). ការបង្ហូរទឹកពីកន្លែងស្តុកសត្វនៅលើនាវា។

(d). ប្រភេទសំណល់រាវផ្សេងទៀតដែលបានលាយលំជាមួយការបង្ហូរទឹកខាងលើ។

២. ធុងស្តុកទឹក៖ ធុងដែលប្រើប្រាស់សម្រាប់ប្រមូល និងស្តុកទឹកស្អុយ។

៣. ទីតាំងដីនៅជិតបំផុត៖ ពាក្យថា "ពីទីតាំងដីដែលនៅជិតបំផុត" សំដៅដល់មូលដ្ឋានដែនសមុទ្រនៃដែនដីដែលកំពុងចោទជាសំនួរ គឺការអនុលោមឡើងទៅតាមច្បាប់អន្តរជាតិ លើកលែងតែសម្រាប់គោលបំណងនៃអនុសញ្ញាបច្ចុប្បន្ន "ពីទីតាំងដីដែលនៅជិតបំផុត" ចេញពីឆ្នេរសមុទ្រភាគខាងលិចសានៃប្រទេសអូស្ត្រាលីគួរមានន័យ ឬកំណត់ពីបន្ទាត់ដែលគូសចេញពីចំណុចនៅលើឆ្នេរនៃប្រទេសអូស្ត្រាលីដូចជា៖

- រយៈទទឹង ១១^{0}០០′ S, រយៈបណ្តោយ ១៤២^{0}០៨′ E
- ទៅចំណុច រយៈទទឹង ១០^{0}៣៥′ S, រយៈបណ្តោយ ១៤១^{0}៥៥′ E
- ពីទីនោះទៅចំណុច រយៈទទឹង ១០^{0}០០′ S, រយៈបណ្តោយ ១៤២^{0}០០′ E
- ពីទីនោះទៅចំណុច រយៈទទឹង ៩^{0}១០′ S, រយៈបណ្តោយ ១៤៣^{0}៥២′ E
- ពីទីនោះទៅចំណុច រយៈទទឹង ៩^{0}០០′ S, រយៈបណ្តោយ ១៤៤^{0}៣០′ E
- ពីទីនោះទៅចំណុច រយៈទទឹង ១៣^{0}០០′ S, រយៈបណ្តោយ ១៤៤^{0}០០′ E
- ពីទីនោះទៅចំណុច រយៈទទឹង ១៥^{0}០០′ S, រយៈបណ្តោយ ១៤៦^{0}០០′ E
- ពីទីនោះទៅចំណុច រយៈទទឹង ១៨^{0}០០′ S, រយៈបណ្តោយ ១៤៧^{0}០០′ E
- ពីទីនោះទៅចំណុច រយៈទទឹង ២១^{0}០០′ S, រយៈបណ្តោយ ១៥៣^{0}០០′ E
- ពីទីនោះទៅចំណុចដែលបិតនៅលើឆ្នេរសមុទ្រអូស្ត្រាលីក្នុង
- រយៈទទឹង២៤^{0}៤២′ S, រយៈបណ្តោយ ១៥៣^{0}១៥′ E។

Draft

បទប្បញ្ញត្តិទី២៖ ការអនុវត្ត

បទប្បញ្ញត្តិនៃ Annex នេះត្រូវអនុវត្តទៅលើ៖

1. នាវាថ្មីដែលមានចំណុះសរុបពី ២០០គោន នឹងលើសពីនេះ
2. នាវាថ្មីដែលមានចំណុះសរុបតិចជាង ២០០គោន ដែលត្រូវបានបញ្ជាក់ថាអាចដឹកមនុស្ស ច្រើនជាង១០នាក់។
3. នាវាថ្មីដែលមិនមានការវាស់ចំណុះសរុប និងដែលត្រូវបានបញ្ជាក់ថាអាចដឹកចំនួនមនុស្ស ច្រើនជាង១០នាក់។
4. នាវាចាស់ដែលមានចំណុះសរុប ២០០គោន នឹងលើពីនេះ, ១០ ឆ្នាំបន្ទាប់ពីកាលបរិច្ឆេទនៃ ការចូលជាធរមាននៃឧបសម្ព័ន្ធនេះ។
5. នាវាចាស់ដែលមានចំណុះសរុបតិចជាង២០០គោន ដែលត្រូវបានបញ្ជាក់ថាអាចដឹកមនុស្ស ច្រើនជាង១០នាក់ ១០ឆ្នាំបន្ទាប់ពីកាលបរិច្ឆេទនៃការចូលជាធរមាននៃឧបសម្ព័ន្ធនេះ។
6. នាវាចាស់ដែលមិនមានការវាស់ចំណុះសរុប និងដែលត្រូវបានបញ្ជាក់ថាអាចដឹកមនុស្ស ច្រើនជាង១០នាក់ ១០ឆ្នាំបន្ទាប់ពីកាលបរិច្ឆេទនៃការចូលជាធរមាននៃឧបសម្ព័ន្ធនេះ។

បទប្បញ្ញត្តិទី៣៖ ការត្រួតពិនិត្យ

(1) រាល់នាវាត្រូវបានតម្រូវឱ្យគោរពតាមបទប្បញ្ញត្តិនៃ Annexនេះ និងដែលត្រូវបានចូលរួមនៅ ក្នុងដំណើរទៅកាន់កំពង់ផែ ឬចំណតនៅឈូងសមុទ្រក្រោមយុត្តាធិការនៃភាគីផ្សេងទៀត នឹងគួរត្រូវអនុវត្តក្នុងការសង្ស័យមតិ ដែលបានបញ្ជាក់ខាងក្រោម៖

ក. ការស្រង់ទិន្នន័យដំបូងមុនពេលនាវានេះត្រូវបានដាក់អោយបម្រើ ឬមុនពេលវិញ្ញាបន បត្រ ត្រូវបានទាមទារ ដោយបិតនៅក្រោមបទប្បញ្ញត្តិ៤ នៃAnnex នេះត្រូវបានចេញជា លើកដំបូង ដែលនឹងមានរួមបញ្ចូលការស្រង់ទិន្នន័យនៃនាវាដែលនឹងត្រូវធ្វើឱ្យប្រាកដ ដូចជា៖

- នៅពេលនាវានេះត្រូវបានបំពាក់ដោយអាងប្រព្រឹត្តកម្មទឹកស្អុយ អាងនេះនឹងបំពេញ តាមតម្រូវការនៃប្រតិបត្តិការ ដោយផ្អែកលើស្តង់ដារ និងវិធីសាស្ត្រការធ្វើតេស្តដែល បង្កើតឡើងដោយអង្គការ។
- នៅពេលនាវានេះត្រូវបានបំពាក់ជាមួយប្រព័ន្ធ(អាងទឹកស្អុយ)ដើម្បី បំបែកសាធាតុ តូចៗ និងបំបាត់ឬសំលាប់មេរោគក្នុងលូទឹកស្អុយ ដែលប្រព័ន្ធអាងនេះគួរតែជាការ អនុម័តដោយរដ្ឋបាល។

Draft

- នៅពេលនាវានេះត្រូវបានបំពាក់ដោយធុងស្តុកសំណល់ទឹកស្អុយ កម្រិតសមត្ថភាពស្តុករបស់ធុងគួរតែបំពេញទៅតាមតម្រូវការឬការកំណត់របស់រដ្ឋបាល សម្រាប់បង្ការការប្រើប្រាស់បរិមាណលើសនៃទឹកស្អុយ ដែលអាចកើតមានឡើងក្នុងពេលដំណើរនៃប្រតិបត្តិការនាវានេះ ចំនួនមនុស្សនៅក្នុងនាវា និងកត្តាពាក់ព័ន្ធផ្សេងទៀត។ ធុងស្តុកទឹកស្អុយនេះគួរសំដៅដល់ការចង្អុលបង្ហាញឱ្យច្បាស់ពីបរិមាណនៃចំណុះរបស់វា។
- នាវានេះត្រូវបានបំពាក់បំពង់បង្ហូរទឹក ដែលនាំឱ្យមានភាពងាយស្រួលសម្រាប់បង្ហូរទឹកស្អុយទៅកន្លែងទទួលបែងចែកទឹករួម ហើយប្រភេទដូចជាបំពង់បង្ហូរទឹកនេះបានតម្រូវតាមការតភ្ជាប់ស្តង់ដារនៅច្រាំង ក្នុងការអនុលោមតាមបទប្បញ្ញត្តិ 11 នៃAnnexនេះ។

ខ. ការស្រង់ទន្ទ័យឬការត្រួតពិនិត្យសាលឡើងវិញនោះត្រូវធ្វើឡើងក្នុងចន្លោះពេលណាមួយដែលបានកំណត់ដោយរដ្ឋបាល ប៉ុន្តែមិនឱ្យលើសពីប្រាំឆ្នាំ ដែលនឹងត្រូវធ្វើឡើងដើម្បីធានាថាឧបករណ៍ បំពង់បង្ហូរទឹក ការរៀបចំ និងសម្ភារៈគោរពបានពេញលេញតាមតម្រូវការរបស់កម្មវិធីរបស់ Annex នេះ។ ទោះជាយ៉ាងណា, ត្រង់ចំណុចរយៈពេលនៃ វិញ្ញាបនប័ត្រការទប់ស្កាត់ ការបំពុលទឹកស្អុយអន្តរជាតិ (1973) (International Sewage Pollution Prevention Certificate) ត្រូវបានពន្យារពេលដូចដែលមានបញ្ជាក់នៅក្នុងបទប្បញ្ញត្តិ ៧ (២) ឬ (៤) នៃAnnex នេះ។

(2) រដ្ឋបាលត្រូវបង្កើតវិធានការសមស្របសម្រាប់ការត្រួតពិនិត្យនាវា ដែលមិនស្ថិតនៅក្នុងប្រការ នៃកថាខ័ណ្ឌ (១) នៃបទប្បញ្ញត្តិនេះក្នុងគោលបំណងដើម្បីធានាថាប្រការនៃ Annex នេះត្រូវបានគោរព។

(3) ការស្រង់ទិន្ន័យរបស់នាវាដូចជាការអនុវត្តទាក់ទងនឹងបទប្បញ្ញត្តិនៃ Annex នេះនឹងត្រូវបានអនុវត្តដោយមន្ត្រីរដ្ឋបាល។ រដ្ឋបាលអាច, ទោះជាយ៉ាងណា, ការទុកចិត្តក្នុងការស្រង់ទិន្ន័យទាំងការអង្កេត បានតែងតាំងសម្រាប់គោលបំណង ឬដើម្បីអង្គការទទួលស្គាល់ដោយវា។ ក្នុងគ្រប់ករណីទាំងអស់ រដ្ឋបាលមានការព្រួយបារម្ភទៅលើការធានាទាំងស្រុងចំពោះ ការសម្រេចបរិបូណ៌ និងប្រសិទ្ធភាពនៃការប្រមូលទិន្ន័យនេះ។

(4) បន្ទាប់ពីការស្រង់ទិន្ន័យផ្សេងៗរបស់នាវាដែលបិតក្រោមបទប្បញ្ញត្តិនេះត្រូវបានធ្វើរួចរាល់, គ្មានការផ្លាស់ប្តូរសំខាន់ៗណាត្រូវធ្វើឡើងចំពោះ ឧបករណ៍ បំពង់បង្ហូរទឹក ការរៀបចំ ឬ

សម្ភារៈត្រូវបានរាយការណ៍ពីការស្រង់ទិន្នន័យដោយគ្មានការយល់ព្រមពីរដ្ឋការ លើកលែងតែមានការប្លាស់ប្តូរនៃបរិក្ខា ឬបំពង់បង្ហូរទឹកនោះដោយផ្ទាល់។

បទប្បញ្ញត្តិទី៨៖ ការចេញវិញ្ញាបនបត្រ

(1) An International Sewage Pollution Prevention Certificate (វិញ្ញាបនប័ត្រការការពារការបំពុលទឹកស្អុយអន្តរជាតិ) (១៩៧៣) នឹងត្រូវបានចេញ បន្ទាប់ពីការស្នង់មតិមួយដោយអនុលោមតាមប្រការនៃបទប្បញ្ញត្តិ ៣ នៃAnnexនេះ សម្រាប់នាវាណាមួយដែលបានធ្វើដំណើរទៅកាន់កំពង់ផែ ឬនៅចំណតក្នុងឈូងសមុទ្រ ក្រោមយុត្តាធិការរបស់ភាគីផ្សេងទៀតទៅលើអនុសញ្ញា។

(2) វិញ្ញាបនប័ត្រនេះត្រូវបានចេញដោយរដ្ឋបាល ឬដោយមនុស្ស ឬអង្គការសិទ្ធិអំណាច។ ក្នុងគ្រប់ករណីទាំងអស់នេះបានសន្ទ្ធត់ថា រដ្ឋបាលជាអ្នកទទួលខុសត្រូវពេញលេញសម្រាប់វិញ្ញាបនបត្រនេះ។

បទប្បញ្ញត្តិទី៨៖ ការបញ្ចេញទឹកស្អុយ

(1) អនុវត្តតាមប្រការនៃបទប្បញ្ញត្តិ ៩ នៃAnnexនេះ ការបង្ហូរទឹកស្អុយចូលទៅក្នុងសមុទ្រត្រូវបានហាមឃាត់ លើកលែងតែនៅពេល៖

(a) កប៉ាល់បានបញ្ចេញទឹកលូស្អុយ ដែលបានបំបែកជាសាធាតុតូចៗ និងដែលបានសម្លាប់មេរោគរួច ដោយប្រើប្រព័ន្ធដែលបានអនុម័តដោយរដ្ឋបាល មាននៅក្នុងការអនុលោមតាមបទប្បញ្ញត្តិ ៣ (១) (a) នៅចម្ងាយនាវាចរជាង ៧,៤ គីឡូម៉ែត្រពីទីតាំងដីជិតបំផុត ឬទឹកលូស្អុយដែលមិនទាន់ត្រូវបាន បំបែកឱ្យទៅជាភាគល្អិត ឬសម្លាប់មេរោគរួចនោះ នៅចម្ងាយជាង ២២,២គីឡូម៉ែត្រ ពីដែនដីដែលនៅជិតបំផុត ដែលបានលើកឡើងថានៅក្នុងករណីណាមួយ, ទឹកលូដែលត្រូវបានរក្សាទុកនៅក្នុងធុងស្តុកទឹកស្អុយ នឹងមិនត្រូវបានបញ្ចេញចោលភ្លាមៗទេ ប៉ុន្តែអាចបញ្ចេញក្នុងអត្រាមធ្យមនៅពេលនាវានេះកំពុងធ្វើដំណើរ និងកិច្ចដំណើរការនីតិវិធីនៅមិនតិចជាង ៤ knots (៧,៤ គីឡូម៉ែត្រ) ដែលអត្រានៃការបញ្ចេញចោលនេះ នឹងត្រូវបានអនុម័ត ដោយរដ្ឋបាលផ្អែកលើស្តង់ដារដែលបង្កើតឡើងដោយអង្គការ។

(b) នាវានេះមាននៅក្នុងប្រតិបត្តិការអាងប្រព្រឹត្តកម្មទឹកស្អុយ ដែលត្រូវបានបញ្ជាក់ដោយរដ្ឋបាល ដើម្បីបំពេញតាមតម្រូវការប្រតិបត្តិការបញ្ជូនទៅក្នុងបទប្បញ្ញត្តិ ៣ (១) (a) (i) នៃAnnex នេះ

(i) លទ្ធផលការធ្វើតេស្តនៃរោងចក្រនេះត្រូវបានដាក់ចុះនៅក្នុង International Sewage Pollution Prevention Certificate (វិញ្ញាបនប័ត្រការការពារការបំពុលលូទឹកស្អុយអន្តរជាតិ) (១៩៧៣) របស់នាវានេះ

(ii) លើសពីនេះទៀត,ការបង្ហូរសំណល់រាវមិនត្រូវប្រព្រឹត្តទៅក្នុងទម្រង់សំណល់រឹងអណ្តែតដែលអាចមើលឃើញ ឬក៏បណ្តាលឱ្យមានការចេញពណ៌ នៃទឹកនៅជុំវិញនោះ

(c) នាវានេះត្រូវស្ថិតនៅក្នុងដែនទឹក ដែលស្ថិតក្រោមយុត្តាធិការរបស់រដ្ឋ និងការបញ្ចេញទឹកសំអុយត្រូវបិតក្នុងការអនុលោមតាមលក្ខខណ្ឌមានផលប៉ះពាល់តិចតួច ដូចដែលត្រូវបានកំណត់ដោយរដ្ឋ។

(2) នៅពេលទឹកលូនេះ ត្រូវបានលាយជាមួយកាកសំណល់ផ្សេងៗ ឬសំណល់រាវដែលមានលក្ខខណ្ឌនៃការបញ្ចេញចោលផ្សេងៗគ្នា នោះច្បាប់បន្ថែមទៀតនឹងត្រូវបានអនុវត្តចំពោះផលប៉ះពាល់ដែលធ្ងន់ធ្ងរ។

បទប្បញ្ញត្តិទី៩៖ ករណីលើកលែង

បទប្បញ្ញត្តិទី ៨ ក្នុងAnnex នេះនឹងមិនត្រូវបានអនុវត្តក្នុង

(a). ការបង្ហូរទឹកសំអុយពីនាវាដែលចាំបាច់សម្រាប់គោលបំណងនៃការធានាសុវត្ថិភាពរបស់នាវាមួយនេះ និងអ្នកដែលនៅក្នុងនាវា ឬរក្សាជីវិតនៅលើសមុទ្រ

(b) ការបង្ហូរទឹកសំអុយបណ្តាលមកពីការខូចខាតនាវា ឬឧបករណ៍របស់នាវានោះ អាចធ្វើទៅបានលុះត្រាតែ ហេតុផលទាំងអស់បិតក្នុងករណីនៃការប្រុងប្រយ័ត្ន ដែលសមហេតុផលមួយ និងអាចទទួលយកបាន ដែលបានអនុវត្តនៅមុន និងក្រោយពេលការខូចខាតកើតឡើង សម្រាប់គោលបំណងនៃការការពារ ឬកាត់បន្ថយការបញ្ចេញចោល។

៣.២០ Annex V: បទប្បញ្ញត្តិសម្រាប់ការការពារនៃការបំពុលដោយសំណល់រឹងពីនាវា

បទប្បញ្ញត្តិទី២៖ ការអនុវត្ត

លុះត្រាតែគោលបំណងជាក់លាក់ត្រូវបានបញ្ជាក់ឱ្យច្បាស់ លើមិនដូច្នេះទេ ប្រការនៃ Annex នេះនឹងត្រូវអនុវត្តទៅលើនាវាទាំងអស់។

បទប្បញ្ញត្តិទី៣៖ ការហាមឃាត់ទូទៅនៃការបញ្ចេញសំណល់ទៅក្នុងសមុទ្រ

1. ការបោះចោលសំរាមទាំងអស់ទៅក្នុងសមុទ្រត្រូវបានហាមឃាត់ លើកលែងករណីដែលមានចែងក្នុងបទប្បញ្ញត្តិ ៤, ៥, ៦ និង៧ នៃ នៃAnnex នេះ

Draft

2. តាមរយៈបទប្បញ្ញត្តិទី ៧ នៃAnnex នេះ គម្រោងត្រូវកាត់បន្ថយសំណល់ប្លាស្ទិក ដូចជា ខ្សែសន្ទូច សំណាញ់ និងសំណល់ថង់ប្លាស្ទិក ចូលទៅក្នុងសមុទ្រ ហើយហាមដាច់ខាតចំពោះការដុតសំណល់ប្លាស្ទិកផ្សេងៗ។
3. លើកលែងតែមានចែងនៅក្នុងបទប្បញ្ញត្តិ ៧ នៃនៃAnnex នេះ ការបោះចោល សំណល់ប្រេងឆាទៅក្នុងសមុទ្រត្រូវបានហាមឃាត់។

បទប្បញ្ញត្តិទី៨៖ ការបោះចោលសំរាមក្រៅតំបន់ពិសេស

1. ការអនុវត្តតាមប្រការនៃបទប្បញ្ញត្តិ ៥, ៦ និង៧ នៃAnnex, ការបោះចោលសំរាមទាំងប៉ុន្មានទៅក្នុងសមុទ្រដែលបិតនៅក្រៅតំបន់ពិសេស នឹងត្រូវបានអនុញ្ញាតតែ ខណៈពេលដែលនាវានេះកំពុងធ្វើដំណើរ ហើយឱ្យឆ្ងាយពីទីតាំងដីដែលនៅជិតបំផុត តាមដែលអាចធ្វើទៅបាន ប៉ុន្តែក្នុងករណីដែលមិនតិចជាងៈ
   - ចំងាយ ៥,៥៥គីឡូម៉ែត្រពីដីគោកជិតបំផុត គឺសម្រាប់ការកាកសំណល់អាហារដែលត្រូវបានឆ្លងកាត់ ការបំបែក ឬកិនដោយគ្រឿងម៉ាស៊ីន។ កំទិចសំណល់ល្អិតៗ ដែលមានសមត្ថភាពឆ្លងកាត់សំណាញ់មានប្រហោងមិនលើសពី ២៥mm។
   - ចំងាយ ២២,២ គីឡូម៉ែត្រពីដីគោកជិតបំផុត គឺសម្រាប់កាកសំណល់អាហារដែលមិនទាន់បានបំម្ទែង ដោយមានអនុលោមតាមកថាខណ្ឌទី ១ ខាងលើ។
   - ចំងាយ ២២,២ គីឡូម៉ែត្រពីដីគោកជិតបំផុត គឺសម្រាប់សំណល់នាវាដឹកទំនិញដែលមិនអាចកែខៃដោយបានប្រើវិធីសាស្ត្រធម្មតាសម្រាប់នាវាមិនផ្ទុកទំនិញ។
   - សម្រាប់សំណល់សាកសពសត្វ គួធ្វើការបោះចោលឱ្យឆ្ងាយពីដីគោកដែលជិតបំផុត តាមតែអាចធ្វើទៅបាន ដោយបានដាក់បញ្ចូលទៅក្នុងគោលការដែលបង្កើតឡើងដោយអង្គការ។
2. ពពួកសាប៉ូ ឬសារធាតុសម្រាប់រក្សាភាពស្រស់មិនឱ្យឆាប់រលួយ ដែលមានក្នុងកន្លែងផ្ទុកទំនិញ ដំបូលនាវា និងទឹកត្រូវបង្ហូរចេញផ្នែកខាងក្រៅនាវា អាចបញ្ចេញចោលចូលទៅក្នុងសមុទ្រ ប៉ុន្តែសាធាតុទាំងនោះត្រូវតែ មិនបង្កគ្រោះថ្នាក់ឬផលប៉ះពាល់ធ្ងន់ធ្ងរដល់បរិស្ថានសមុទ្រ បានបញ្ចូលទៅក្នុងសេចក្តីណែនាំ ដែលបង្កើតឡើងដោយអង្គការ។
3. ពេលសំរាមបានលាយជាមួយវត្ថុផ្សេងៗ ឬត្រូវបានផ្ទុកដោយសារធាតុបំពុលដ៏ទៃទៀត ការបោះចោលត្រូវបានហាមឃាត់ ឬត្រូវមានលក្ខខណ្ឌបោះចោលដ៏ទៃទៀតនោះ លក្ខខណ្ឌច្បាប់បន្ថែមទៀតនឹងត្រូវបានអនុវត្ត។

Draft

បទប្បញ្ញត្តិទី៥៖ លក្ខខណ្ឌពិសេសសម្រាប់ការបញ្ចេញសំរាមពីទីតាំងនៅមួយកន្លែងឬកន្លែងអណ្តែតលើទឹក

1. ស្ថិតនៅក្រោមប្រការនៃកថាខ័ណ្ឌទី២ នៃបទប្បញ្ញត្តិនេះ ការបោះចោលសំរាមណាមួយចូលទៅក្នុងសមុទ្រពី ទីតាំងនៅមួយកន្លែងឬទីតាំងអណ្តែតលើទឹក និងពីគ្រប់នាវាទាំងអស់ដែលធ្វើដំណើរឆ្លងកាត់ក្នុងចំងាយ ៥០០ម៉ែត្រ ពីទីតាំងលើទឹកនោះ ត្រូវបានហាមឃាត់។

2. សំណល់ម្ហូបអាហារអាចបោះចោលទៅក្នុងសមុទ្រពី ទីតាំងនៅមួយកន្លែងឬកន្លែងអណ្តែតលើទឹក ដែលមានចំងាយ ២២,២គីឡូម៉ែត្រ ពីទីតាំងដីគោកជិតបំផុត និងពីគ្រប់នាវាដែលបានធ្វើដំណើរឆ្លងកាត់ក្នុងចំងាយ ៥០០ម៉ែត្រ ពីទីតាំងលើទឹកនោះ តែក្នុងករណីដែលសំណល់ត្រូវបានឆ្លងកាត់ម៉ាស៊ីនកិនបំបែកប៉ុណ្ណោះ។ សំណល់កំទេចកំទី ឬសំណល់អាហារដែលបានកិនទាំងនោះ ត្រូវមានលិទ្ធភាពឆ្លងកាត់សំណាញ់ច្រោះដែលមានទំហំប្រហោងមិនធំជាង២៥mm។

បទប្បញ្ញត្តិទី៦៖ ការបោះចោលសំរាមក្នុងតំបន់ពិសេស

1. ការអនុញ្ញាតអោយបោះចោលសំរាមទាំងឡាយខាងលើទៅក្នុងទឹកសមុទ្រនៃតំបន់ពិសេសគួរធ្វើឡើងនៅពេលនាវាកំពុងធ្វើដំណើរតាមផ្លូវ និងដូចខាងក្រោម៖

   - បោះចោលសំណល់អាហារទៅក្នុងទឹកសមុទ្រអោយឆ្ងាយពីទីតាំងដែលនៅជិតដីគោកបំផុតតាមដែលអាចធ្វើបាន ប៉ុណ្តែមិនត្រូវឱ្យជិតជាង ២២,២គីឡូម៉ែត្រពីទីតាំងដីគោកជិតបំផុត ឬជិតផែនទឹកកក។ សំណល់អាហារគួកិនឬបំបែកទៅជាដំតូចៗ ហើយអាចឆ្លងកាត់សំណាញ់ដែលមានប្រហោងមិនធំជាង ២៥mm។ សំណល់អាហារទាំងនោះមិនត្រូវមានផ្ទុកសារធាតុពុលពីសំរាមផ្សេងទៀត។ ការបោះចោលសំណល់ផលិទ្ធផលពីបក្សី រួមមានសាច់បក្សី និងផ្នែកផ្សេងទៀតនោះ ត្រូវបានហាមឃាត់ក្នុងតំបន់អង់តាក់ទិក លុះត្រាតែផលិទ្ធផលទាំងនោះត្រូវបានសម្អាតដើម្បីសំងួតឬសម្លាប់មេរោគ។

2. ការបញ្ចេញកចោលសំណល់នាវាដឹកទំនិញណាដែលមិនអាចប្រើប្រាស់ឡើងវិញបានតាមរយៈវិធីសាស្ត្រធសាមញ្ញសម្រាប់នាវាមិនដាក់ទំនិញនោះ រាល់លក្ខខណ្ឌខាងក្រោមអាចទទួលយកបាន៖

   - សំណល់នាវាដឹកទំនិញ ពពួកសាប៉ូ ឬថ្នាំរក្សាគុណភាពឱ្យនៅស្រស់ ដែលមាននៅក្នុងបំពង់បង្ហូរទឹកសំណល់(សម្រាប់លាងសម្អាតសម្ភារៈលើកាប៉ាល់) ហើយដែល

មិនរាប់បញ្ចូលសារធាតុបង្ករគ្រោះថ្នាក់ផ្សេងៗប៉ះពាល់ទៅដល់បរិស្ថានសមុទ្រនោះ បានបញ្ចូលទៅក្នុងសេចក្តីណែណាំដែលបានលើកឡើងដោយអង្គការ។

- ទាំងទិសដៅចូលចតនៅផែ និងទិសដៅចាកចេញទៅកាន់ផែបន្ទាប់ សុទ្ធតែបិតក្នុងតំបន់ពិសេស ហើយនាវានោះមិនអាចប្តូរទីតាំងចំណតនៅក្រៅតំបន់ពិសេសនៃកំពង់ផែទាំងពីបានទេ។
- កំពង់ផែ(អន្តរជាតិ)ដែលមិនមានសេវាឬកន្លែងប្រមូលប្រេងចម្រុះ សំរាមផ្សេងៗនៅលើពនាវា បានបញ្ចូលក្នុងសេចក្តីណែណាំដែលបានលើឡើងដោយអង្គការ។
- ដែលនៅក្នុងចំណុច ២.១ ២.២ និង២.៣ នៃកថាខណ្ឌនេះត្រូវបានបំពេញបន្ថែម, ការបញ្ចេញចោលរាលសំណល់រាវដែលមានផ្ទុកកាកសំណល់ គួរធ្វើឡើងអោយឆ្ងាយពីទីតាំងដីគោកជិត ឬពីផែនទឹកកកតាមដែលអាចធ្វើទៅបាន និងមិនឱ្យជិតជាង ២២.២គីឡូម៉ែត្រ ពីដីគោកជិតបំផុត ឬ ផែនទឹកកកដែលនៅជិតបំផុត។

3. ពពួកសាប៉ូ ឬថ្នាំរក្សាគុណភាពសាច់ឬបន្លែឱ្យនៅស្រស់ មាននៅលើដំបូលនាវា និងកន្លែងបញ្ចេញទឹកទៅក្រៅនាវានោះ អាចបង្ហូរចូលទៅសមុទ្របាន លុះត្រាតែក្នុងករណីដែលសារធាតុទាំងនោះមិនបង្កផលប៉ះពាល់ឬគ្រោះថ្នាក់ដល់បរិស្ថានសមុទ្រ ដែលមានរៀបរាប់ក្នុងសេចក្តីណែណាំធ្វើឡើងដោយអង្គការ។
4. ពេលសំរាមបានលាយជាមួយ ឬបានផ្ទុកជាតិពុលពីរបស់ផ្សេងទៀត ត្រូវបានហាមមិនឱ្យបោះចោល ឬក៏មានលក្ខខណ្ឌផ្សេងទៀតក្នុងការបោះចោល ហើយតម្រូវការតឹងរ៉ឹងបន្ថែមទៀតនឹងត្រូវបានអនុវត្ត។

**បទឃ្ឌ្ឌ្ឌ

2. ក្នុងស្ថានភាពដែលបានរៀបរាប់ក្នុងកថាខណ្ឌ ១ នៃបទប្បញ្ញត្តិនេះ ភាគីនៃកិច្ចព្រមព្រាងគួរអនុវត្តតាមវិធានទាំងនេះ ដើម្បីឱ្យប្រាកដថា នាវាឬកាប៉ាល់មិនត្រូវធ្វើដំណើរ រហូតដល់ស្ថានភាពត្រូវបានយកមកអនុវត្តទៅតាមការរៀបចំ ដែលបានអនុលោមតាមលក្ខខណ្ឌនៃ Annex នេះ។
3. រាល់នីតិវិធីទាក់ទងនឹងការត្រួតពិនិត្យនាវាឬកាប៉ាល់បរទេសនៅកំពង់ផែក្នុងរដ្ឋនីមួយៗ ដែលមានចែងក្នុងមាត្រា ៥ នៃកិច្ចព្រមព្រាងបច្ចុប្បន្ន គួរយកមកប្រើក្នុងបទប្បញ្ញត្តិនេះ
4. មិនមានបទប្បញ្ញត្តិណាមួយបានបកស្រាយ ឬបង្កើតឡើងដើម្បីកំរិតសិទ្ធ និងកាតព្វកិច្ចរបស់គូភាគី ដែលដាក់ចេញដើម្បីគ្រប់គ្រងលើតម្រូវក្នុងកិច្ចប្រតិបត្តិការ ដែលផ្តល់ជូនចំពោះកិច្ចព្រមព្រាងបច្ចុប្បន្ន។

៣.២១ Annex VI: **បទប្បញ្ញត្តិសម្រាប់ការការពារនៃការបំពុលខ្យល់ពីនាវា**

ជ់ពួក៨ៃ: **និយមន័យទូទៅ**

- **ការបញ្ចេញសារធាតុចញ្ចឹម**:មានន័យថាជាដំណើរការបញ្ចេញសំណល់ដែលមានផលប្រយោជន៍ទៅក្នុងឡចំហេះឧស្ម័នដែលមនុស្សបង្កើតជាម៉ាស៊ីនដុតចំហេះដែលស្ថិតក្នុងការគ្រប់គ្រងដំណើរការគ្រប់ពេលជាមួយនឹងឡចំហេះនោះនិង មានការគ្រប់គ្រងលើសីតុណ្ហភាពចន្លោះពី ៨៥០°C ទៅ ១២០០°C។
- ការកំណត់ No_x ៖ មានន័យថាតួរលេខស្តង់ដារសម្រាប់ការគ្រប់គ្រងការបញ្ចេញរបស់នីត្រូសែនអុកស៊ីត (NO_x) ដែលបញ្ចេញមកពីនាវា ក្នុងសន្ទិសិទ្ធដើម្បីរកដំណោះស្រាយ និងការកែប្រែលើច្បាប់នេះ។
- សារធាតុដែលធ្វើឲ្យធ្លុះធ្លាយស្រទាប់អូសូនត្រូវបានរកឃើញនៅលើការសាងសង់នាវា(board ship) ប៉ុន្តែវាមិនកំណត់ទៅនឹងៃ

  - បំពុងពន្លត់អគ្គីភ័យ
  - Halon 1211 Bromochlorcodifluoromethane
  - Halon 1301 Bromotrifluoromethane
  - Halon 2402 1,2-Dibromo-1,1,2,2-tetrafluoroethane (also known as Halon 114B2)

ការសាងសង់នាវា ការដុតរំលាយសមាសធាតុលោហៈ: មានន័យថាការរំលាយនៃសំណល់ឬធាតុផ្សំរបស់នាវាដែលជាប្រភេទសំណល់ឬសមាសធាតុបំពុលផ្សេងៗដែលបង្កើតកំឡុងពេលបំបែក រំលាយនៃបំណែកនាវាទាំងឡាយ។

ការសាងសង់នាវា/កប៉ាល់ ការដុតរំលាយ ម៉ាស៊ីនដុតរំលាយនាវា មានន័យថាម៉ាស៊ីនបំបែក ឬរំលាយវានាដែលបង្កើតឡើងដើម្បីដំណាក់កាលបឋមនៃការរំលាយសមាសធាតុរបស់នាវា។

នាវាដែលកំពុងដំណើរការ មានន័យថានាវា/កប៉ាល់ ដែលកំពង់ផ្ទុកប្រេងដែលមានបញ្ហាលិចធ្លាយសមាសធាតុពុលផ្សេងៗ ឬវាស្ថិតក្នុងដំណាក់កាលសាងសង់។

ការកែប្រែខ្លឹមសារច្បាប់នៃនាវាខ្វងប្រេង មានន័យថា:

1. ការតំឡើងម៉ាស៊ីននាវា ក្នុងឬក្រោយថ្ងៃទី១ ខែមករា ឆ្នាំ២០០០ នោះដែលធ្វើឲ្យមានការកែប្រែខ្លះទៅនឹងម៉ាស៊ីនដែលមានការបញ្ចេញលើសស្តង់ដានៃការបញ្ចេញដែលកំណត់ក្នុងបទប្បញ្ញត្តិ១៣ នៃច្បាប់ MARPOL 73/78, Annex VI, ទម្លាប់នៃការផ្លាស់ប្តូរម៉ាស៊ីនទាំងឡាយជាផ្នែកសំខាន់ក្នុងបច្ចេកទេសសម្អាតដែលមិនគួរប្រើប្រាស់ ការប្តូរលក្ខណៈនៃការបញ្ចេញនឹងមិនអាចត្រូតពិនិត្យបានក្នុងបច្ចេកទេសត្រួតពិនិត្យការសម្អាត "ការផ្លាស់ប្តូរខ្លឹមសារឲ្យមាននិរន្តរភាព" ដើម្បីកាត់បន្ថយផលប៉ះពាល់ក្នុងមួយផ្នែកឬច្រើនផ្នែកក្នុងការផ្លាស់ប្តូរផ្សេងៗ។
2. ការដំឡើងម៉ាស៊ីនលើនាវា/កប៉ាល់ មុនថ្ងៃទី១ ខែមករា ឆ្នាំ២០០០ នោះក៏មានការកែប្រែខ្លះចំពោះម៉ាស៊ីនដែលមានមានការបញ្ចេញសារធាតុបំពុលកាន់តែច្រើន នឹងធ្វើឲ្យដឹងនូវលក្ខណៈនៃការបញ្ចេញសារធាតុបំពុលដោយវិធីសាស្ត្រវាស់សារធាតុបំពុលធម្មតា ដែលបង្ហាញក្នុង៦.៣ (NO_x) ក្នុងភាពលើស នៃការអនុញ្ញាតនឹងកំណត់ក្នុង (៦.៣.១១) នៃ NO_x។ ការផ្លាស់ប្តូរជារួម ប៉ុន្តែវាមិនកំណត់ការគ្រប់គ្រង ឬក្នុងការកំណត់ប៉ារ៉ាម៉ែត្រនៃបច្ចេកទេសដូចជា ការផ្លាស់ប្តូរបីស្តុងម៉ាស៊ីន(camshaft) ប្រព័ន្ធដុតប្រេងឥន្ធនៈ ប្រព័ន្ធខ្យល់រូបសណ្ឋាននៃម៉ាស៊ីនដុតរំលាយ ឬរយៈពេលការប្រើប្រាស់ម៉ាស៊ីន។

សមាសធាតុផ្សំមានន័យថាជាផ្នែកខ្លះនៃសមាសធាតុនោះដែលអាចផ្លាស់ប្តូរនឹងមានឥទ្ធិពលលើដំណើរការបញ្ចេញ NO_x ដែលគ្រប់គ្រងដោយអ្នកបង្កើត/សាងសង់ និងផ្នែកគ្រប់គ្រងការកំណត់ចំនួន។

ការកំណត់ មានន័យថាការកែសម្រួលការផ្លាស់ប្តូរលក្ខណៈដែលមានឥទ្ធិពលលើដំណើរការបញ្ចេញសមាសធាតុបំពុល NO_x របស់ម៉ាស៊ីន។

នៅលើការកំណត់អំពី NO_x មានន័យថាជានិតិវិធីមួយដែលអាចសម្រួលអំពីបរិក្ខាកិច្ចដែលស្នើរសុំដើម្បីកំណត់ការប្រើប្រាស់នាវា/កប៉ាល់។ នៅពេលអនុញ្ញាតឲ្យប្រមូលទិន្នន័យ ឬនៅពេលធ្វើការផ្លាស់ប្តូរថ្មី ប្រចាំឆ្នាំ និងការធ្វើវិសោធនកម្ម ដូចដែរការស្នើសុំដើម្បីឲ្យប្រាកដត្រឹមត្រូវជាមួយនឹងការស្នើរសុំខ្លះចំពោះ ការកំណត់NO_x ឲ្យច្បាស់លាស់ដោយឧបករណ៍វាស់ដែលបង្កើតឡើងដោយអ្នកជំនាញ និងបង្កើនភាពទុកចិត្តដោយថ្នាក់ជាតិ ឬអ្នកគ្រប់គ្រងសិទ្ធិជំនាញនៅលើបញ្ហានេះ។

ជំពូកទី៥៖ ការស្នើរសុំនៃ Annex VI និងការប្រតិបត្តិ

៥.១ បទប្បញ្ញាត្តិ១២ ការធ្លុះធ្លាយស្រទាប់អូសូន

- បញ្ហា និងការបម្រុងទុកនៃបទប្បញ្ញាត្តិ៣ (មានគោលបំណងដើម្បីឲ្យមានសុវត្ថិភាពល្អចំពោះវានា/កប៉ាល់ ឬរក្សាទុកជីវិតដែលនៅក្នុងសមុទ្រ ឬលទ្ធផលនៃការបញ្ចេញសារធាតុបំពុលធ្វើឲ្យមានការបំផ្លាញស្រទាប់ អូសូន ឬការផ្លាស់ប្តូរផ្សេងទៀត) នៃច្បាប់ MAPOL Annex VI។ ការបញ្ចេញសារធាតុបំពុលដោយមិនបានដឹងខ្លួននឹងមិនអាចសន្និដ្ឋានពីការបញ្ចេញតិចបំផុត។ ការសន្និដ្ឋានលើការបញ្ចេញដែលកំពង់តែជួបប្រទះលើបញ្ហាដំណើរការ កំពង់បម្រើការ កំពង់ជួសជុល ឬប្រព័ន្ធរៀបចំឬបរិក្ខារកិច្ច។ ជារួមការបញ្ចេញសារធាតុបំពុលទៅក្នុងខ្យល់នេះមិនរួមបញ្ចូលបញ្ហាដែលតូចៗ ជាមួយនឹងការបង្កើតឬ ការកែច្នៃឡើងវិញនៃការធ្លុះធ្លាយស្រទាប់អូសូន។
- ក្រោយថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៥ ការដំឡើងឧបករណ៍ឬម៉ាស៊ីនដែលធ្វើឲ្យ អូសូនធ្លុះធ្លាយ(ODS) និងមិនអនុញ្ញាតទៀតឡើយ។
- ការដកចេញនូវម៉ាស៊ីនដែលធ្វើឲ្យប៉ះពាល់ដល់ស្រទាប់អូសូនប្រហែលនឹងមិនត្រូវពិន័យទេក្នុងសេវាកម្មទាំងឡាយដែលប្រាកដថាមិនអនុញ្ញាតឲ្យបញ្ចេញសារធាតុ ODS និងនៅពេលប្រើប្រាស់ឧស្ម័នធម្មជាតិ វានឹងផ្តល់ឲ្យនូវភាពសមរួលដល់សហគ្រាសជួសជុល ឬបំបែកនាវា/កប៉ាល់។
- ប៉ុន្តែការដំឡើងថ្មីអាចប្រើប្រាស់បាននូវសាធាតុ hydro-chlorofluorocarbons (HCFCs) និងអនុញ្ញាតដល់ថ្ងៃទី១ ខែមករា ឆ្នាំ២០២០។

៥.២ បទប្បញ្ញាតិ១៣ នីត្រូសែនអុកស៊ីត (NO_x)

- ក្នុងខ្លឹមសារនៃបទប្បញ្ញាត្តិ១៣ បានកំណត់ដែនកំណត់លើការបញ្ចេញសារធាតុបំពុលនីត្រូសែនអុកស៊ីត (NO_x) ដែលចេញពីចំហេះរបស់ម៉ាស៊ីន។ គោលបំណងនៃបទប្បញ្ញាត្តិនេះគឺដើម្បីកាត់បន្ថយការបញ្ចេញសារធាតុបំពុល ដែលបណ្តាលមកពីចំហេះរបស់ម៉ាស៊ីននាវា/កប៉ាល់ ជាមួយនឹងផលប៉ះពាល់។ នៅថ្ងៃទី១ ខែមករា ឆ្នាំ២០០០ ក្នុងកំឡុងពេលនេះត្រូវត្រួតពិនិត្យពិតប្រាកដពីបរិមាណនៃការបញ្ចេញនីត្រូសែនអុកស៊ីត (NO_x) របស់នាវាដែលបញ្ចេញ និងមិនបានបង្កើនថែមនូវការបញ្ចេញសារធាតុបំពុល។
- ការកំណត់ការបញ្ចេញ (NO_x)ត្រូវបានអនុវត្តដោយផ្អែកលើអត្រានៃល្បឿនរបស់ម៉ាស៊ីនដែលបញ្ចេញ និងអនុវត្តតាមការកំណត់ខាងក្រោម។

g/KWh	RPM
17.0	N<130
$45.0\ X\ n^{(-0.2)}$	N ≥ 130 but < 2000

9.8	N ≥ 2000

- នាវា/កប៉ាល់ថ្មីៃ៖ ទោះជាយ៉ាងណាបទប្បញ្ញាត្តិ១៣គឺមិនបញ្ចូលជាកំហិតរបស់ Annex VI នៃច្បាប់ MAPOL 73/78។ ចំហេះពីម៉ាស៊ីន (ចំហេះម៉ាស៊ីនត្រូវបានលើកលែង ការតំឡើងម៉ាស៊ីនទូកធម្មតា និងម៉ាស៊ីនផ្សេងៗទៀតឬម៉ាស៊ីនបំរុងទុកសម្រាប់ប្រើក្នុងពេលមានអាសន្ន) ជាមួយនឹងថាមពលខាងក្រៅដែលច្រើនជាង ១៣០KWh ដែលដំឡើងលើនាវា មិនកំណត់GT។ ការសាងសង់នៅក្នុងឬក្រោយ ថ្ងៃទី១ ខែមករា ឆ្នាំ២០០០ គឺធានាឬជំនួសឲ្យបានចំពោះ អាជ្ញាធមិជាតិទៅនឹងការស្នើសុំការទប់ស្កាត់ក្នុងបញ្ហាការកំណត់ស្តង់ដារ NO_x ។
- ការបញ្ចេញ NO_x ដោយនាវាចំហេះម៉ាស៊ីន
  a) គឺការផ្លាស់ប្តូរថ្មីនៃម៉ាស៊ីនចាស់
  b) ការកែសម្រួសប្រព័ន្ធម៉ាស៊ីន
  c) មានអត្រានៃការកើនឡើងច្រើនបំផុត១០% ឬច្រើននឹងអាស្រ័យទៅនឹងការបញ្ជាក់ពីការកំណត់ ការមិនកំណត់នៃថ្ងៃសាងសង់របស់នាវា ដោយហេតុនេះម៉ាស៊ីនដែលបានដំឡើងការផ្លាស់ប្តូរគឺអាស្រ័យលឹការសហាការណ៍ ពីទំនាក់ទំនងភាពនៃម៉ាស៊ីន។
- ការទទួលខុសត្រូវលើការកាត់បន្ថយនៃសាមាសធាតុបំពុល NO_x គឺដើម្បីគោរពគោលការណ៍នៃជីវិតជាមួយនឹងការកែច្នៃម៉ាស៊ីនដើម្បីកាត់ការបញ្ចេញសារធាតុបំពុល NO_x ម្តងបន្តិចៗរបស់ម៉ាស៊ីន គឺជាបែបផែបដែលម៉ាស៊ីនបញ្ចេញសារធាតុបំពុលជាមធ្យមច្រើន និងលឿនត្រូវសិក្សាឡើងវិញ ពីព្រោះវាបញ្ចេញទៅក្នុងខ្យល់ក្នុងរយៈពេលវែងហើយកំរិតសីតុណ្ហភាពខ្ពស់ក្នុងចំហេះនៃបំពង់ម៉ាស៊ីន។
- យោងលើសៀវភៅស្តង់ដារប៉ារ៉ាម៉ែត្រនៃម៉ាស៊ីន។
- គ្រប់ម៉ាស៊ីនដែលអនុវត្តតាមបទប្បញ្ញាត្តិ១៣ យោងតាមសៀវភៅស្តង់ដារប៉ារ៉ាម៉ែត្រម៉ាស៊ីនគឺដើម្បីការពារដោយផ្អែកលើការផ្លាស់ប្តូររបស់ស្តង់ដារប៉ារ៉ាម៉ែត្រចំហេះ នៃសមាសធាតុផ្សំរបស់ម៉ាស៊ីនដែលត្រូវបានកំណត់ និងប្រហែលមានឥទ្ធិពលលើការបញ្ចេញសារធាតុបំពុល NO_x។
- វាជាឯកសារដែលចាំបាច់ដើម្បីប្រមូលទិន្នន័យ និងការត្រួតពិនិត្យ ព្រោះវាជួយកត់ត្រាសម្រាប់ការកែប្រែឲ្យល្អចំពោះការត្រួតពិនិត្យម៉ាស៊ីន។ បញ្ហាខ្លះនៃការប្រមូលទិន្នន័យនឹងជួយសម្រួលឲ្យស្រួលក្នុងការពិនិត្យចំពោះសៀវភៅដែលកត់ត្រាដែលច្បាស់លាស់ដែលមិនផ្លាស់ប្តូរ និងអាចជួយបង្កើតម៉ាស៊ីនដែលមានប្រសិទ្ធិភាពលើការបំភាយសារធាតុបំពុលNO_x។ អ្នកគ្រប់គ្រងកប៉ាល់/នាវា ត្រូវច្បាស់លាស់អំពីសៀវភៅកត់ត្រា

របាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាននិងសង្គមពេញលេញ លើគម្រោង ខ្សែកាប៉ូ អ្ន ១ ១ ១

ដែលត្រូវពិនិត្យជានិច្ច។ ប្រសិនជាការកំណត់លើម៉ាស៊ីនមិនត្រូវជាមួយសៀវភៅ នោះការប្រមូលទិន្នន័យពីម៉ាស៊ីន ដែលប្រហែលសន្និដ្ឋានច្រើនដងជាមួយអ្នកជំនាញដែលយល់ច្បាស់ និងមានទេពកោសល្យលើបញ្ហាការវាស់ការបញ្ចេញសារធាតុបំពុល NO_x។

៤.៣ បទប្បញ្ញត្តិ១៨ ស៊ុលហ្ហ្ស្ស្ត SO_x

- ការគ្រប់គ្រងលើការបញ្ចេញ SO_x ការសន្និដ្ឋានលើការបន្ថែមមួយនៃសមាសធាតុចំនួន ៤.៥%m/m លើ ស៊ុលភ្ជ (sulphur) នៃប្រេងឥន្ធនៈ និងផ្អែកលើការបង្ហាញរបស់ IMO ជាមធ្យមរបស់SO_x ក្នុងពិភពលោកដែលប្រើប្រាស់ប្រេងឥន្ធនៈ:
  (ដែលជាប្រភពដំបូងដែលមានឥទ្ធិពលលើសន្ធិសញ្ញា Protocol Guide to MARPOL 73/78, Annex VI, បទប្បញ្ញត្តិនេះសម្រាប់ការការពារទប់ស្កាត់ការបំពុលខ្យល់ពីនាវា/កប៉ាល់។
- ការគ្រប់គ្រងការបញ្ចេញសារធាតុបំពុល SO_x
- Annex VI ការទប់ស្កាត់ការនាំចូលដោយយោងតាមការគ្រប់គ្រងការបញ្ចេញក្នុងតំបន់ពិសេស និងការបង្កើតជាមួយនឹងការគ្រប់គ្រងជាបណ្តាញលើការបញ្ចេញ SO_x។ ក្នុងករណីនេះSO_x នៃឥន្ធនៈដែលប្រើលើនាវាជាទូទៅមិនអាចលើសពីចំនួន ១.៥%m/m ប្រសិនជានាវាមានការផ្លាស់ប្តូរជាមួយនឹងការបញ្ចេញ និងគ្រប់គ្រងសារធាតុបំពុលSO_x ក្នុងតំបន់ (SECA) នោះ៖
  - ការប្រើប្រាស់ប្រេងឥន្ធនៈជាមួយ SO_x ច្រើនបំផុត ១.៥%m/m
  - ការប្រើប្រាស់នូវប្រព័ន្ធឧស្ម័នធម្មជាតិឲ្យអស់លទ្ធភាព (ឧស្ម័នឥន្ធនៈធម្មជាតិមិនមាន SO_x) ដើម្បីកាត់បន្ថយការបញ្ចេញ SO_x សរុបរបស់នាវាទៅនឹង ៦g/Kwh ឬតិចជាងការគណនាទម្ងន់សរុបនៃ SO_x ដែលបញ្ចេញឬ
  - ប្រើប្រាស់បច្ចេកទេសវាស់ទម្ងន់ដើម្បីកាត់បន្ថយការបញ្ចេញ SO_x ឲ្យទាបជាង ៦g/Kwh។
- ទោះជាយ៉ាងណាកន្លែងដែលប្រើប្រាស់ឧស្ម័នឥន្ធនៈមិនមាន SO_x ការសំអាត Sulphur នោះសំណល់ទឹកគួរមិនត្រូវទទួលបានការពិន័យក្នុងតំបន់កំពង់ផែទេ ការចតនូវកន្លែងចំណត និងតាមផ្លូវសមុទ្រលុះត្រាតែវាមានឯកសារច្បាប់អនុញ្ញាតត្រឹមត្រូវលើនាវាដែលមិនមានការបញ្ចេញសំណល់ ការត្រួតពិនិត្យអំពីផលប៉ះពាល់ទៅលើប្រព័ន្ធអេកូឡូស៊ី នៃទីតាំងកំពង់ផែ ទីតាំងចំណតផ្លូវការ អាស្រ័យលើការសហប្រតិបត្តិក្នុងតំបន់ដោយប្រើសិទ្ធិនៃអង្គភាពកំពុងផែ IMO។
- Baltic Sea Area គឺបង្កើតឡើងសម្រាប់ការគ្រប់គ្រងការបញ្ចេញ SO_x ក្នុងតំបន់នៃសន្ធិសញ្ញា Protocol។ (ដាក់ឲ្យប្រើប្រាស់ចាប់ពី ថ្ងៃទី១៩ ខែ០៥ ឆ្នាំ២០០៦)

- ខែមីនា ឆ្នាំ២000 EMPC បានសម្រួល និងបំផុសឲ្យមានការកែប្រែខ្លះនៃច្បាប់ Annex VI ដោយរួមបញ្ចូលនៃសមុទ្រខាងជើងអំពីការគ្រប់គ្រងការបញ្ចេញ SO_x ក្នុងតំបន់ ក្នុងបំណងដើម្បីរក្សាទុកមាត្រាខ្លះនៃច្បាប់ MARPOL Annex ដែលបានដាក់ឲ្យប្រើប្រាស់វាត្រូវបានសង្ឃឹមថាសមុទ្រខាងជើងអាចចូលជាសមាជិក SECA 2007។

៤.៤ បទបញ្ញាត្តិ១៤ សាមាសធាតុសរីរាង្គប្រហើរ (Volatile Organic Compound) VOCs

- ប្រព័ន្ធប្រមូលសមាសធាតុរាវក្នុងខ្យល់ត្រូវតែសម្អាតឲ្យល្អ និងប្រកាសឲ្យនាវាចាកចេញពីកំពង់ផែ ឬចំណតដែលផ្តល់សិទ្ធ និងអនុញ្ញាតដោយច្បាប់ Annex VI ដែលជាអ្នកអាចប្រកាសអំពីការគ្រប់គ្រងកំពង់ផែ និងចំណតរបស់នាវា/កប៉ាល់ដោយសារការបញ្ចេញ VOCs។ ដូចនេះប្រព័ន្ធប្រមូលគឺនិងយល់ព្រមដោយនាយកដ្ឋាននេះដោយផ្អែកលើគោលបំណង ដែលមានការសម្រុះសម្រួលក្នុង MSC/Circ.585, ជាស្តង់ដារដើម្បីគ្រប់គ្រងការបញ្ចេញសមាសធាតុរាវក្នុងខ្យល់។ អាជ្ញាប័ណ្ណរបស់រដ្ឋត្រូវត្រួតពិនិត្យដោយ IMO នៃថ្ងៃដែលប្រត្តិបត្តិការ ទំហំរបស់នាវា និងប្រភេទនៃទំនិញ ដែលនឹងស្នើរក្នុងការគ្រប់គ្រងការបញ្ចេញ។ យ៉ាងហោចណាស់ ៦ខែដំបូងនៃថ្ងៃប្រត្តិបត្តិការដើម្បីការគ្រប់គ្រងចំណតនាវា។ ការបញ្ចេញចោលរបស់នាវាដោយមិនបានប្រព័ន្ធប្រមូលសមាសធាតុរាវក្នុងខ្យល់ប្រហែលជាអាចទទួលដោយចំណតជាមួយនឹងការបំពាក់ ការគ្រប់គ្រងការបញ្ចេញសមាសធាតុបំពុលរាវក្នុងខ្យល់ (VECs) ក្នុងរយៈពេល៣ឆ្នាំ ហើយពេលប្រត្តិបត្តិការរបស់ចំណតនាវានោះ។
- ប្រសិនជាអាជ្ញាធមិនៃប្រទេសនោះបានបង្កើតកំពង់ផែឬចំណតនាវា/កប៉ាល់ ដែលស្ថិតក្រោមការគ្រប់គ្រងដោយច្បាប់ ដូចជាការបញ្ចេញសារធាតុបំពុល VOCs គឺនឹងធ្វើឲ្យរៀបរយល្អនៃម៉ាស៊ីន ហើយមានប្រព័ន្ធគ្រប់គ្រងការបញ្ចេញសារធាតុរាវទៅក្នុងខ្យល់ ដែលយល់ព្រមដោយអាជ្ញាធម៌ និងកំពង់ដាក់ក្នុងគណនីយភាពនៃការចូលរួមក្នុងស្តង់ដារសុវត្ថិភាពក្នុងលក្ខណៈវិធីដើម្បីការជៀសវាងការយឺតយ៉ាវហួសហេតុ របស់អ្នកគ្រប់គ្រងនាវា/កប៉ាល់។
- IMO គួរតែបន្ថែមការកែប្រែនៅលើបញ្ជីនៃកំពង់ផែ និងចំណតនាវាក្នុងចំណោមសមាជិកទាំងអស់។
- បទប្បញ្ញាត្តិនេះផ្តល់តែនៅលើការដាក់បញ្ចូលឧស្ម័នធម្មជាតិ ក្នុងពេលដែលប្រទេសនោះកំពុងដំណើរការនឹងប្រព័ន្ធប្រត្តិបត្តិការដែលអនុញ្ញាតត្រឹមត្រូវនៃការទប់ស្កាត់ឧស្ម័នមេតាន (non-metheane) VOCs ដែលនៅលើទឹក និងមានសុវត្ថិភាពចំពោះដីគោក។

៤.៤ បទប្បញ្ញាត្តិ១៦ ការរំលាយបំបែកគ្រឿងនាវា/កប៉ាល់

- **នាវា/កប៉ាល់ថ្មី៖** ម៉ាស៊ីនរំលាយលោហៈសម្រាប់ការដំឡើងនាវា/កប៉ាល់ផ្សេងៗ គឺជាបញ្ហាដែលធ្វើឲ្យប៉ះពាល់ ដែលក្រោយថ្ងៃទី១ ខែមករា ឆ្នាំ២០០០ ដោយមានការជួយសម្រួលដោយអាជ្ញាធមិជាតិ ការគ្រប់គ្រងដោយផ្អែកលើការសម្រេចរបស់សភា MEPC.76(40)។ ស្ថង់ដារទូទៅលើការរំលាយលោហៈសម្រាប់ការសាងសង់បំបែកនាវា/កប៉ាល់ និងត្រូវស្នើរសុំតាមច្បាប់ Appendix IV to MARPOL 73/78, Annex VI, សម្រាប់បញ្ហាទាក់ទង និងប្រភេទសម្រាប់សម្រួលការគ្រប់គ្រងដែនកំណត់ នៃការសាងសង់ និងការដុតរំលាយបំបែកលោហៈ នាវា។
- **ការបញ្ចេញចោលរបស់វានៃ៖** ការបញ្ចេញចោលសំណល់របស់នាវា ដែលបណ្តាលមកពីការសាងសង់ការដុតរំលាយបំបែកលោហៈសម្រាប់នាវា/កប៉ាល់ជាមួយ និងអាជ្ញាប័ណ្ណរបស់នាវា មុនឬក្រោយថ្ងៃទី១ ខែមករា ឆ្នាំ២០០០ ដែលត្រូវបានសម្រួលដល់ការគ្រប់គ្រងគ្រប់ប្រភេទក្នុងការសម្រេច (ចំណាំ៖ ក្នុងករណីដែលអាជ្ញាប័ណ្ណអស់សុពលភាពនោះ ការប្រគល់ឲ្យដំណើរការម៉ាស៊ីនដុតរំលាយបំបែកលោហៈនឹងផ្តល់ត្រឹមថ្ងៃទី១ ខែមករា ឆ្នាំ២០០០ ឬក្រោយ។
- ក្រុមប្រឹក្សាជាតិប្រហែលអនុញ្ញាតឲ្យអាចមាននូវម៉ាស៊ីនរំលាយបំបែក ដូចជា MEPC (33) លើនាវាមុនថ្ងៃទី៥ មេសា ឆ្នាំ២០០៥ ប៉ុន្តែក្រោយថ្ងៃទី១ ខែមករា ឆ្នាំ២០០០ ប្រហែលត្រូវបានបន្តក្នុងសេវាកម្ម ផ្តល់នូវការផ្លាស់ប្តូរដែលមិនទាន់បញ្ចប់ដែលមានឥទ្ធិពលលើលក្ខណៈនៃការបញ្ចេញ។
- MEPC.76(40) ការព្យាយាមធ្វើឲ្យមានសុវត្ថិភាពនៃបណ្តាញអគ្គីសនី និងម៉ាស៊ីន ការការពារអគ្គីភ័យ ការកំណត់ការបញ្ចេញការគ្រប់គ្រងដំណើរការម៉ាស៊ីន។ ម៉ាស៊ីនរំលាយបំបែកលោហៈដែលនៅលើនាវា/ទូក/កប៉ាល់។
- ការរំលាយបំបែកនាវា ដូចជាមានការអនុញ្ញាតតែមួយគត់ ក្នុងការរំពឹងទុកលើអ្នករំលាយបំបែកនាវា ដែលការរំលាយបំបែកនេះបានបង្កើតសំណល់រាវភក់ និងភក់ប្រេងកំឡុងពេលធ្វើប្រត្តិបត្តិការធម្មតានៃនាវាហើយប្រហែលជាបង្កើតក្នុងចំនួនច្រើនសម្រាប់ការបង្កើតអគ្គីសនី ឬបង្កើតកម្តៅខ្លាំង ប៉ុន្តែក្នុងបញ្ហានេះអាចមើលឃើញថាមិនមានបញ្ហាពេលនាវាស្ថិតក្នុងកំពង់ផែ ទីចំណត ឬតំបន់ផ្សេងទៀត។
- ច្បាប់ Annex គឺបានហាមឃាត់ការដុតរំលាយនាវា/កប៉ាល់ដោយ៖
  1. Annex I, II & III ដែលមានទំនិញនៅច្រើន និង មានការទាក់ទងនឹងការចម្លងមេរោគនៃកញ្ចប់សមាសធាតុផ្សេងៗ
  2. Polychlorinated biphenyles (PCBs)
  3. កញ្ចប់សំណល់ដែលមានជាប់នូវប្រភេទលោហៈធ្ងន់

Draft

4. ធ្វើការសម្អាត់ការផលិតប្រេងកាត់ និងសមាសធាតុគីមីដែលរួមផ្សំគ្នា។

បទឃ្លាគ្នា១៧ សេវាកម្មសម្រួលលើអគារ ការិយាល័យដែលនៅតំបន់ឆ្នេរ

- ក្នុងបទឃ្លាគ្នានេះនិយាយអំពីទំនួលខុសត្រូវក្នុងការបង់ពន្ធឲ្យទៅរដ្ឋាភិបាល (Parties to MARPOL Protocol of 1997)
  ដើម្បីផ្គត់តាមគោលការណ៍សេវាកម្មសម្រួលការគ្រប់គ្រងលើការបញ្ចេញចោលរបស់អគារការិយាល័យ សហគ្រាស។

a) ការធ្វើឲ្យមាននិរន្តរភាពចំពោះការធ្លុះធ្លាយស្រទាប់អូស្សូន និងបរិក្ខាកិច្ចដែលមិនមាន និរន្តរភាព ពេលដែលសម្អាតដែលបណ្តាលមកពីការជួសជុលនាវាក្នុងកំពង់ផែ។

b) ការធ្វើឲ្យមានការគ្រប់គ្រងការប្រើប្រាស់ឲ្យអស់លទ្ធិភាព និងឧស្ម័នធម្មជាតិដោយ សម្រួលឲ្យមានការប្រើប្រាស់ប្រព័ន្ធឧស្ម័នធម្មជាតិឲ្យអស់លទ្ធភាពនៅកន្លែង ដែលមានការបន្ទរបន្ថយសម្រាប់ការបញ្ចេញកាកសំណល់ ដោយមិនអនុញ្ញាតក្រោមបទបញ្ញាត្តិ១៣នៃច្បាប់ Annex។ ការប្រើប្រាស់នូវសេវាកម្មដែលធ្វើឲ្យមានការប៉ះពាល់តិច ប្រហែលនឹងមិនមានបញ្ហាច្រើនលើការគ្រប់គ្រងការបញ្ចេញរបស់នាវាទេ។

- ទាំងនេះជាការបំរុងទុកសម្រាប់ការធ្វើរបាយការណ៍ស្នើសុំការធ្វើដំណើរ ដែលអាចប្រើប្រាស់បាន ឬមិនគ្រប់គ្រាន់នៃសេវាកម្ម ដែលអជ្ញាធមិជាអ្នកត្រួតពិនិត្យ និងជាអ្នកបើកឲ្យមានទំនាក់ទំនងអន្តរជាតិដូចទៅនិង IMO។ IMO បានចរាចរក្នុងពិភពលោកដោយមានការទទួលពត៌មានពីរដ្ឋាភិបាល។

៤.៧ បទឃ្លាគ្នា១៣ បរិមាណប្រេងឥន្ធនៈ

បទឃ្លាគ្នានេះសម្រាប់ការពិនិត្យ និងគ្រប់គ្រងរបស់រដ្ឋចំពោះការលក់ និងប្រើប្រាស់បានលើនាវា/កប៉ាល់ជាមួយនឹងគោលបំណងពិតប្រាកដអំពីការលិចធ្លាយប្រេង ពីទូក/នាវា ដែលជួយមិនឲ្យមានការបារម្ភពីការលិចធ្លាយនេះ។

- កិច្ចសន្យាពីការប្រើប្រាស់ប្រេងឥន្ធនៈលើទូក/នាវា
  - បញ្ចូលនូវអ៊ីដ្រូការបូដែលក្លាយមកពីប្រេងឆៅ
  - និងប្រើសេរីនូវអាស៊ីតសរីរាង្គ
  - មិនរួមបញ្ចូលសំណល់គីមី
    - មិនអនុគ្រោះលើប្រត្តិបត្តិការរបស់ម៉ាស៊ីនដែលធ្វើឲ្យមានផលប៉ះពាល់
    - ការធ្វើឲ្យមានការរំខានដល់អ្នកដ៏ទៃ
    - ការធ្វើឲ្យមានការបំពុលខ្យល់
- ការដឹកជញ្ជូនប្រេងដោយវិធីសាស្ត្រផ្សេងៗនៃប្រេងឆៅមិនអាចៈ

- លើសពីកំណត់ ៤.៥% និង១.៥% ជាការស្នើរនៃបទប្បញ្ញាតិ១៤
- ចំណុះនៃអាស៊ីតសរីរាង្គ
  - ការធ្វើឲ្យគ្រោះថ្នាក់នៃសុវត្ថិភាពនាវា/កប៉ាល់ ឬមានផលប៉ះពាល់ដល់ប្រត្តិបត្តិការនៃម៉ាស៊ីន
  - ការធ្វើឲ្យមានការព្រួយបារម្ភដល់មនុស្ស
  - ធ្វើឲ្យមានការបំពុលខ្យល់។

- បទប្បញ្ញាតិនេះមិនគិតលើធ្យូងថ្ម ឬប្រភេទសមាសធាតុរឹង ឬភាពមិនច្បាស់លាស់នៃថាមពលឥន្ធនៈ។
- ទាំងនេះជាការផ្តល់ឲ្យដោយបទប្បញ្ញាតិ Port State Flag State authorities
  - ដើម្បីត្រួតពិនិត្យការផ្គត់ផ្គង់របស់កន្លែងស្តុកប្រេង និងមានការថតនូវរូបភាពដែលអាចទុកចិត្តបានដោយអ្នកជំនាញ
  - ដើម្បីពិនិត្យបញ្ជីការស្តុកនៃប្រេងឥន្ធនៈជាមួយកំពង់ផែដែលកំណត់អំពីបញ្ហានេះ
  - ដើម្បីយកសំណាកប្រេងពីនាវាទៅត្រួតពិនិត្យភាពដូចគ្នាជាមួយនឹង MARPOL 73/78, Annex VI requirement
  - ធ្វើឲ្យប្រាកដនៃសកម្មភាពត្រឹមត្រូវដើម្បីធានាឲ្យឃើញនូវភាពមិនមែនជាប្រេងក្រោមការយល់ព្រម (ដូចជាការយកឥន្ធនៈចេញពីនាវា) និងក្នុងបញ្ហាដែលមានការផ្គត់ផ្គង់ប្រេងឥន្ធនៈ។

៤.៨ បទប្បញ្ញាត្តិ១៩ ការស្នើរសុំកន្លែង និងការដំឡើងម៉ាស៊ីនខ្លងប្រេង

- MARPOL Annex VI៖ គឺមិនអនុញ្ញាតឲ្យមានការបញ្ចេញសារធាតុបំពុលដោយផ្ទាល់ដែលកើតឡើងដោយសារការរុករកប្រេង ការធ្វើអាជីវកម្មបូមប្រេង និងការភ្ជាប់ដំណើរការក្នុងសមុទ្រផ្សេងៗលើតំបន់ដែលមានផ្កាថ្ម។ ទោះជាយ៉ាងណាវាបានធ្វើឲ្យមានការភាយចេញសារធាតុបំពុលដោយម៉ាស៊ីនខ្ងងដែលប្រើក្នុងគោលបំណងតែមួយឬច្រើនសម្រាប់ការរុករក ការធ្វើអាជីវកម្មប្រេង និងការភ្ជាប់ដំណើរការក្នុងសមុទ្រលើតំបន់មានផ្កាថ្ម ហើយវាដូចគ្នានិងការផ្គត់ផ្គង់ថាមពលដល់ក្រុមវារិក ការធ្វើឲ្យមានការធ្លុះធ្លាយស្រទាប់អូស្សូនដោយក្រុមនាវិកប្រើប្រាស់ និងបញ្ចេញសារធាតុបំពុលក្នុងខ្យល់។
- ក្នុងនោះដែរ ការនៅនឹងមួយកន្លែង និងការអណ្តែតនៅលើផ្ទៃទឹក ជារូមនៃការត្រួតពិនិត្យប្រដាប់ខ្ងងប្រេង ដែលដូចគ្នាទៅនិងលក្ខណៈ នៃការពិនិត្យសម្រាប់នាវាតាមបំណងរបស់ច្បាប់Annex។ ការទទួលយកបានក្នុងការរំពឹងថាការបញ្ចេញសារធាតុបំពុលទៅក្នុងបរិយាកាសដោយផ្ទាល់ជាមួយនិងការគ្រប់គ្រងតែមួយក្នុងស្ថានភាពនេះហើយក៏មានការបង់ពន្ធដល់រដ្ឋាភិបាលដែលសម្រួលពីការគ្រប់គ្រងគុណភាពទឹកនៅតំបន់នោះ។